ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០




## គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤

ខែកុម្ភៈ ឆ្នាំ២០១៩

# អារម្ភកថា

កម្ពុជាបានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំ ឆ្លើយតបនឹងបរិបទតំបន់ សកលលោក ដែលមានមហិច្ឆតានិងវិសាលភាពធំទូលាយជាងមុន សំដៅលើកកម្ពស់គុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត ក្នុងក្របខណ្ឌទូលំទូលាយ គ្របដណ្តប់លើគ្រប់ប្រភេទ និងកម្រិតនៃការអប់រំ ជាពិសេស ស្របនឹងទស្សនវិស័យអភិវឌ្ឍន៍កម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ សមិទ្ធផលអប់រំ និងឧត្តមានុវត្តន៍ជាច្រើនដែលកម្ពុជាទទួលបានពីការអនុវត្តគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងផែនការអប់រំសម្រាប់ទាំងអស់គ្នា គឺជាមូលដ្ឋានដ៏សំខាន់ ដើម្បីឈានទៅសម្រេចការអប់រំក្នុងបរិបទឆ្នាំ២០៣០ ខាងមុខ។

វិស័យអប់រំ មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង និងសមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់ ដើម្បីរួមចំណែកលើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដែលជួយបង្កើនកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព។

ក្នុងន័យនេះ ការអប់រំសម្រាប់ឆ្នាំ២០៣០ ផ្តោតជាសំខាន់លើការផ្តល់សេវាប្រកបដោយគុណភាព សមធម៌ បរិយាបន្ន សម្រាប់អប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា រួមទាំងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេស ការសិក្សាពេញមួយជីវិត ដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ ស្របតាមយុគសម័យបច្ចេកវិទ្យា ក្នុងការបង្កើនសេដ្ឋកិច្ច និងសុខដុមជីវិតបុគ្គល និងសង្គម។

ផែនទីបង្ហាញផ្លូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា រៀបចំឡើង ដោយមានការពិគ្រោះយោបល់ និងការវិភាគយ៉ាងល្អិតល្អន់រវាងក្រសួង-ស្ថាប័ន អ្នកពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាបាននូវភាពប្រទាក់ក្រឡាគ្នាទៅនឹងគោលនយោបាយមានស្រាប់ ដែលធ្វើឱ្យផែនទីបង្ហាញផ្លូវនេះ មានចក្ខុវិស័យ គោលនយោបាយ និងយុទ្ធសាស្ត្រប្រកបដោយភាពប្រាកដប្រជា មានសង្គតិភាព ក្នុងការសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្តីពីការអប់រំ ឆ្នាំ២០៣០ ខាងមុខ។

ការអនុវត្តផែនទីបង្ហាញផ្លូវនេះឱ្យទទួលបានជោគជ័យ តម្រូវឱ្យមានការប្រឹងប្រែងរួមគ្នារវាងក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ វិស័យឯកជន សង្គមស៊ីវិល និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ វត្ថុបំណងនៃផែនទីបង្ហាញផ្លូវនេះនឹងសម្រេចបានតាមរយៈផែនការយុទ្ធសាស្ត្រវិស័យអប់រំរយៈពេលមធ្យមទៅតាមដំណាក់កាលនីមួយៗ។

ក្រសួងអប់រំ យុវជន និងកីឡា បង្ហាញពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការអភិវឌ្ឍធនធានមនុស្ស និងភាពជាពលរដ្ឋសកលឱ្យឆ្លើយតបនឹងបរិបទនៃការអភិវឌ្ឍកម្ពុជា។ ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធទាំងអស់ និងការអភិវឌ្ឍសមត្ថភាពសម្រាប់ការអប់រំឆ្នាំ២០៣០របស់អង្គការយូណេស្កូដែលបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំផែនទីបង្ហាញផ្លូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា។

ថ្ងៃអង្គារ ៨កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

# មាតិកា


| | | ទំព័រ |
|---|---|---|
| **១.** | **សេចក្តីផ្តើម** | ១ |
| ១.១ | សារតារ | ១ |
| ១.២ | ដំណើរការរៀបចំផែនទីបង្ហាញផ្លូវ | ២ |
| ១.៣ | រចនាសម្ព័ន្ធនៃផែនទីបង្ហាញផ្លូវ | ៤ |
| **២.** | **បរិបទនៃការអភិវឌ្ឍនៅប្រទេសកម្ពុជា** | ៥ |
| ២.១ | ស្ថានភាពប្រជាសាស្ត្រ និងសង្គម | ៥ |
| ២.២ | សេដ្ឋកិច្ច | ៧ |
| ២.៣ | អាទិភាព និងបញ្ហាប្រឈមសំខាន់ៗជុំវិញការអភិវឌ្ឍ | ៨ |
| **៣.** | **បរិបទនៃការអភិវឌ្ឍវិស័យអប់រំកម្ពុជា** | ១៤ |
| ៣.១ | រដ្ឋធម្មនុញ្ញ និងក្របខណ្ឌគតិយុត្ត | ១៤ |
| ៣.២ | រចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំ | ១៥ |
| ៣.៣ | អភិបាលកិច្ច និងហិរញ្ញប្បទានវិស័យអប់រំ | ១៥ |
| ៣.៤ | គោលនយោយបាយ យុទ្ធសាស្ត្រវិស័យអប់រំ | ១៦ |
| ៣.៥ | សមិទ្ធផលសម្រេចបានក្នុងវិស័យអប់រំ និងបញ្ហាប្រឈម | ១៨ |
| ៣.៦ | ការបន្សុំចំណុចដៅនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ទៅនឹង គោលនយោបាយអប់រំកម្ពុជា | ២៧ |
| ៣.៧ | សមិទ្ធផលអប់រំកម្ពុជា ៖ ទស្សនវិស័យប្រៀបធៀប | ៣១ |
| **៤.** | **ចក្ខុវិស័យ អាទិភាព គោលនយោបាយ និងយុទ្ធសាស្ត្រវិស័យអប់រំ** | ៣៤ |
| ៤.១ | ទស្សនវិស័យនៃការអភិវឌ្ឍរបស់កម្ពុជា | ៣៤ |
| ៤.២ | គោលបំណងនៃការអប់រំជាតិ | ៣៦ |
| ៤.៣ | ចក្ខុវិស័យវិស័យអប់រំ | ៣៧ |

៤.៤ គោលដៅរួមនៃផែនទីបង្ហាញផ្លូវសម្រាប់ការអប់រំឆ្នាំ ២០៣០ ៤០

៤.៥ អាទិភាពគោលនយោបាយសម្រាប់ឆ្នាំ ២០៣០ ៤០

**៥. ផែនការហិរញ្ញប្បទាន** ៨០

៥.១ ការធ្វើចំណោល ៨០

៥.២ ការផ្តល់ហិរញ្ញប្បទាន ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ ៨២

**៦. ការពិនិត្យតាមដាន និងវាយតម្លៃ** ៨៦

៦.១ រចនាសម្ព័ន្ធ និងដំណើរការនៃការពិនិត្យតាមដាន និងវាយតម្លៃ ៨៧

៦.២ ការពិនិត្យតាមដាន គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ - ការអប់រំ ឆ្នាំ២០៣០ ៨៩

៦.៣ ក្របខណ្ឌលទ្ធផលសំខាន់ៗ ៩៥

# តារាង


| | | |
|---|---|---|
| តារាងទី១ | សូចនាករប្រជាសាស្ត្រ | ៦ |
| តារាងទី២ | យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ (២០១៨-២០២៣) | ១៦ |
| តារាងទី៣ | កម្រិតនៃការបន្សុីគ្នាចំណុចដៅនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី៤ ឆ្នាំ២០៣០ទៅនឹងគោលនយោបាយ និងកម្មវិធីអប់រំកម្ពុជា ដែលកំពុងអនុវត្ត | ៣០ |
| តារាងទី៤ | ការប្រៀបធៀបសូចនាករមួយចំនួនរបស់កម្ពុជា និងប្រទេសមានចំណូល មធ្យមកម្រិតខ្ពស់ | ៣២ |
| តារាងទី៥ | ការប្រៀបធៀបចំណាយវិស័យអប់រំនៅកម្ពុជា និងប្រទេសមានចំណូលមធ្យម កម្រិតខ្ពស់ | ៣៣ |
| តារាងទី៦ | ចំណុចដៅសំខាន់ៗសម្រាប់ការគាំពារ និងអប់រំកុមារ និងការអប់រំមត្តេយ្យសិក្សា | ៤៣ |
| តារាងទី៧ | យុទ្ធសាស្ត្របង្កើនការចូលរៀន និងគុណភាពនៃការគាំពារនិងអប់រំកុមារតូច និងការអប់រំមត្តេយ្យសិក្សា | ៤៤ |
| តារាងទី៨ | ចំណុចដៅសំខាន់ៗ សម្រាប់ការអប់រំបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ | ៤៨ |
| តារាងទី៩ | យុទ្ធសាស្ត្រសម្រាប់កែលម្អការអប់រំកម្រិតមូលដ្ឋាន | ៤៨ |
| តារាងទី១០ | ចំណុចដៅសំខាន់ៗ សម្រាប់ការអប់រំមធ្យមសិក្សាទុតិយភូមិ | ៥៣ |
| តារាងទី១១ | យុទ្ធសាស្ត្រ សម្រាប់លើកកម្ពស់ការអប់រំមធ្យមសិក្សាទុតិយភូមិ | ៥៥ |
| តារាងទី១២ | យុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈនៅ មធ្យមសិក្សាទុតិយភូមិ | ៥៩ |
| តារាងទី១៣ | ចំណុចដៅសំខាន់ៗ សម្រាប់ការអប់រំឧត្តមសិក្សា | ៦២ |
| តារាងទី១៤ | យុទ្ធសាស្ត្រសម្រាប់កែលម្អការអប់រំឧត្តមសិក្សា | ៦៣ |
| តារាងទី១៥ | យុទ្ធសាស្ត្រសម្រាប់កែលម្អការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ | ៦៦ |
| តារាងទី១៦ | ចំណុចដៅសំខាន់ៗ សម្រាប់អក្ខរកម្មមនុស្សពេញវ័យ | ៧០ |
| តារាងទី១៧ | យុទ្ធសាស្ត្រសម្រាប់លើកកម្ពស់អក្ខរកម្មយុវជន និងមនុស្សពេញវ័យ | ៧០ |

| | | |
|---|---|---|
| តារាងទី១៨ | យុទ្ធសាស្រ្តសម្រាប់កែលម្អការគ្រប់គ្រងសាលារៀន | ៧៤ |
| តារាងទី១៩ | យុទ្ធសាស្រ្តសម្រាប់ពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំ | ៧៦ |
| តារាងទី២០ | យុទ្ធសាស្រ្តសម្រាប់លើកកម្ពស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | ៧៨ |
| តារាងទី២១ | ចំណោលប្រជាជន ចន្លោះពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០៣០ | ៨១ |
| តារាងទី២២ | ចំណោលសិស្សចូលរៀនតាមភូមិសិក្សា ចន្លោះពីឆ្នាំ ២០១៦ដល់ ២០៣០ | ៨១ |
| តារាងទី២៣ | ចំណោលតម្រូវការគ្រូបង្រៀន | ៨២ |
| តារាងទី២៤ | ការប៉ាន់ប្រមាណពីធនធានដែលមានសម្រាប់វិស័យអប់រំ | ៨៣ |
| តារាងទី២៥ | ការព្យាករណ៍ចំណាយ (ចំណាយចរន្ត និងចំណាយមូលធន) (គិតជាលានដុល្លារ) | ៨៤ |
| តារាងទី២៦ | គម្លាតថវិកា | ៨៤ |
| តារាងទី២៧ | ក្របខណ្ឌសូចនាករជាតិ សម្រាប់ពិនិត្យតាមដានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤-ការអប់រំឆ្នាំ២០៣០ | ៩១ |
| តារាងទី២៨ | ម៉ាទ្រិកលទ្ធផល | ៩៥ |

# ១. សេចក្តីផ្តើម

## ១.១ សាវតារ

សហគមន៍ជំនាញខាងអប់រំក្នុងសកលលោក តំណាងដោយអ្នកចូលរួមប្រមាណ ១ ៦០០ រូប មកពីប្រទេស ១៦០ ក្នុងនោះ មានរដ្ឋមន្ត្រី ១២០ រូប ប្រធាននិងសមាជិកគណៈប្រតិភូ តំណាងអង្គការពហុភាគី និងទ្វេភាគី អង្គការសង្គមស៊ីវិល សមាគមគ្រូបង្រៀន និងអ្នកដឹកនាំធុរកិច្ច បានអនុម័តសេចក្តីប្រកាសអ៊ីនឈ័ននៅក្នុងវេទិកាអប់រំពិភពលោក ទីក្រុងអ៊ីនឈ័ន សាធារណរដ្ឋកូរ៉េ កាលពីថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥។ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនេះ បានគូសបញ្ជាក់សាជាថ្មីនូវសេចក្តីអំពាវនាវ ដែលបានធ្វើឡើងនៅក្នុងសន្និសីទពិភពលោកស្តីពី ការអប់រំសម្រាប់ទាំងអស់គ្នា នៅទីក្រុងចុមទៀន ប្រទេសថៃ កាលពីឆ្នាំ១៩៩០ ដោយបានពិនិត្យបន្ថែមនិងអនុម័តគោលដៅទាំង ៦ នៅទីក្រុងដាកា ប្រទេសសេណេហ្គាល់ ឆ្នាំ២០០០។ សេចក្តីប្រកាសអ៊ីនឈ័ន គឺជាចំណុចចាប់ផ្តើមនៃការបន្តចក្ខុវិស័យអប់រំជាសកល ឆ្នាំ២០៣០ និងមានគោលបំណង "ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា"។ ការប្តេជ្ញាចិត្តថ្មី ចំពោះការអភិវឌ្ឍវិស័យអប់រំជាសកល បានដាក់ចេញនូវរបៀបវារៈកាន់តែគ្រប់ជ្រុងជ្រោយ ប្រកបដោយមហិច្ឆតាជាងមុន ដែលធ្វើឱ្យការអប់រំ "មានលក្ខណៈគ្រប់ជ្រុងជ្រោយ បរិយាបន្ន បណ្តុះនូវក្តីប៉ងប្រាថ្នា និងឆ្លើយតបចំពោះគ្រប់កាលៈទេសៈរបស់សកលលោក"។ របៀបវារៈអប់រំឆ្នាំ២០៣០ គឺជាគោលដៅទី៤ក្នុងចំណោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទាំង ១៧ នៃរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០៣០ ដែលបានអនុម័តក្នុងមហាសន្និបាតសហប្រជាជាតិលើកទី៧០ កាលពីខែកញ្ញា ឆ្នាំ២០១៥។ ការបញ្ចូលចក្ខុវិស័យអប់រំឆ្នាំ២០៣០ទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤បង្ហាញឱ្យឃើញថា របៀបវារៈអប់រំសកលមានតែមួយគឺ "គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ - របៀបវារៈអប់រំឆ្នាំ២០៣០"។ របៀបវារៈថ្មីនេះ បានពង្រីកវិសាលភាពគោលដៅអប់រំសម្រាប់ទាំងអស់គ្នាទាំង ៦ ដោយបានផ្តោតខ្លាំងថែមទៀតពីការចូលរៀនទៅជាការរៀនដែលមានលក្ខណៈបរិយាបន្ន សមធម៌ ប្រសិទ្ធភាព និងឆ្លើយតប ព្រមទាំងទទួលស្គាល់ថា ការរៀនសូត្រ គឺជាដំណើរការដែលកើតឡើងពេញមួយជីវិត។ របៀបវារៈនេះក៏បានដាក់ចេញនូវក្របខណ្ឌទូលំទូលាយ គ្របដណ្តប់លើការអប់រំ និងគ្រប់កម្រិត និងគ្រប់ប្រភេទទាំងអស់ផងដែរ។

ឆ្លើយតបនឹងសេចក្តីអំពាវនាវជាសកល ក្រសួងអប់រំ យុវជន និងកីឡាកម្ពុជាបានចាប់ផ្តើមរៀបចំផែនទីបង្ហាញផ្លូវ វិស័យអប់រំឆ្នាំ២០៣០ (ហៅកាត់ថា ផែនទីបង្ហាញផ្លូវ)។ ផែនទីបង្ហាញផ្លូវនេះបង្ហាញពីចក្ខុវិស័យអប់រំកម្ពុជាសម្រាប់ឆ្នាំ២០៣០ ដើម្បីឱ្យកម្ពុជាសម្រេចបានឋានៈជាប្រទេសចំណូល

មធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ផែនទីបង្ហាញផ្លូវនេះបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់កម្ពុជា ក្នុងការសម្រេចចំណុចដៅនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ដើម្បីឆ្លើយតបនឹងអាទិភាពនៃការអភិវឌ្ឍប្រទេស តាមរយៈការដាក់ចេញនូវក្របខណ្ឌរួម និងអភិក្រមរយៈពេលវែងដែលត្រូវអនុវត្តទូទាំងវិស័យសម្រាប់អភិវឌ្ឍវិស័យអប់រំ និងផ្តល់សេវាអប់រំ។ ផែនទីបង្ហាញផ្លូវនេះក៏ដាក់ចេញអាទិភាព និងយុទ្ធសាស្ត្រ ព្រមទាំងបង្ហាញពីជម្រើស និងអភិក្រមដែលអាចប្រើប្រាស់សម្រាប់ការអនុវត្តផែនទីបង្ហាញផ្លូវ និងបង្ហាញពីការវិភាគបញ្ហាប្រឈម និងឱកាសនានាជុំវិញការអនុវត្តផែនទីបង្ហាញផ្លូវផងដែរ។ ឯកសារនេះត្រូវបានរៀបចំ ដោយមានការគាំទ្របច្ចេកទេសពីអង្គការយូណេស្កូក្នុងក្របខណ្ឌនៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពវិស័យអប់រំ ដែលគាំទ្ររដ្ឋជាសមាជិកលើការពង្រឹងសមត្ថភាព ដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។ ក្នុងក្របខណ្ឌរបៀបវារៈអប់រំ ២០៣០-គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ឯកសារនេះប្រើប្រាស់អភិក្រមទូទាំងវិស័យដោយគ្របដណ្តប់លើការអប់រំនៅគ្រប់កម្រិត និងចំណុចដៅទាំងអស់នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ដោយឈរលើទស្សនវិស័យការសិក្សាពេញមួយជីវិត ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

## ១.២ ដំណើរការរៀបចំផែនទីបង្ហាញផ្លូវ

ផែនទីបង្ហាញផ្លូវត្រូវបានរៀបចំ ក្រោមការដឹកនាំរួម និងការណែនាំជាយុទ្ធសាស្ត្ររបស់ក្រុមការងារមួយ ដែលមានឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួន ណារ៉ុន** រដ្ឋមន្ត្រី ជាប្រធាន និងសមាជិក ៣៥ រូប ជាថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងអប់រំ យុវជន និងកីឡា តំណាងមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិលសំខាន់ៗ។ ក្រុមការងារបច្ចេកទេសមួយ ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡាបានផ្តល់ជំនួយបច្ចេកទេសដល់ការរៀបចំសេចក្តីព្រាងផែនទីបង្ហាញផ្លូវ។ ក្រុមការងារនេះមានសមាជិក ៤២ រូប មកពីក្រសួង ស្ថាប័នពាក់ព័ន្ធ នាយកដ្ឋានពាក់ព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល។ ក្រៅពីនេះ ក្រុមការងារបច្ចេកទេសមួយទៀត មានសមាជិក ២៣ រូប ដែលសម្របសម្រួលពិភាក្សាដោយឯកឧត្តម **លីម សុធា** អគ្គនាយកគោលនយោបាយ និងផែនការស្តីពីស្ថិតិនិងសូចនាករ។ ក្រុមការងារស្នូលរៀបចំផែនការមកពីនាយកដ្ឋានក្រោមអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ គឺជាអ្នកផ្តល់ការគាំទ្រដល់សកម្មភាពអនុវត្តជាក់ស្តែង។

ឯកសារនេះ គឺជាលទ្ធផលនៃកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី មូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ និងការវិភាគល្អិតល្អន់អស់រយៈពេលជាច្រើនខែ ដោយរាជរដ្ឋាភិបាល

កម្ពុជា និងដៃគូអភិវឌ្ឍ។ ឯកសារនេះត្រូវបានរៀបចំឡើង ដោយមានការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍសំខាន់ៗ និងសង្គមស៊ីវិល។

ការងារជាច្រើន ត្រូវបានធ្វើឡើងសម្រាប់ប្រមូលព័ត៌មាន ដើម្បីរៀបចំផែនទីបង្ហាញផ្លូវនេះ។ ការពិនិត្យឡើងវិញលើគោលដៅអប់រំសម្រាប់ទាំងអស់គ្នាត្រូវបានរៀបចំ ដោយក្រសួងអប់រំ យុវជន និងកីឡា ជាផ្នែកមួយនៃការពិនិត្យឡើងវិញថ្នាក់ជាតិលើគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ក្នុងឆ្នាំ ២០១៤-២០១៥ និងការវិភាគស្ថានភាពវិស័យអប់រំដែលបានធ្វើឡើងដោយវិទ្យាស្ថានអន្តរជាតិសម្រាប់ផែនការអប់រំ អង្គការយូណេស្កូក្រោមការគាំទ្រពីអង្គការយូនីសេហ្វបានផ្តល់នូវការយល់ដឹងស៊ីជម្រៅអំពីលទ្ធផលសម្រេចបានរបស់វិស័យអប់រំ។ ការពិនិត្យឡើងវិញលើគោលដៅអប់រំសម្រាប់ទាំងអស់គ្នា បានធ្វើការវាយតម្លៃពីបទពិសោធន៍ពីការអនុវត្តការអប់រំសម្រាប់ទាំងអស់គ្នា និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍អប់រំ។ ក្នុងក្របខណ្ឌវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡា និងនាយកដ្ឋានពាក់ព័ន្ធបានរៀបចំឯកសារ និងក្របខណ្ឌគោលនយោបាយជាច្រើន (ដូចជា គោលនយោបាយគ្រូបង្រៀន ក្របខណ្ឌកម្មវិធីសិក្សាថ្មី ផែនការគោលឧត្តមសិក្សា)។ ក្របខណ្ឌគោលនយោបាយទាំងនេះបានដាក់ចេញនូវចក្ខុវិស័យរយៈពេលវែង និងរយៈពេលខ្លីរបស់រដ្ឋាភិបាលសម្រាប់វិស័យអប់រំទាំងមូល ក៏ដូចជាសម្រាប់ផ្នែកនានានៃវិស័យអប់រំ។ ក្រៅពីនេះមានឯកសារគោលនយោបាយជាតិជាច្រើន (ដូចជា គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម គោលនយោបាយស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ) បានដាក់ចេញនូវចក្ខុវិស័យអភិវឌ្ឍន៍រយៈពេលវែង ដែលមានភាពពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍវិស័យអប់រំដែរ។ ឯកសារគោល-នយោបាយសំខាន់ៗទាំងនេះ ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការរៀបចំផែនទីបង្ហាញផ្លូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព-ការអប់រំ។

វិសាលភាព និងភាពស្មុគស្មាញនៃចំណុចដៅអប់រំ ឆ្នាំ២០៣០ តម្រូវឱ្យមានការកំណត់អាទិភាពតាមរយៈការពិភាក្សាជាមួយអ្នកពាក់ព័ន្ធជាច្រើន។ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ជាច្រើននៅថ្នាក់ជាតិ និងថ្នាក់រាជធានី-ខេត្ត ដើម្បីប្រមូលធាតុចូលអំពីបញ្ហាប្រឈម និងអាទិភាពនាពេលអនាគតសម្រាប់វិស័យអប់រំ។ ព្រឹត្តិការណ៍សំខាន់ៗដែលរៀបចំនៅថ្នាក់ជាតិ រួមមានសិក្ខាសាលាពិគ្រោះយោបល់អំពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ឆ្នាំ២០១៦ និងសិក្ខាសាលាមូលដ្ឋាននីយកម្មការអប់រំឆ្នាំ២០៣០ កាលពីខែកុម្ភៈ ឆ្នាំ២០១៧។ អង្គវិបស្សនាប្រចាំឆ្នាំរបស់ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ កាលពីខែមិថុនា ឆ្នាំ២០១៧ បានធ្វើការពិភាក្សាពីក្របខណ្ឌនៃផែនទីបង្ហាញផ្លូវ និងផ្តល់នូវការតម្រង់ទិសសម្រាប់កំណត់ពីអាទិភាព ចំណុចដៅ និងយុទ្ធសាស្ត្រអប់រំសម្រាប់

ប្រទេសទាំងមូល។ កិច្ចប្រជុំពិគ្រោះយោបល់ស្តីពី គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ដែលបានធ្វើឡើងកាលពីខែសីហាឆ្នាំ២០១៧ បានផ្តល់នូវធាតុចូលនិងព័ត៌មានគ្រឡប់ជាច្រើនលើសេចក្តីព្រាង។

រាជរដ្ឋាភិបាលកម្ពុជាបានបំពេញតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍរបៀបវារៈអប់រំ ឆ្នាំ២០៣០ និងជាប្រទេសនាំមុខមួយក្នុងចំណោមប្រទេសកំពុងអភិវឌ្ឍន៍នានា នៅក្នុងការពិភាក្សាទាំងថ្នាក់តំបន់ និងអន្តរជាតិ រហូតដល់របៀបវារៈនេះត្រូវបានអនុម័ត និងការពិភាក្សាបន្តបន្ទាប់នៅក្នុងកិច្ចប្រជុំថ្នាក់តំបន់អាស៊ីប៉ាស៊ីហ្វិចស្តីពីការអប់រំ ដែលបានរៀបចំធ្វើឡើង នៅទីក្រុងបាងកក។

កម្ពុជាមានបទពិសោធយ៉ាងច្រើនលើការសម្រេចសកលកម្មនៃការអប់រំបឋមសិក្សា តាមរយៈការខិតខំប្រឹងប្រែងអនុវត្តការអប់រំសម្រាប់ទាំងអស់គ្នា និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលនាំឱ្យកម្ពុជាស្ថិតក្នុងស្ថានភាពមួយដ៏ល្អក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។ កន្លងមកច្រើនឆ្នាំកម្ពុជាបានពង្រឹងសមត្ថភាពក្នុងការដឹកនាំរៀបចំរបៀបវារៈអប់រំ គៀរគរធនធាន សម្របសម្រួលដៃគូអភិវឌ្ឍ និងគ្រប់គ្រងគំនិតផ្តួចផ្តើមកំណែទម្រង់នានា។ សមិទ្ធផលនេះ ធ្វើឱ្យកម្ពុជាស្ថិតក្នុងស្ថានភាពល្អប្រសើរ ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤-ការអប់រំឆ្នាំ២០៣០ បើធៀបនឹង ១៥ ឆ្នាំ មុន នៃការអនុវត្តគោលដៅអប់រំសម្រាប់ទាំងអស់គ្នា។

### ១.៣ រចនាសម្ព័ន្ធនៃផែនទីបង្ហាញផ្លូវ

បន្ទាប់ពីការបង្ហាញដោយសង្ខេបពីផែនទីបង្ហាញផ្លូវ ក្នុងជំពូកទី១ ជំពូកទី២ សង្ខេបពីបរិបទនៃការអភិវឌ្ឍ និងបរិបទសង្គម-សេដ្ឋកិច្ច និងនយោបាយសំខាន់ៗ ដែលពាក់ព័ន្ធនឹងប្រព័ន្ធអប់រំ។ ជំពូកនេះបង្ហាញពីនិន្នាការខ្លះៗនៃប្រព័ន្ធអប់រំ រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ជំពូកទី៣ បង្ហាញលម្អិតពីបរិបទនៃការអភិវឌ្ឍវិស័យអប់រំកម្ពុជា រួមទាំងសមិទ្ធផលសម្រេចបាន និងបញ្ហាប្រឈម។ ជំពូកទី៤ ជាខ្លឹមសារសំខាន់នៃផែនទីបង្ហាញផ្លូវ បង្ហាញពីចក្ខុវិស័យ អាទិភាពគោលនយោបាយ ចំណុចដៅ និងយុទ្ធសាស្ត្រវិស័យអប់រំ។ ជំពូកទី៥ បង្ហាញទូទៅពីតម្រូវការធនធានហិរញ្ញវត្ថុសម្រាប់រយៈពេលនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។ ចុងក្រោយ គឺជំពូកទី៦ បង្ហាញពីរបៀបពិនិត្យតាមដានការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ និងការវាយតម្លៃផលប៉ះពាល់នៃកម្មវិធី។ ជំពូកនេះក៏នឹងបង្ហាញពីក្របខណ្ឌលទ្ធផលផងដែរ។

## ២. បរិបទនៃការអភិវឌ្ឍនៅប្រទេសកម្ពុជា

### ២.១ ស្ថានភាពប្រជាសាស្ត្រ និងសង្គម

ប្រទេសកម្ពុជាមានប្រជាជន ១១,៥ លាន នាក់ នៅឆ្នាំ១៩៩៨ កើនឡើងដល់ ១៣,៤ លាន នាក់ នៅឆ្នាំ២០០៨ និង១៤,៧លាននាក់នៅឆ្នាំ២០១៣ ហើយត្រូវបានប៉ាន់ប្រមាណ ១៥,៦ លាននាក់នៅឆ្នាំ២០១៦។ ផ្អែកតាមនិន្នាការនេះ ការព្យាករណ៍ប្រជាជនកម្ពុជានឹងកើនឡើងដល់ ១៨ លាននាក់ នៅឆ្នាំ២០២៨។ អត្រាកំណើនប្រជាជនប្រចាំឆ្នាំបានថយចុះពី ២,១២ ភាគរយ មក ១,៥៤ ភាគរយ កំឡុងឆ្នាំ១៩៩៨-២០០៨ និងពី ១,៥៤ ភាគរយ នៅឆ្នាំ ២០០៨ មក ១,៤៤ ភាគរយ នៅឆ្នាំ២០១៦។ ផលធៀបភេទបានកើនឡើងតិចតួចពី ៩៤០នាក់ ទៅ ៩៤៣នាក់ នៃចំនួនបុរសក្នុងចំនួនស្រី ១០០០នាក់ នៅដំណាក់កាលឆ្នាំ២០០៨-២០១៣។ ដង់ស៊ីតេប្រជាជនដែលមានចំនួន ៧៥ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ នៅឆ្នាំ២០០៨ បានកើនឡើងដល់ ៨២ នាក់ នៅឆ្នាំ២០១៣ និង ៨៦,៨ នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ នៅឆ្នាំ២០១៦។ ដូចគ្នានេះដែរ ផលធៀបប្រជាជនក្នុងបន្ទុកមានការប្រែប្រួលគួរឱ្យកត់សម្គាល់កំឡុងពេលចន្លោះជំរឿនឆ្នាំ១៩៩៨-២០០៨ និងក្នុងឆ្នាំ២០១៣។ ផលធៀបប្រជាជនក្នុងបន្ទុកសរុបដែលស្មើនឹង ៨៦ នាក់ ក្នុងចំណោមប្រជាជនស្ថិតក្នុងវ័យធ្វើការ ចំនួន ១០០ នាក់ នៅឆ្នាំ១៩៩៨ បានធ្លាក់ចុះមក ៦១ នាក់ នៅក្នុងឆ្នាំ២០០៨ ហើយបន្តធ្លាក់ចុះដល់ចំនួន ៥២ នាក់ នៅក្នុងឆ្នាំ២០១៣ និង៥១,២ នាក់ នៅឆ្នាំ២០១៦ ដោយផលធៀបប្រជាជនក្នុងបន្ទុកចំណោមបុរសមានចំនួនច្រើនជាងផលធៀបប្រជាជនក្នុងបន្ទុកក្នុងចំណោមស្ត្រី។ ការថយចុះដ៏គួរឱ្យកត់សម្គាល់ គឺបានកើតឡើងចំពោះផលធៀបប្រជាជនក្នុងបន្ទុកវ័យក្មេង ដោយបានថយចុះពី ៨០ នាក់ មក ៥៤ នាក់ ក្នុងចំណោម ប្រជាជនស្ថិតក្នុងវ័យធ្វើការចំនួន ១០០ នាក់នៅចន្លោះឆ្នាំ១៩៩៨-២០០៨ ហើយមកត្រឹម ៤៥ នាក់ នៅក្នុងឆ្នាំ២០១៣ ដោយសារការធ្លាក់ចុះយ៉ាងលឿននៃអត្រាលទ្ធភាពមានកូនសរុបពីប្រមាណ ៤,០នាក់ ក្នុងស្ត្រី១នាក់ នៅឆ្នាំ១៩៩៨ មក ២,៨ នាក់ នៅឆ្នាំ២០១៣ និង ២,៦ នាក់ ក្នុងស្ត្រីម្នាក់ នៅឆ្នាំ២០១៦។ ជំរឿនទូទៅប្រជារាស្ត្រឆ្នាំ២០០៨ បង្ហាញថា មនុស្សចាស់ដែលសំដៅលើមនុស្សដែលមានអាយុចាប់ពី ៦៥ ឆ្នាំឡើងទៅ មានប្រមាណជា ៥ ភាគរយ នៃចំនួនប្រជាជនសរុប នៅឆ្នាំ២០០៨ បានកើនឡើង ៥,១ ភាគរយ ឆ្នាំ២០១៦ ហើយរំពឹងថា អត្រានេះនឹងកើនឡើងរហូតដល់ប្រមាណជា ៦,៩ ភាគរយ ត្រឹមឆ្នាំ២០២៨។ តារាងទី១ បង្ហាញពីសូចនាករប្រជាសាស្ត្រគោលមួយចំនួន សម្រាប់ឆ្នាំ ១៩៩៨ និង ២០១៦។

## តារាងទី ១៖ សូចនាករប្រជាសាស្ត្រ

| សូចនាករ | ១៩៩៨ | ២០១៦ |
|---|---|---|
| ចំនួនប្រជាជនសរុប (គិតជាពាន់នាក់) | ១១ ៤៣៨ | ១៥ ៤០៥ |
| អត្រាកំណើនប្រចាំឆ្នាំ (%) | ២,៤៩ | ១,៤៤ |
| អត្រាផ្តល់កំណើត (កំណើត ក្នុងស្ត្រីម្នាក់) | ៥,៣ | ២,៦ |
| បុរសធៀបនឹងស្ត្រី (ស្រី ១០០ នាក់) | ៩៣,០ | ៩៤,៩ |
| ប្រជាជនអាយុក្រោម ១៥ ឆ្នាំ (% នៃប្រជាជនសរុប) | ៤២,៨ | ២៨,៧ |
| ដង់ស៊ីតេប្រជាជន (នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ) | ៦៤,០ | ៨៦,៨ |
| អត្រាប្រជាជនរស់នៅទីប្រជុំជន (% នៃប្រជាជនសរុប) | ១៥,៧ | ២១,៤ |

*ប្រភព ៖ របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨*

លក្ខណៈប្រជាសាស្ត្រនៃប្រទេសកម្ពុជា គឺមានប្រជាជនវ័យក្មេងច្រើននៅឡើយ។ នៅឆ្នាំ១៩៩៨ ប្រជាជនអាយុក្រោម ១៥ឆ្នាំ មាន ៤២,៨ ភាគរយ បានថយចុះគួរឱ្យកត់សម្គាល់មក ២៨,៧ ភាគរយឆ្នាំ ២០១៦ ហើយនឹងថយចុះមក២៥,៩ភាគរយ នៅឆ្នាំ២០២៨។ ប្រជាជនក្នុងវ័យធ្វើការ (អាយុ១៥-៦៤ឆ្នាំ) បានកើនឡើងពី ៥៣,៧ ភាគរយ ទៅ ៦២ ភាគរយ កំឡុងពេល ១៩៩៨-២០០៨ ហើយអាចកើនដល់ ៦៧,៣ ភាគរយ នៅឆ្នាំ២០២៨។ ការផ្លាស់ប្តូររចនាសម្ព័ន្ធអាយុពីវ័យក្មេងទៅវ័យធ្វើការ និងអត្រាកំណើននៃក្រុមមនុស្សក្នុងវ័យធ្វើការដែលនៅបន្តមានកម្រិតខ្ពស់ជាងអត្រាកំណើនប្រជាជនសរុប និងប្រជាជនក្នុងបន្ទុក បានផ្តល់ជាកាលានុវត្តភាពប្រជាសាស្ត្រមួយសម្រាប់កម្ពុជា។ បម្រែបម្រួលលក្ខណៈប្រជាសាស្ត្រយ៉ាងឆាប់រហ័សបានបើកចំហនូវឱកាសប្រជាសាស្ត្រដ៏ធំមួយ ពោលគឺមានយុវជនដល់វ័យធ្វើការជាច្រើននាក់ ដែលកំពុងត្រៀម ឬ កំពុងចូលប្រឡូកក្នុងទីផ្សារការងាររួចទៅហើយ។ ប្រជាជនវ័យក្មេងទាំងនេះអាចផ្តល់នូវ "ភាគលាភប្រជាសាស្ត្រ" ដ៏មានសក្តានុពល ដែលជំរុញឱ្យប្រទេសកម្ពុជាទទួលបានប្រយោជន៍សេដ្ឋកិច្ច ប្រសិនបើមានការវិនិយោគគ្រប់គ្រាន់លើការងារយុវជន ការអប់រំ និងការទទួលបានសេវាសុខភាព ដូចជា សុខភាពផ្លូវភេទ និងបន្តពូជជាដើម។ អត្រាបង្កើតកូនសរុប មានកម្រិតទាបដែលនឹងធ្វើឱ្យអត្រាប្រជាជនក្នុងបន្ទុកបន្តថយចុះ ក្នុងរយៈពេល ៣ ទសវត្សរ៍ទៀត និងរួមចំណែកដល់កំណើនផលិតផលសរុបក្នុងស្រុក (ផ.ស.ស.)។

ប្រជាជនកម្ពុជា ភាគច្រើនជាប្រជាជនជនបទ ដែលប្រមាណ ៨០ ភាគរយ រស់នៅតំបន់ជនបទ និង ២០ ភាគរយ រស់នៅតំបន់ប្រជុំជន។ របាយការណ៍នេះទំនងជានឹងមានការផ្លាស់ប្តូរក្នុងរយៈពេលខ្លី ដោយសារតែការធ្វើចំណាកស្រុកចេញពីតំបន់ជនបទមានអត្រាខ្ពស់។ ជំរឿនទូទៅនូវប្រជាពលរដ្ឋឆ្នាំ

២០០៨ បានបង្ហាញថា ប្រជាជនជិត ៣,៦ លាននាក់ នៅទូទាំងប្រទេស គឺជាអ្នកធ្វើទេសន្តរប្រវេសន៍។ ចលនាបែបនេះ កំពុងធ្វើឱ្យមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃរចនាសម្ព័ន្ធរបស់សង្គមជនបទ ដោយសារតែចាស់ជរាត្រូវក្លាយជាអ្នកថែទាំកុមារ ដែលឪពុកម្តាយពួកគេបានធ្វើចំណាកស្រុក។ បញ្ហានេះ ចាំបាច់ត្រូវមានការកែតម្រូវគោលនយោបាយ កម្មវិធី និងអន្តរាគមន៍នានា ដើម្បីឆ្លើយតបចំពោះបញ្ហាដែលពាក់ព័ន្ធនឹងការអប់រំ សុខភាព និងសុខុមាលភាពជារួមរបស់កុមារ។ នៅពេលចំនួនប្រជាជននៅទីក្រុងមានការកើនឡើងបែបនេះ គួរបង្កើនការវិនិយោគលើសេវាសង្គម រួមទាំងសេវាអប់រំផង។

## ២.២ សេដ្ឋកិច្ច

ផ្អែកលើការផ្សះផ្សារជាតិក្នុងចំណោមភាគីជម្លោះ កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ ហើយបន្ទាប់មក ការបោះឆ្នោតសកលលើកទី១ត្រូវបានរៀបចំនៅក្នុងឆ្នាំ១៩៩៣។ តាមរយៈ ***គោលនយោបាយឈ្នះ-ឈ្នះ*** កម្ពុជាទទួលបានសន្តិភាពពេញលេញនៅក្នុងឆ្នាំ១៩៩៨។ កម្ពុជាចាប់ផ្តើមបើកចំហទីផ្សារ និងសមាហរណកម្មសេដ្ឋកិច្ចរបស់ខ្លួនជាមួយនឹងអាស៊ាន និងសេដ្ឋកិច្ចសកលលោក។ បរិយាកាសអំណោយផលនៃសុខសន្តិភាពសង្គម និងរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបានធ្វើប្រទេសកម្ពុជានៅតែរក្សាបាននូវកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់សម្រាប់រយៈពេលពីរទសវត្សរ៍ចុងក្រោយ ជាមួយនឹងអត្រាកំណើនមធ្យមប្រចាំឆ្នាំ ៧,៧ ភាគរយ និងកាត់បន្ថយភាពក្រីក្រមកត្រឹម ១៣,៥ ភាគរយ នៅឆ្នាំ២០១៤។ សមិទ្ធផលនេះធ្វើឱ្យកម្ពុជាក្លាយជាប្រទេសដែលមានសេដ្ឋកិច្ចរីកលូតលាស់យ៉ាងឆាប់រហ័ស ដែលត្រូវបានប្រសិទ្ធនាមថាជាខ្លាថ្មីប្រចាំតំបន់អាស៊ី ដោយសារការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាប់គ្នាសម្រាប់រយៈពេលប៉ុន្មានឆ្នាំចុងក្រោយ។

ចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ត្រូវបានប៉ាន់ស្មានថា នឹងកើនឡើងដល់រង្វង់ ១ ៣០០ ដុល្លារអាមេរិកក្នុងឆ្នាំ២០១៦ បន្ទាប់ពីមានកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពរយៈពេលជាងពីរទសវត្សរ៍កន្លងមក ហើយបានធ្វើឱ្យកម្ពុជាវិវឌ្ឍខ្លួនទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបនាឆ្នាំ២០១៥។ ផលិតផលសរុបក្នុងស្រុកកម្ពុជាបានកើនឡើងគួរកត់សម្គាល់ពី ១៥ ២២៩ ពាន់លានដុល្លារអាមេរិក ឆ្នាំ២០១៣ ដល់ ១៩,៨៦ ពាន់លានដុល្លារអាមេរិក ឆ្នាំ២០១៦។ (ផ.ស.ស.)សម្រាប់ប្រជាជនម្នាក់ កើនឡើងពី ៧៣១ លានដុល្លារ ឆ្នាំ២០០៩ ដល់ ១ ៣០២ ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៦។ អត្រាភាពក្រីក្របានថយចុះពី ៤៧,៨ ភាគរយ ឆ្នាំ២០០៧ មក ១៣,៥ ភាគរយ ឆ្នាំ២០១៤។ និន្នាការនេះធ្វើឱ្យកម្ពុជាមានសុទិដ្ឋិនិយមថានឹងអាចសម្រេចបាននូវគោលដៅរយៈពេលវែងរបស់ខ្លួន ក្នុងការប្រែក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ឆ្នាំ២០៥០។

កំណើនសេដ្ឋកិច្ច ត្រូវបានជំរុញដោយការវិនិយោគរបស់វិស័យឯកជន ក្នុងវិស័យកសិកម្ម ការផលិតសម្លៀកបំពាក់ សំណង់ និងទេសចរណ៍ ក៏ដូចជាការវិនិយោគរបស់វិស័យសាធារណៈលើផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ និងទីក្រុង។ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបានជួយសម្រួលឱ្យមានការសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ កម្ពុជាបានប្រើប្រាស់ដីធ្លី និងធនធានទឹករបស់ខ្លួន យ៉ាងមានប្រសិទ្ធភាពដើម្បីបង្កើនផលិតកម្មកសិកម្ម។ កម្ពុជាផ្តល់នូវទីតាំងផលិតកម្មទាក់ទាញ ដោយសារចំណាយថ្លៃដើមទាបសម្រាប់រោងចក្រកាត់ដេរ ហើយក៏ជាទិសដៅទេសចរណ៍ដ៏ពេញនិយមមួយនៅអាស៊ីអាគ្នេយ៍ផងដែរ។

ប្រទេសកម្ពុជាបន្តទទួលបាន "ភាគលាភប្រជាសាស្ត្រ" និងការបង្កើតការងារសម្រាប់យុវជន និងស្ត្រី ក្នុងឧស្សាហកម្មដែលត្រូវការកម្លាំងពលកម្មច្រើន ដែលបានជួយជំរុញកំណើនសេដ្ឋកិច្ច និងប្រាក់ចំណូលសម្រាប់ប្រជាជនម្នាក់។ ប្រជាជនអាយុ ១៥-៦៤ឆ្នាំ មានប្រមាណជា ៨៣ ភាគរយ ចូលរួមក្នុងទីផ្សារពលកម្មនៅឆ្នាំ២០១៥ ក្នុងនោះស្ត្រី ប្រមាណ ៧៧ ភាគរយ និង បុរស ប្រមាណ ៨៩ ភាគរយ។ អត្រាអ្នកគ្មានការងារធ្វើមានកម្រិតទាប ប៉ុន្តែការងារមិនរៀបរយមានកម្រិតខ្ពស់ ទោះបីជាមាននិន្នាការលើការចងក្រងការងារឱ្យរៀបរយក៏ដោយ។

## ២.៣ អាទិភាព និងបញ្ហាប្រឈមសំខាន់ៗជុំវិញការអភិវឌ្ឍ

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តយុទ្ធសាស្ត្រចតុកោណ តាំងពីឆ្នាំ២០០៤មក ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ជាក្របខណ្ឌគោលមួយសម្រាប់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ ចាត់ទុកកំណើនបរិយាបន្នថា ជាអាទិភាពរួមមួយនៃការអភិវឌ្ឍសម្រាប់ ២០១៤-២០១៨។ យុទ្ធសាស្ត្រនេះទទួលស្គាល់ថា កំណើនបរិយាបន្នអាចសម្រេចទៅបាន នៅពេលដែលប្រជាពលរដ្ឋទាំងអស់មានលទ្ធភាពស្មើគ្នា ក្នុងការទទួលបានឱកាសអភិវឌ្ឍន៍ដូចជា កិច្ចគាំពារសង្គម និងឱកាសទទួលបានការងារប្រកបដោយអត្ថប្រយោជន៍។ អ្វីដែលសំខាន់គឺ អភិបាលកិច្ចល្អជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរួមនឹងកំណែទម្រង់សេវាសង្គម កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់ហិរញ្ញវត្ថុ និងរដ្ឋបាលសាធារណៈ និងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ។ នៅក្នុងស្នូលនៃអភិបាលកិច្ចល្អ យុទ្ធសាស្ត្របានដាក់ចេញសម្រាប់អាទិភាពទាំង៤ ដើម្បីដោះស្រាយបញ្ហាប្រឈមការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងធនធានមនុស្សដូចជា ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការលើកកម្ពស់វិស័យកសិកម្ម និងការអភិវឌ្ឍវិស័យឯកជន និងការងារ។ កំណើនសេដ្ឋកិច្ច ការបង្កើតការងារ ការបែងចែកប្រកបដោយសមធម៌ និងការគ្រប់គ្រងស្ថាប័នសាធារណៈ និងធនធានប្រកបដោយប្រសិទ្ធភាព ត្រូវបានចាត់ទុកថា

មធ្យោបាយសម្រាប់បន្តអនុវត្ត និងពង្រឹងការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព។ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បន្តផ្តោតអាទិភាពលើការពង្រឹងយន្តការអនុវត្ត។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ គឺជាមធ្យោបាយដ៏សំខាន់ សម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ។

គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម រយៈពេល ១០ឆ្នាំ ២០១៥-២០៥ បានដាក់ចេញផែនទីបង្ហាញផ្លូវសម្រាប់លើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព”។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាល គឺជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា ពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥។ គោលនយោបាយទទួលស្គាល់ពីភាពចាំបាច់ក្នុងការកសាងជំនាញកម្មករ អ្នកបច្ចេកទេស វិស្វករ និងអ្នកវិទ្យាសាស្ត្រ ដើម្បីឈានទៅសម្រេចរបៀបវារៈនៃការអភិវឌ្ឍវិស័យកម្មន្តសាល។ ឯកសារគោល-នយោបាយជាច្រើន រួមទាំងការវិភាគដែលរៀបចំដោយដៃគូអភិវឌ្ឍន៍របស់ប្រទេសកម្ពុជាផង បានចាត់ទុកបញ្ហាខាងក្រោមថាជាបញ្ហាប្រឈមសំខាន់ៗនៃការអភិវឌ្ឍ។

### *២.៣.១ ការកសាងធនធានមនុស្ស*

ទោះបី កម្ពុជាមានភាពល្អប្រសើរខាងប្រជាសាស្ត្រក៏ដោយ កម្លាំងពលកម្មភាគច្រើននៅមានកម្រិតអប់រំទាប និងកម្រិតជំនាញទាបនៅឡើយ។ ជាលទ្ធផល កម្ពុជាមានការប្រឈមនឹងអន្តរកាលសេដ្ឋកិច្ច ខណៈពេលដែលមានបំណងចាកចេញពីសកម្មភាពដែលត្រូវការជំនាញកម្រិតទាប និងមានតម្លៃទាប និងពង្រីកមូលដ្ឋានឧស្សាហកម្មរបស់ខ្លួន ដើម្បីបង្កើតកំណើនបរិយាបន្នដែលឈរលើមូលដ្ឋានទូលំទូលាយ។ ការសិក្សាជាច្រើនបានបង្ហាញពី កង្វះជំនាញ និងកង្វះទីផ្សារការងារ ពិសេស ជំនាញកម្រិតទាបទៅកម្រិតមធ្យម។ កង្វះកម្លាំងពលកម្មដែលបានទទួលការអប់រំ និងមានជំនាញនឹងធ្វើឱ្យកម្ពុជាមានការលំបាក ក្នុងការប្រកួតប្រជែងជាមួយប្រទេសជិតខាង ដើម្បីដណ្តើមការវិនិយោគផ្ទាល់ពីបរទេស។ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មទទួលស្គាល់យ៉ាងច្បាស់ពីភាពចាំបាច់ ដើម្បីអភិវឌ្ឍធនធានមនុស្សឱ្យបានសមស្រប។ ជាអាទិភាព កម្ពុជាគួរអភិវឌ្ឍចំណេះធ្វើ និងធនធានបច្ចេកទេសដែលចាំបាច់សម្រាប់ធ្វើពិពិធកម្មផលិតកម្មរបស់ខ្លួនទៅរកសកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់ និងបង្កើនជំនាញ។ អាហារូបត្ថម្ភ ការអប់រំកុមារតូច និងគុណភាពអប់រំបឋមសិក្សា និងអប់រំមូលដ្ឋានការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការអប់រំកម្រិតឧត្តមសិក្សា គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍជំនាញ។

### ២.៣.២ កំណើនសេដ្ឋកិច្ចបរិយាបន្ន

ទោះបី សម្រេចបាននូវវឌ្ឍនភាពសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ ការទទួលផលប្រយោជន៍ក៏មិនមានភាពស្មើគ្នាទៅតាមតំបន់នៃប្រទេស។ កម្រិតភាពក្រីក្រនៅតែបន្តមានច្រើនតំបន់ជនបទ បើធៀបនឹងតំបន់ទីប្រជុំជន។ ប្រជាជនភាគច្រើននៃអ្នកបានចាកចេញពីភាពក្រីក្រនៅតែងាយរងគ្រោះដោយសារវិបត្តិសេដ្ឋកិច្ចនិងការប្រែប្រួលដូចជាជំងឺនិងគ្រោះមហន្តរាយធម្មជាតិ។ ការឆ្លើយតបចំពោះបញ្ហានៃភាពក្រីក្រនិងវិសមភាព គឺស្ថិតក្នុងចំណោមអាទិភាពស្នូលរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីសម្រេចកំណើនបរិយាបន្ន កម្ពុជាចាំបាច់ត្រូវការគាំពារសង្គមបន្ថែមទៀតដើម្បីឱ្យការកាត់បន្ថយភាពក្រីក្រនៅលើគោលជំហរកាន់តែមាននិរន្តរភាព និងបរិយាបន្ន ដែលអាចធ្វើឱ្យគ្រួសារដែលងាយរងគ្រោះមានភាពរឹងមាំក្នុងការទប់ទល់នឹងផលប៉ះពាល់នៃវិបត្តិផ្សេងៗ។ កំណើនបរិយាបន្នទាមទារឱ្យមានការវិនិយោគពីវិស័យសាធារណៈ និងឯកជនឱ្យចំគោលដៅ និងមានប្រសិទ្ធភាពជាងមុន ដើម្បីបង្កើនផលិតភាព និងប្រាក់ចំណូល ក៏ដូចជាបង្កើតឱកាសការងារសម្រាប់ប្រជាពលរដ្ឋទាំងប្រុស ទាំងស្រីនៅតំបន់ជនបទ និងតំបន់ប្រជុំជន។

### ២.៣.៣ ការអភិវឌ្ឍសង្គម និងកិច្ចគាំពារសង្គម

ប្រព័ន្ធគាំពារសង្គមរបស់កម្ពុជានៅមានលក្ខណៈបែកខ្ញែកពីគ្នា និងវិសាលភាពនៅមានកម្រិតដោយសារតែការវិនិយោគមិនគ្រប់គ្រាន់ ការសម្របសម្រួលរវាងតួអង្គសំខាន់ៗនៅមានកម្រិតខ្សោយ ខ្វះការកំណត់អាទិភាព និងការកំណត់រកក្រុមគោលដៅនៅមានកម្រិតខ្សោយនៅឡើយ។ គ្រួសារក្រីក្រនិងងាយរងគ្រោះមួយចំនួន ពុំទាន់បានទទួលការធានារ៉ាប់រងគ្រប់គ្រាន់។ ក្រោយពីវិសាលភាពនៃការធានារ៉ាប់រង ការប្រើប្រាស់សេវានេះនៅជាការលំបាក និងចាំបាច់ត្រូវមានអន្តរាគមន៍ចម្បងៗ ដើម្បីឱ្យប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះអាចប្រើប្រាស់សេវាសុខភាពបាន តាមរយៈការផ្តល់ព័ត៌មានសុខភាពចំគោលដៅ និងការអប់រំសុខភាពប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនោះដែរ ចាំបាច់ត្រូវមានការឆ្លើយតបចំពោះតម្រូវការផ្នែកគាំពារសង្គមរបស់ស្ត្រីឱ្យបានកាន់តែប្រសើរ តាមរយៈការកំណត់ក្រុមគោលដៅឱ្យបានកាន់តែល្អជាងមុន។ ក្នុងវិស័យអប់រំ ភាពចាំបាច់ជាបន្ទាន់ គឺការបង្កើនលទ្ធភាពទទួលបានការគាំពារ និងអភិវឌ្ឍន៍កុមារតូច ក៏ដូចជាការអប់រំនៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ និងបង្កើនគុណភាព និងភាពឆ្លើយតបនៃការអប់រំនៅគ្រប់កម្រិតទាំងអស់។ ការប្រឹងប្រែងខ្លាំងបន្ថែមទៀត គឺបង្កើនការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមករវាងគំនិតផ្តួចផ្តើមគោលនយោបាយនានា ដើម្បីធានាឱ្យការផ្តល់សេវាសុខភាព អាហារូបត្ថម្ភ ការអភិវឌ្ឍកុមារតូច ការអប់រំ កិច្ចគាំពារសង្គម និងការបញ្ជ្រាបយេនឌ័រ ប្រកបដោយគុណភាពកាន់តែល្អប្រសើរឡើង។

### ២.៣.៤ ការអភិវឌ្ឍប្រកបដោយចីរភាព

ការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស ក៏មានផលប៉ះពាល់ដល់បរិស្ថាន និងធនធានធម្មជាតិរបស់ប្រទេសផងដែរ។ ការពង្រីកផ្ទៃដីដាំដុះ សកម្មភាពជីសម្បទានសេដ្ឋកិច្ច ការកាប់ឈើខុសច្បាប់ ការរត់ពន្ធឈើ នឹងបណ្តាលឱ្យប៉ះពាល់ដល់បរិស្ថាន។ គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ដូចជា ការសាងសង់ទំនប់វារីអគ្គិសនី ប្រព័ន្ធធារាសាស្ត្រ ការបង្កើតតំបន់ឧស្សាហកម្ម និងសកម្មភាពអភិវឌ្ឍន៍អចលនទ្រព្យនៅតំបន់ទីក្រុង និងជាយក្រុង កំពុងដាក់សម្ពាធមកលើធនធានទឹក និងបង្កផលប៉ះពាល់ដល់គុណភាព និងបរិមាណទឹក។ សសរស្តម្ភសំខាន់ៗនៃសេដ្ឋកិច្ចកម្ពុជាដូចជា កសិកម្ម នេសាទ ព្រៃឈើ និងទេសចរណ៍ សុទ្ធតែជាវិស័យដែលងាយរងផលប៉ះពាល់ដោយសារអាកាសធាតុ។ ប្រជាជនក្រីក្រ និងងាយរងគ្រោះដែលរស់នៅតំបន់ជនបទ និងតំបន់ប្រជុំជន ក្នុងនោះមួយភាគធំជាស្ត្រីនិងកុមារ ជារឿយៗ តែងប្រឈមនឹងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ។ រាជរដ្ឋាភិបាលទទួលស្គាល់ថា ចាំបាច់ត្រូវមានការថ្លឹងថ្លែងឱ្យបានសមស្របរវាងការអភិវឌ្ឍសេដ្ឋកិច្ច និងធនធានរបស់ប្រទេស។ កម្ពុជាបានបោះជំហានជាច្រើន ដើម្បីធានាឱ្យមានការអភិវឌ្ឍប្រកបដោយចីរភាពតាមរយៈការអនុម័តលើក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើន។ ប្រការនេះ ចាំបាច់ត្រូវខិតខំប្រឹងប្រែងជាលក្ខណៈយុទ្ធសាស្ត្របន្ថែមទៀតដើម្បីពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិដែលចូលជាធរមានរួចហើយ រួមនឹងការកសាងសមត្ថភាពបច្ចេកទេស និងការផ្តល់ធនធានហិរញ្ញវត្ថុ និងធនធានមនុស្សផងដែរ។ ទន្ទឹមនេះដែរ ចាំបាច់ត្រូវអនុវត្តវិធានការគាំពារសង្គម ឱ្យស្របតាមស្ថានភាពជាក់ស្តែង ដើម្បីបង្កើនភាពធន់ទ្រាំនៃសហគមន៍ដែលរស់នៅតំបន់ជនបទ និងតំបន់ប្រជុំជន ទប់ទល់នឹងផលប៉ះពាល់ជាអវិជ្ជមាន ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។ កម្ពុជាបានរៀបចំផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយស្តីពី ការប្រែប្រួលអាកាសធាតុក្នុងគោលបំណងធ្វើការបញ្ជ្រាបការឆ្លើយតបចំពោះការប្រែប្រួលអាកាសធាតុ នៅតាមស្ថាប័ននានារបស់រាជរដ្ឋាភិបាល។

### ២.៣.៥ កំណែទម្រង់អភិបាលកិច្ច

អភិបាលកិច្ចល្អ គឺជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និង ទី៤ របស់រាជរដ្ឋាភិបាល។ អភិបាលកិច្ចល្អផ្តោតលើកំណែទម្រង់ចំនួនបួន គឺកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់រដ្ឋបាលសាធារណៈ រួមនឹងវិមជ្ឈការនិងវិសហមជ្ឈការ កំណែទម្រង់ប្រឆាំងអំពើពុករលួយ និងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។ វិស័យរដ្ឋបាលសាធារណៈត្រូវការកំណែទម្រង់ជាទ្រង់ទ្រាយធំ ដើម្បីបង្កើតប្រព័ន្ធរដ្ឋបាលផ្អែកតាមលទ្ធផលការងារ ដើម្បីឱ្យមន្ត្រីសាធារណៈកាន់តែមានគណនេយ្យភាព និងឆ្លើយតបចំពោះតម្រូវការ និងការរំពឹងទុករបស់សាធារណជនទូទៅ។ រាជរដ្ឋាភិបាលបានអនុវត្ត

វិធានការជាជំហានៗ ដើម្បីផ្តល់បៀវត្សឱ្យបានសមស្របដល់មន្ត្រីរាជការ ក្នុងគោលបំណងលើកទឹកចិត្តឱ្យពួកគេបំពេញការងារកាន់តែប្រសើរជាងមុន និងកាត់បន្ថយលទ្ធភាពប្រព្រឹត្តអំពើពុករលួយ។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានបង្កើតឱកាសឱ្យប្រជាពលរដ្ឋទៅរកក្រុមប្រឹក្សាតាមមូលដ្ឋាន ដើម្បីដោះស្រាយបញ្ហាដែលកើតមានក្នុងសហគមន៍របស់ពួកគេ។ ការចូលរួមពីប្រជាពលរដ្ឋនៅកម្រិតមូលដ្ឋានបែបនេះ គួររក្សាឱ្យនៅបន្តមានទៅមុខទៀត។ ចាំបាច់ត្រូវមានការបន្តសម្រេចវឌ្ឍនភាព ក្នុងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដូចជា ការបង្កើនចំណូលពន្ធ និងការបង្កើនប្រសិទ្ធភាព និងតម្លាភាពចំណាយ ដើម្បីអាចកៀរគរធនធានសម្រាប់ផ្តល់សេវាសង្គមដែលមានគុណភាពល្អប្រកបដោយនិរន្តរភាព ជាពិសេសសម្រាប់ប្រជាជនក្រីក្រ ងាយរងគ្រោះ និងបាត់បង់ឱកាស។

### ២.៣.៦ សមភាពយេនឌ័រ និងការចូលរួមរបស់ស្ត្រី

រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានសមិទ្ធផលធំៗជាច្រើនល្អសម្រាប់គោលដៅទី៣ លើកកម្ពស់សមភាពយេនឌ័រនិងការផ្តល់ភាពអង់អាចដល់ស្ត្រីរបស់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលមានចំណុចដៅចំនួន៤ គឺ(១)កាត់បន្ថយឱ្យបានច្រើននូវគម្លាតយេនឌ័រក្នុងការអប់រំកម្រិតមធ្យមសិក្សា និងឧត្តមសិក្សា (២)លុបបំបាត់គម្លាតយេនឌ័រក្នុងការងារទទួលប្រាក់កម្រៃក្នុងគ្រប់វិស័យ (៣)លុបបំបាត់គម្លាតយេនឌ័រនៅក្នុងស្ថាប័នសាធារណៈ និង(៤)កាត់បន្ថយឱ្យបានច្រើនរាល់ទម្រង់អំពើហិង្សាប្រឆាំងនឹងស្ត្រីនិងកុមារ។ តំណាងស្ត្រីនៅក្នុងស្ថាប័នរដ្ឋសភាបានកើនឡើង នៅក្នុង៥អាណត្តិចុងក្រោយ និងបានកើនដល់ ២០,៣៣ ភាគរយ ក្នុងឆ្នាំ២០១៣។ ចំណែកឯសមាជិកព្រឹទ្ធសភាជាស្ត្រី បានកើនដល់ ១៦,៤ ភាគរយ ឆ្នាំ២០១៥។ ចំនួនស្ត្រីក្នុងមុខតំណែងជាឧបនាយករដ្ឋមន្ត្រី ១រូប (១០ ភាគរយ) រដ្ឋមន្ត្រី ៣រូប (១០,៧ ភាគរយ) រដ្ឋលេខាធិការ ៣៨រូប (២០,៥៤ ភាគរយ) និងអនុរដ្ឋលេខាធិការ ៤៨រូប (១៧,៦ ភាគរយ)។ សមាមាត្រស្ត្រី ជាមន្ត្រីរាជការកើនឡើងពី ៣៨ ភាគរយ ក្នុង២០១៤ ដល់ ៤០ ភាគរយ ក្នុងឆ្នាំ២០១៦។ បទដ្ឋានសង្គមលើទំនាក់ទំនងយេនឌ័រនៅតែជាបញ្ហាចម្បង ដែលរារាំងដល់ការបង្កើនឱកាសដល់ស្ត្រី និងក្មេងស្ត្រីក្នុងការទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនានា និងការចូលរួមនិងការទទួលបានសេវាសាធារណៈ។ ខ្វះការគាំទ្រ និងលើកទឹកចិត្តពីគ្រួសារនិងសហគមន៍ក្នុងការជំរុញឱ្យស្ត្រីចូលរួមក្នុងកិច្ចអភិវឌ្ឍ។ កម្ពុជាបានបង្ហាញប្រពៃណីនៃសហគ្រិនភាពរបស់ស្ត្រីដែលមានសក្តានុពល ច្រើនក្នុងការបង្កើត និងពង្រីកអាជីវកម្មខ្នាតតូច និងមធ្យម ប៉ុន្តែនៅមានឧបសគ្គជាច្រើនទាក់ទងនឹងលទ្ធភាពទទួលបានហិរញ្ញវត្ថុ និងសេវាកម្មអភិវឌ្ឍន៍អាជីវកម្ម ហើយស្ត្រីភាគច្រើនស្ថិតក្នុងវិស័យឧស្សាហកម្មដែលមានផលិតភាពទាប ប្រាក់ឈ្នួលនៅមានកម្រិតទាប លក្ខខណ្ឌការងារមិនសូវអំណោយផល។ អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រនៅតែបន្តកើតមានឡើង ដែលជាការឆ្លុះបញ្ចាំង

ពីវិសមភាពយេនឌ័រផង និងការពង្រឹងឱ្យមានវិសមភាពយេនឌ័របន្ថែមទៀត។

ការអប់រំ និងការបណ្តុះបណ្តាល គឺជាយុទ្ធសាស្រ្តសំខាន់ជាងគេ ដើម្បីសម្រេចគោលបំណងនៃការអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។ ភស្តុភាងនៃការស្រាវជ្រាវ និងបទពិសោធន៍ជាច្រើនពីប្រទេសផ្សេងៗក្នុងសកលលោកបានបង្ហាញពីអានុភាពនៃការអប់រំ ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅ ជួយមនុស្សឱ្យទទួលបានការងារសមរម្យ បង្កើនប្រាក់ចំណូលរបស់ពួកគេ និងបង្កើនផលិតភាព ដែលជួយនាំមកនូវការអភិវឌ្ឍសេដ្ឋកិច្ច។ ការអប់រំ គឺជាមធ្យោបាយដែលមានអានុភាពបំផុតដើម្បីសម្រេចសមភាពយេនឌ័រ លើកកម្ពស់សុខភាពប្រជាពលរដ្ឋ ជំរុញលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស បង្កើនភាពជាប្រជាពលរដ្ឋសកល ជំរុញឱ្យមានការចូលរួមពីប្រជាពលរដ្ឋ ក៏ដូចជាការអភិវឌ្ឍប្រកបដោយចីរភាព។ ជារួម ការអប់រំ និងការបណ្តុះបណ្តាល គឺជាដំណោះស្រាយតែមួយគត់ សម្រាប់អភិវឌ្ឍធនធានមនុស្សដែលជាតម្រូវការចាំបាច់ និងជំរុញឱ្យមាននវានុវត្តន៍ និងអភិវឌ្ឍខ្លាំងក្លាពីសេដ្ឋកិច្ចពឹងផ្អែកលើកម្លាំងពលកម្មទៅសេដ្ឋកិច្ចផ្អែកលើចំណេះដឹង។ បរិបទនេះទើបប្រទេសកម្ពុជារៀបចំផែនទីបង្ហាញផ្លូវវិស័យអប់រំ ឆ្នាំ២០៣០ នេះឡើង។

## ៣. បរិបទនៃការអភិវឌ្ឍវិស័យអប់រំកម្ពុជា

កម្ពុជាបានចាប់ផ្តើមកសាងរចនាសម្ព័ន្ធ និងស្ថាប័ននយោបាយ សង្គម និងសេដ្ឋកិច្ចឡើងវិញ បន្ទាប់ពីបានបញ្ចប់ជម្លោះផ្ទៃក្នុង។ ទន្ទឹមនឹងការសម្រេចបានលទ្ធផលធំធេង ក្នុងការដោះស្រាយបញ្ហាប្រឈមធំ ដោយប្រើប្រាស់រយៈពេលខ្លីកម្ពុជាមានលទ្ធភាពបង្កើត និងរៀបចំប្រព័ន្ធអប់រំជាតិឡើងវិញ ដោយបានដាក់ចេញនូវគោលបំណងគោលនយោបាយយ៉ាងច្បាស់លាស់ យន្តការអភិបាលកិច្ចដែលមានដំណើរការ និងគ្រឹះស្ថានសិក្សាជាច្រើននៅទូទាំងប្រទេស។ ប្រព័ន្ធអប់រំបានផ្តល់សេវាអប់រំដល់សិស្ស មាតាបិតា គ្រូបង្រៀន និងអ្នកសិក្សាពេញវ័យរាប់សែននាក់នៅទូទាំងប្រទេស។ ស្របនឹងការប្តេជ្ញាចិត្តខ្ពស់នៅថ្នាក់ជាតិ ភាពជាដៃគូ និងការរៀបចំអន្តរាគមន៍ចំគោលដៅ បានផ្តល់នូវកាលានុវត្តដ៏ធំធេង ដើម្បីធានាឱ្យកុមារគ្រប់រូបអាចទទួលបានការអប់រំ។ ផ្នែកនេះធ្វើការពិភាក្សាពីបរិបទនៃការអភិវឌ្ឍវិស័យអប់រំ រួមនឹងសមិទ្ធផល និងបញ្ហាប្រឈមនានា។

### ៣.១ រដ្ឋធម្មនុញ្ញ និងក្របខណ្ឌគតិយុត្ត

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ទទួលស្គាល់សិទ្ធិរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងការទទួលបានការអប់រំ ដោយរដ្ឋត្រូវទទួលខុសត្រូវក្នុងការការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ក្នុងការទទួលបានការអប់រំគ្រប់កម្រិតទាំងអស់ប្រកបដោយគុណភាព។ មាត្រា ៦៥ នៃរដ្ឋធម្មនុញ្ញ ចែងថា "រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការគ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះបានទៅដល់ប្រជាពលរដ្ឋគ្រប់រូប"។ មាត្រា៦៦ នៃរដ្ឋធម្មនុញ្ញ បង្ហាញពីគោលការណ៍សំខាន់ៗនៃប្រព័ន្ធអប់រំ"រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញនិងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការ និងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូប មានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត"។ ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការអប់រំរបស់កម្ពុជា ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីខែធ្នូ ឆ្នាំ២០០៧ បានចែងថា ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច ៩ឆ្នាំ ប្រកបដោយគុណភាពដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ។ រាជរដ្ឋាភិបាលកម្ពុជាទទួលយកទស្សនទាន ដែលថាការអប់រំគឺជាសិទ្ធិមនុស្សជាមូលដ្ឋាន ដែលមានតួនាទីយ៉ាងសំខាន់ ដើម្បីឱ្យប្រជាពលរដ្ឋអាចមានការអភិវឌ្ឍគ្រប់ជ្រុងជ្រោយ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នអនុសញ្ញាស្តីពីសិទ្ធិកុមារ កាលពី ឆ្នាំ១៩៩២ និងអនុសញ្ញាស្តីពីសិទ្ធិជនពិការ កាលពីឆ្នាំ២០១២។

## ៣.២ រចនាសម្ព័ន្ធនៃប្រព័ន្ធអប់រំ

ប្រព័ន្ធអប់រំកម្ពុជា មាន ៖ (ក) កម្រិតមត្តេយ្យសិក្សា រយៈពេល ៣ឆ្នាំ (ខ) កម្រិតបឋមសិក្សា (ថ្នាក់ទី១-៦) រយៈពេល ៦ឆ្នាំ (គ) កម្រិតមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៩) រយៈពេល ៣ឆ្នាំ និងកម្រិតមធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២) រយៈពេល ៣ឆ្នាំ និង(ឃ) កម្រិតឧត្តមសិក្សា (បរិញ្ញាបត្ររយៈពេល ៤ឆ្នាំ បរិញ្ញាបត្រជាន់ខ្ពស់ រយៈពេល ២ឆ្នាំ និងថ្នាក់បណ្ឌិត រយៈពេល ៣ ឆ្នាំ ទៅ ៦ឆ្នាំ)។ ប្រព័ន្ធអប់រំនេះក៏ផ្តល់ការអប់រំក្រៅប្រព័ន្ធផងដែរ ដោយផ្តោតសំខាន់លើអក្ខរកម្មមនុស្សពេញវ័យក្រោយអក្ខរកម្ម និងសមមូលទៅនឹងអប់រំផ្លូវការ។ កម្ពុជា ក៏មានកម្មវិធីតម្រង់ទិស អប់រំបច្ចេកទេស និងវិជ្ជាជីវៈជាច្រើនដែលដំណើរការក្រោមក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ៣.៣ អភិបាលកិច្ច និងហិរញ្ញប្បទានវិស័យអប់រំ

វិស័យអប់រំគ្រប់គ្រងដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមាន ៧ អគ្គនាយកដ្ឋាន ៣៧ នាយកដ្ឋានជំនាញ ២៥ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និង១៩៧ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។ គ្រឹះស្ថានសិក្សាមានជិត ១៣ ០០០ ដែលជាសាលាមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា។ សាលាគរុកោសល្យមាន ២៣និងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជន ១២១។ ក្រសួងអប់រំ យុវជន និងកីឡា ទទួលបន្ទុករៀបចំ ដឹកនាំការអនុវត្ត និងពិនិត្យតាមដានគោលនយោបាយ ផែនការ និងកម្មវិធីអប់រំ។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ទទួលខុសត្រូវជួយគាំទ្រក្រសួងក្នុងការអនុវត្តគោលនយោបាយ និងកម្មវិធីអប់រំ រៀបចំផែនការនិងដាក់សំណើសម្រាប់បន្តអភិវឌ្ឍវិស័យអប់រំ ផ្តល់ទិន្នន័យនិងស្ថិតិ និងគ្រប់គ្រងបុគ្គលិកអប់រំ។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ មានតួនាទីសំខាន់ក្នុងការធានាបាននូវការអនុវត្តគោលនយោបាយ និងកម្មវិធីអប់រំ។ នាយកសាលាមានភារកិច្ចរៀបចំផែនការអភិវឌ្ឍផែនការប្រចាំឆ្នាំ និងត្រួតពិនិត្យដំណើរការប្រចាំថ្ងៃរបស់សាលារៀន។

ថវិកាជាតិសម្រាប់វិស័យអប់រំភាគច្រើន ទទួលបានមកពីរដ្ឋាភិបាល។ លើសពីនេះ វិស័យអប់រំក៏ទទួលបានមូលនិធិគាំទ្រពីប្រភពផ្សេងទៀតជាច្រើនដែរដូចជា អង្គការមិនមែនរដ្ឋាភិបាល កម្ចីពីបរទេស ជំនួយបច្ចេកទេស និងហិរញ្ញប្បទានឥតសំណង និងចំណូលដែលរកបានដោយសហគមន៍ និងសាលារៀននីមួយៗ។ ថវិកាសម្រាប់វិស័យអប់រំគិតជាភាគរយនៃផ.ស.ស.គឺ ៣,៤៧ ភាគរយ ឆ្នាំ២០១៨។ ភាគរយនៃថវិកាជាតិសម្រាប់វិស័យអប់រំ បានកើនឡើងក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ឆ្នាំ២០១៣ ភាគរយនៃថវិកាវិស័យអប់រំធៀបនឹងថវិកាជាតិគឺ ១៥,៥ ភាគរយ កើនដល់ ១៨,៣ ភាគរយ ឆ្នាំ២០១៦។

## ៣.៤ គោលនយោបាយ យុទ្ធសាស្ត្រវិស័យអប់រំ

រាជរដ្ឋាភិបាលបានចាត់ទុកថា ការអប់រំមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការសម្រេចមហិច្ឆតារបស់ខ្លួន ដើម្បីប្រែក្លាយពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាបទៅប្រទេសចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសដែលមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០។ ដើម្បីសម្រេចគោលដៅនេះ ត្រូវអភិវឌ្ឍគោលនយោបាយ និងយុទ្ធសាស្ត្រអប់រំ ឱ្យឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ (២០១៤-២០១៨) និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ (២០១៨-២០២៣)បានផ្តល់អាទិភាពលើមនុស្ស។ ឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណដែលផ្តល់អាទិភាពខ្ពស់លើមនុស្ស ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និងសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ ត្រូវអភិវឌ្ឍធនធានមនុស្សដែលមានសមត្ថភាព និងគុណភាពខ្ពស់ ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ច និងភាពប្រកួតប្រជែងរបស់ប្រទេស។ សូមពិនិត្យមើលតារាងខាងក្រោម ៖

**តារាង ២ ៖ យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ (២០១៨ -២០២៣)**

| | |
|---|---|
| **ចតុកោណទី១ ៖ ការអភិវឌ្ឍធនធានមនុស្ស**<br>១) ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា<br>២) ការបណ្តុះបណ្តាលជំនាញបច្ចេកទេស<br>៣) ការលើកកម្ពស់សេវាសុខភាពសាធារណៈ និងអាហារូបត្ថម្ភ<br>៣) ការពង្រឹងសមភាពយេនឌ័រ និង ការគាំពារសង្គម | **ចតុកោណទី៣ ៖ ការអភិវឌ្ឍវិស័យឯកជន និងការងារ**<br>១) ការអភិវឌ្ឍទីផ្សារការងារ<br>២) ការលើកស្ទួយសហគ្រាសធុនតូច និង មធ្យម និងសហគ្រិនភាព<br>៣) ការរៀបចំ និង អនុវត្តភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន<br>៤) ការពង្រឹងការប្រកួតប្រជែង |
| **ចតុកោណទី២ ៖ ការធ្វើពិពិធកម្មសេដ្ឋកិច្ច**<br>១) ការកែលម្អប្រព័ន្ធឡូជីស្ទីក ការលើកកម្ពស់ការតភ្ជាប់ផ្នែកដឹកជញ្ជូន ថាមពល និងឌីជីថល<br>២) ការអភិវឌ្ឍប្រភពកំណើនសេដ្ឋកិច្ចគន្លឹះ និងថ្មីៗ<br>៣) ការរៀបចំខ្លួនសម្រាប់សេដ្ឋកិច្ចឌីជីថល និងឆ្លើយតបនឹងបដិវត្តឧស្សាហកម្មទី៤<br>៤) ការជំរុញការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងធនាគារ | **ចតុកោណទី៤ ៖ ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន**<br>១) ការលើកស្ទួយវិស័យកសិកម្ម និង ការអភិវឌ្ឍជនបទ<br>២) ការគ្រប់គ្រងធនធានធម្មជាតិ និង វប្បធម៌ប្រកបដោយចីរភាព<br>៣) ការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម<br>៤) ការធានាចីរភាពបរិស្ថាន និង ការរៀបចំខ្លួនឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ |

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ បានរៀបចំឡើងជាជំហានៗសម្រាប់កសាងធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ សំដៅរួមចំណែកសម្រេចចក្ខុវិស័យ និងគោលដៅជាតិទាំងនេះ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផ្តល់អាទិភាពខ្ពស់ដល់ការទទួលបានសេវាអប់រំកម្រិតមូលដ្ឋានប្រកបដោយគុណភាពខ្ពស់ និងសមធម៌។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំមានគោលនយោបាយសំខាន់បី គឺ ក) ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ ខ) លើកកម្ពស់គុណភាព និងភាពឆ្លើយតប និងគ) ធានាភាពសក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំនៅគ្រប់កម្រិតថ្នាក់។ វិធានការជាច្រើន បានដាក់ចេញដើម្បីបង្កើនការចូលរៀនរបស់កុមារ និង យុវជន ដែលបាត់បង់ឱកាស ឱ្យទទួលបានការអប់រំកនៅកម្រិតផ្សេងៗ។

កំណែទម្រង់អភិបាលកិច្ច គឺជាសមាសភាគស្នូលនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ បច្ចុប្បន្នវិធានការកំណែទម្រង់សំខាន់ៗ បាននិងកំពុងអនុវត្ត ដើម្បីបង្កើនសមត្ថភាព និងគណនេយ្យភាពរបស់គ្រូបង្រៀនដូចជា ការអនុវត្តយ៉ាងតឹងរឹងនូវក្រមសីលធម៌គ្រូបង្រៀនជាដើម។ ការគ្រប់គ្រងវិស័យអប់រំកាន់តែមានប្រសិទ្ធភាព តម្លាភាព និងផ្តោតលើលទ្ធផលតាមរយៈការកែលម្អការគ្រប់គ្រងថវិកាដោយផ្សារភ្ជាប់ធនធានហិរញ្ញវត្ថុជាមួយនឹងលទ្ធផល ការអភិវឌ្ឍបុគ្គលិក ការពង្រឹងស្តង់ដាគុណផល ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីនៅគ្រប់កម្រិតថ្នាក់ និងការកែលម្អភាពជាដៃគូរវាងរដ្ឋាភិបាល និងសហគមន៍ និងមាតាបិតាសិស្ស ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។

បន្ទាប់ពីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំបានពីរឆ្នាំកន្លះ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិក្នុងឆ្នាំ២០១៦ ដើម្បីពិនិត្យមើលថាតើគោលដៅ និងគោលបំណងនានាដែលបានដាក់ចេញនៅក្នុងផែនការយុទ្ធសាស្ត្រ បានសម្រេចប្រកបដោយប្រសិទ្ធភាពដែរឬទេ។ ការពិនិត្យឡើងវិញនេះ ក៏មានគោលបំណងបច្ចុប្បន្នភាពផែនការឱ្យស្របតាមចំណុចដៅនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជាផងដែរ។ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនេះ បានកែសម្រួលគោលនយោបាយអប់រំរយៈពេលមធ្យមពីបីមកត្រឹមពីរវិញ។ ទន្ទឹមនឹងនេះ ក្រសួងអប់រំ យុវជន និងកីឡា បានទទួលយកជាផ្លូវការនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ (ធានាការអប់រំឱ្យមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សារៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា) ជាគោលនយោបាយទី១ និងរក្សាគោលនយោបាយទី៣ទៅជាគោលនយោបាយទី២វិញ។

## ៣.៥ សមិទ្ធផលសម្រេចបានក្នុងវិស័យអប់រំ និងបញ្ហាប្រឈម

### *ការអប់រំមត្តេយ្យសិក្សា*

ប្រទេសកម្ពុជា បានផ្តល់អាទិភាពខ្ពស់ដល់ការអប់រំមត្តេយ្យសិក្សា និងអនុវត្តនូវកម្មវិធី និងយុទ្ធសាស្ត្រជាច្រើន ដើម្បីពង្រីកការចូលរៀននៅមត្តេយ្យសិក្សា។ ទិន្នន័យបានបង្ហាញថា កុមារអាយុ ៥ ឆ្នាំ ៦៨,៥ ភាគរយ បានចូលរៀនក្នុងកម្មវិធីអប់រំកុមារតូច ឬ មត្តេយ្យសិក្សាគ្រប់រូបភាព ក្នុងឆ្នាំសិក្សា ២០១៧-២០១៨។ កុមារដ៏ច្រើនលើសលប់ (ពីរភាគបី) បានចូលរៀននៅសាលាមត្តេយ្យរដ្ឋ ខណៈពេលដែលកុមារផ្សេងទៀត ចូលរៀននៅ មត្តេយ្យសិក្សាសហគមន៍ (១៧,៥ ភាគរយ) ឬ សាលាមត្តេយ្យឯកជន (១០ ភាគរយ)។ ចំនួនសាលាមត្តេយ្យសិក្សារដ្ឋ បានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ សាលាមត្តេយ្យសិក្សារដ្ឋ មាន ៤ ១៧៦ ឆ្នាំសិក្សា២០១៧-២០១៨ ធៀបនឹង ១ ៦៣៤ ឆ្នាំសិក្សា២០០៧-២០០៨។ ដូចគ្នានេះដែរ សាលាមត្តេយ្យសិក្សាសហគមន៍ មាន ២ ៩៥៥ និងសាលាមត្តេយ្យសិក្សាឯកជន មាន ៤៥៦ ឆ្នាំសិក្សា២០១៧-២០១៨។ ចំនួនគ្រូបង្រៀនមានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ ពី ២ ៩៦០ ឆ្នាំសិក្សា២០០៧-២០០៨ ដល់ ៥ ៣៩៨ ឆ្នាំសិក្សា២០១៧-២០១៨។ ផ្អែកតាមរបាយការណ៍វិភាគស្ថានភាពអប់រំ ដែលរៀបចំដោយវិទ្យាស្ថានអន្តរជាតិសម្រាប់ផែនការអប់រំ ឆ្នាំ២០១៦ បង្ហាញថា ចំនួនសិស្សចូលរៀនមត្តេយ្យសិក្សាកើនឡើងជិត ២,៥ ដង ពីឆ្នាំសិក្សា ២០០៥-២០០៦ ដល់ ២០១៤-២០១៥ (ពោលគឺពី ១០១ ៥៥៩ នាក់ ទៅ ២៤៨ ៣៤៨ នាក់)។ សន្ទស្សន៍យុគភាពយេនឌ័រ ចាប់ពីឆ្នាំ២០០៧ ដល់ ២០១៦ នៅបន្តស្មើនឹង ១,០។

ទោះបី មានការសម្រេចបាននូវសមិទ្ធផលបែបនេះ ក៏នៅមានបញ្ហាប្រឈមចម្បងៗផងដែរ សម្រាប់អនុវិស័យអប់រំកុមារតូច។ កុមារនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល ជាពិសេសកុមារក្រីក្រ និងកុមារជួបការលំបាក មានលទ្ធភាពចូលរៀនតិចតួចប៉ុណ្ណោះ។ ការចូលរៀនទាបនៅមត្តេយ្យសិក្សា បានជះឥទ្ធិពលដល់ការត្រៀមខ្លួនចូលរៀនរបស់កុមារតូចភាគច្រើន។ កង្វះគ្រូបង្រៀនក៏ជាបញ្ហាប្រឈមធ្ងន់ធ្ងរផងដែរ។ ការជ្រើសរើសគ្រូបង្រៀនមិនទាន់ឆ្លើយតបនឹងសន្ទុះនៃការចូលរៀនរបស់កុមារឡើយ។ ប៉ុន្មានឆ្នាំចុងក្រោយ ការចូលរៀននៅមត្តេយ្យសិក្សារដ្ឋបានកើន ១០,៣ ភាគរយ ខណៈពេលដែលចំនួនគ្រូបង្រៀនបានកើនប្រហែល ៥,៥ ភាគរយ ប៉ុណ្ណោះ។ ប្រការនេះ បានជះឥទ្ធិពលដល់ផលធៀបសិស្ស-គ្រូ ដែលកើនឡើងពី ២៦,៩ ឆ្នាំសិក្សា២០០៧-២០០៨ ដល់ ៣៩,៨ ឆ្នាំសិក្សា២០១៧-២០១៨។

គុណភាពនៃការអប់រំកុមារតូច ជាកង្វល់មួយដ៏ធំផងដែរ។ ការវាយតម្លៃអំណានថ្នាក់ដំបូង ដែលបានធ្វើឡើងនៅឆ្នាំ២០១០ និង២០១២ បង្ហាញថា កុមារកម្ពុជាពុំទទួលបានការត្រៀមខ្លួនឱ្យបាន

គ្រប់គ្រាន់ ដើម្បីចូលរៀននៅបឋមសិក្សាឡើយ។ តេស្តវាយតម្លៃអំណានថ្នាក់ដំបូង ឆ្នាំ២០១២ បានបង្ហាញថា សិស្សថ្នាក់ទី ១ ពាក់កណ្តាលពុំអាចចំណាំអក្សរណាមួយបានឡើយ និងពីរភាគបីនៃសិស្សថ្នាក់ទី១ ពុំអាចអានពាក្យដែលពួកគេពុំធ្លាប់ឃើញណាមួយបានឡើយ។ ដូចគ្នានេះដែរ សិស្សថ្នាក់ទី២ពាក់កណ្តាល ពុំអាចអានពាក្យដែលពួកគេពុំធ្លាប់រៀនហើយណាមួយនោះឡើយ។ បញ្ហាប្រឈមទាក់ទងនឹងលទ្ធភាពចូលរៀន និងគុណភាពអប់រំ អាចបណ្តាលមកពីកង្វះគ្រូបង្រៀន ឬ អ្នកអប់រំកុមារតូចដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ និងគុណវុឌ្ឍិ កង្វះលិខិតបទដ្ឋានគតិយុត្ត និងការពិនិត្យតាមដានបុគ្គលិកដែលកំពុងចូលរួមអនុវត្តកម្មវិធីអប់រំកុមារតូចគ្រប់រូបភាព ការផ្តល់ថវិកាពុំបានគ្រប់គ្រាន់ក្របខណ្ឌគោលនយោបាយមិនទាន់ល្អ ការសម្របសម្រួលពុំបានល្អ ក្នុងចំណោមវិស័យនានា ការពិនិត្យតាមដានពុំបានគ្រប់គ្រាន់ និងកង្វះសម្ភារសិក្សា។

### *ការអប់រំបឋមសិក្សា*

កម្ពុជា បានសម្រេចជោគជ័យគួរឱ្យកត់សម្គាល់ នូវសកលកម្មនៃការអប់រំបឋមសិក្សា ដោយមានអត្រាពិតនៃការសិក្សា ៩៧,៨ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨។ សាលាបឋមសិក្សាមានស្ទើរតែគ្រប់ទីតាំងភូមិសាស្ត្រទាំងអស់។ ទិន្នន័យក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញថា ចន្លោះពីឆ្នាំសិក្សា២០០៧-២០០៨និង២០១៧-២០១៨ មានសាលារៀន ៧១៣ ត្រូវបានសាងសង់បន្ថែម។ អំឡុងពេលនេះចំណុះសិស្សក្នុងសាលារៀនជាមធ្យមបានថយពី ៣៥៧ នាក់ មកនៅត្រឹម ២៨៤ នាក់ ដែលបង្ហាញពីភាពប្រសើរឡើងក្នុងការធ្វើដំណើរទៅសាលារៀន។ ចំនួនសាលាបឋមសិក្សាមិនគ្រប់កម្រិត ក៏បានថយចុះផងដែរ ពី៩៥២ ឆ្នាំសិក្សា២០១២-២០១៣ មក ៥៣២ ឆ្នាំសិក្សា២០១៧-២០១៨។ ប្រសិទ្ធភាពផ្ទៃក្នុងកម្រិតបឋមសិក្សាមានភាពល្អប្រសើរផងដែរ ប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលបង្ហាញឱ្យឃើញតាមរយៈអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា។ អត្រាត្រួតថ្នាក់បានថយពី ១០,៦ ភាគរយ ឆ្នាំសិក្សា២០០៧-២០០៨ មក ៦,៥ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨។ សិស្សត្រួតថ្នាក់ទី១ច្រើន និងសិស្សនៅតំបន់ជនបទ។ សិស្សប្រុស ងាយនឹងត្រួតថ្នាក់ជាងសិស្សស្រី។ ភាគរយកុមារក្រៅសាលាមានភាពល្អប្រសើរជាងមុន ពោលគឺបានថយពី ២២,៨ ភាគរយ ឆ្នាំ២០០៤ មក ១៣,២ ភាគរយ ឆ្នាំ២០១២។

ទោះបី សម្រេចបានលទ្ធផលទាំងនេះ ក៏អនុវិស័យបឋមសិក្សានៅមានបញ្ហាប្រឈមជាច្រើនទៀតផងដែរ។ ការប្រឈមចម្បង គឺការឡើងចុះនៃអត្រាចូលរៀននៅបឋមសិក្សា។ ឧទាហរណ៍ អត្រាពិតនៃការសិក្សាបានថយពី ៩៨,៤ ភាគរយ ឆ្នាំសិក្សា ២០១៥-២០១៦ មក ៩៧,៨ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨ ។ កុមារដែលពុំបានចូលរៀន រួមមានកុមារពិការ កុមារមកពីគ្រួសារក្រីក្រ និងកុមារជនជាតិភាគតិច។ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាបានកើនឡើងក្នុងប៉ុន្មានឆ្នាំចុងក្រោយ ប៉ុន្តែ

បានថយចុះយ៉ាងគំហុកពី ៨៨,៩ ភាគរយ ឆ្នាំសិក្សា ២០១៣-២០១៤ មក ៨២,៧ ភាគរយ ឆ្នាំសិក្សា ២០១៧-២០១៨។ អត្រានេះមានកម្រិតទាបខ្លាំងនៅតាមបណ្ដាស្រុកភាគពាយ័ព្យ (ប្រមាណ ៧០ ភាគរយ)។ ជារឿយៗ អត្រាបញ្ចប់ការសិក្សាមានកម្រិតទាបនៅកន្លែងដែលមានអត្រាបោះបង់ការសិក្សាខ្ពស់។ អត្រាបញ្ចប់ការសិក្សាសម្រាប់សិស្សប្រុសមានកម្រិតទាបជាងសិស្សស្រី។

ការវាយតម្លៃលទ្ធផលសិក្សាបង្ហាញថា សិស្សនៅតាមសាលារៀនពុំបានរៀនសូត្រឱ្យបានគ្រប់គ្រាន់នៅឡើយ។ ក្នុងចំណោមសិស្សថ្នាក់ទី៣ដែលបានធ្វើតេស្តលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យានៅឆ្នាំ២០១២ មានតែ ៥៤,១ ភាគរយ ប៉ុណ្ណោះ ដែលឆ្លើយវិញ្ញាសារខ្មែរបានត្រឹមត្រូវ និង ៤៨ ភាគរយ ឆ្លើយវិញ្ញាសារគណិតវិទ្យាបានត្រឹមត្រូវ។ ការវាយតម្លៃលទ្ធផលសិក្សានៅឆ្នាំ២០១៤បង្ហាញពីលទ្ធផលធ្លាក់ចុះ ដោយសារតែក្នុងចំណោមសិស្សថ្នាក់ទី៣ដែលធ្វើតេស្តលើមុខវិជ្ជាភាសាខ្មែរ មានតែ ៣៥,២ ភាគរយ ប៉ុណ្ណោះ ឆ្លើយបានត្រឹមត្រូវ។ និន្នាការនៃការសម្រេចបានលទ្ធផលការសិក្សាទាបបែបនេះក៏រកឃើញក្នុងចំណោមសិស្សថ្នាក់ទី៦ផងដែរ។ ក្នុងចំណោមសិស្សថ្នាក់ទី៦ដែលបានធ្វើតេស្តលើមុខវិជ្ជាភាសាខ្មែរមានត្រឹមតែ ៤៥,៧ ភាគរយប៉ុណ្ណោះ ឆ្លើយបានត្រឹមត្រូវ។ រីឯតេស្តលើមុខវិជ្ជាគណិតវិទ្យាគឺមានត្រឹមតែ ៤៤,៣ ភាគរយ ឆ្លើយបានត្រឹមត្រូវក្នុងឆ្នាំ២០១៣។ ការវិភាគបានបង្ហាញពីបម្រែបម្រួលនៃលទ្ធផលសិក្សាសិស្សតាមភេទ សាវតារសង្គម សេដ្ឋកិច្ច និងទីតាំងភូមិសាស្ត្រ។ ហេតុផលជាច្រើនត្រូវបានលើកយកមកពន្យល់ពីការសម្រេចលទ្ធផលទាបរបស់សិស្ស ក្នុងការវាយតម្លៃការរៀនសូត្រ។ ការសិក្សារបស់ភាពជាដៃគូអប់រំនៃអង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ២០១៣បានបង្ហាញថា មានការបាត់បង់ចំនួនម៉ោងបង្រៀនជាច្រើននៅតាមសាលារៀន ដោយសារតែគ្រូបង្រៀនអវត្តមាន ចំនួនថ្ងៃឈប់សម្រាកបុណ្យសាធារណៈច្រើនពេក និងការខាតបង់ម៉ោងបង្រៀនជាក់ស្ដែង ដោយសារការអនុវត្តការងារគ្រប់គ្រងមិនបានល្អ។

## *ការអប់រំមធ្យមសិក្សា*

កាចូលរៀននៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ នៅតែមានកម្រិតថេរ ប៉ុន្មានឆ្នាំចុងក្រោយ។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ គឺ ៥៩,២ ភាគរយ និង ២៨,៥ ភាគរយ នៅមធ្យមសិក្សាទុតិយភូមិ ឆ្នាំសិក្សា២០១៧-២០១៨។ រាជរដ្ឋាភិបាលបានបង្កើនចំនួនសាលាមធ្យមសិក្សាបឋមភូមិប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលនាំឱ្យចំណុះសិស្សក្នុងសាលាមធ្យមសិក្សាបឋមភូមិបានថយពី ៤៨៩ នាក់ ឆ្នាំសិក្សា២០០៧-២០០៨ មក ៣៥៣ នាក់ ឆ្នាំសិក្សា២០១៧-២០១៨ និងបង្ហាញពីភាពប្រសើរឡើងក្នុងការទទួលបានសេវាអប់រំនៅមធ្យមសិក្សាបឋមភូមិ។ ចំនួនគ្រូបង្រៀននៅមធ្យមសិក្សាបឋមភូមិ ក៏បានកើនឡើងបន្តិចម្ដងៗផងដែរ ពី ២៣ ១៥៨ នាក់ ឆ្នាំសិក្សា២០០៧-២០០៨ ដល់ ៣៣ ១៨១ នាក់

ឆ្នាំសិក្សា២០១៧-២០១៨ ដែលនាំឱ្យផលធៀបសិស្ស-គ្រូថយចុះយ៉ាងគំហុកពី ២៧,៥៣ ឆ្នាំសិក្សា ២០០៧-២០០៨ មក ២២,៤ ឆ្នាំសិក្សា២០១៧-២០១៨។ ដូចគ្នានេះដែរ ចំនួនសាលាមធ្យមសិក្សាទុតិយភូមិក៏មានការកើនឡើងគួរឱ្យកត់សម្គាល់ផងដែរ។ ចំនួនសិស្សគិតជាមធ្យមក្នុងសាលាមធ្យមសិក្សាទុតិយភូមិគឺ ៨២៨ នាក់ ឆ្នាំសិក្សា២០០៧-២០០៨ធៀបនឹង៥៩៤ ឆ្នាំសិក្សា២០១៧-២០១៨។ ចំនួនគ្រូបង្រៀននៅមធ្យមសិក្សាទុតិយភូមិក៏បានកើនឡើងដែររយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ឆ្នាំសិក្សា ២០០៧-២០០៨ មានគ្រូមធ្យមសិក្សាទុតិយភូមិ ៦ ៧៨៤ នាក់ និងបានកើនដល់ ១៣ ២២៣ នាក់ ឆ្នាំសិក្សា២០១៧-២០១៨។ ការកើនឡើងចំនួនគ្រូបង្រៀន នាំឱ្យផលធៀបសិស្ស-គ្រូថយមកត្រឹម ២១,៦ ឆ្នាំសិក្សា២០១៧-២០១៨ ពី ៣៨,៤៧ ឆ្នាំសិក្សា២០០៧-២០០៨ ដែលជាកត្តាជួយបង្កើនគុណភាពនៃការបង្រៀន និងរៀនបន្ថែមទៀត។

ខណៈពេលដែលមានភាពវិជ្ជមានខ្លះៗនៃការអភិវឌ្ឍនៅមធ្យមសិក្សាកន្លងមកថ្មីៗ ក៏លទ្ធផលនៃការអប់រំមធ្យមសិក្សា ពុំទាន់មានកម្រិតគួរឱ្យកត់សម្គាល់នៅឡើយ។ និន្នាការនៃការចូលរៀននៅមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ បង្ហាញឱ្យឃើញនូវរូបភាពមិនទាន់ប្រសើរនោះទេ។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិគឺ ៥៩,២ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨ គឺស្ថិតក្រោម ៥ ភាគរយនៃអត្រារួមនៃការសិក្សាក្នុងឆ្នាំសិក្សា ២០០៧-២០០៨។ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិគឺ ៤៦,៥ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨ ធៀបនឹង ៤៤,៦ ភាគរយ ចំណុចដៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ការបោះបង់ការសិក្សា គឺជាបញ្ហាប្រឈមនៅមធ្យមសិក្សាបឋមភូមិ ពោលគឺមានកុមារជិត ២០ ភាគរយ បានបោះបង់ការសិក្សា។ អត្រាបោះបង់ការសិក្សា មានការប្រែប្រួលពីស្រុកមួយទៅស្រុកមួយទៀត ពោលគឺចាប់ពី ២១,៩ ភាគរយ ដល់ ៣៤,២ ភាគរយ។

ការចូលរៀននៅមធ្យមសិក្សាទុតិយភូមិ ក៏នៅមានកម្រិតទាបផងដែរ ដូចបានបង្ហាញតាមរយៈអត្រារួមនៃការសិក្សា និងអត្រាពិតនៃការសិក្សា។ ជារឿយៗ ប៉ុន្មានឆ្នាំចុងក្រោយ និន្នាការនៃការចូលរៀនមានភាពឡើងចុះ ដែលបណ្តាលមកពីយុវជនមានឱកាសរកការងារធ្វើច្រើនជាងមុននៅតំបន់ប្រជុំជន។ អត្រាបោះបង់ការសិក្សាកម្រិតនេះ ក៏មានកម្រិតខ្ពស់រហូតដល់ ២៧,៥ ភាគរយ ឆ្នាំសិក្សា២០១៤-២០១៥ និង១៨,៣ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨។ អត្រាបោះបង់ការសិក្សាមានកម្រិតខ្ពស់ ពិសេសនៅថ្នាក់ទី១២ (៣៨,៦ ភាគរយ)។ ការកត់សម្គាល់ឃើញថា ក្នុងចំណោមសិស្សប្រុសពីរនាក់នៅតំបន់ជនបទមានសិស្សម្នាក់បានបោះបង់ការសិក្សាមុនពេលបញ្ចប់ថ្នាក់ចុងក្រោយនៃមធ្យមសិក្សាទុតិយភូមិ។

លទ្ធផលសិក្សាមានកម្រិតទាប គឺជាបញ្ហារឹតតែធ្ងន់ធ្ងរថែមទៀតនៅមធ្យមសិក្សា។ ការវាយតម្លៃថ្នាក់ជាតិលើលទ្ធផលសិក្សារបស់សិស្ស ឆ្នាំសិក្សា២០១៣-២០១៤ បង្ហាញឃើញថា គេស្តលើមុខវិជ្ជា

ភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា មានកម្រិតទាប។ ក្នុងចំណោមសិស្សទាំងអស់ដែលបានធ្វើតេស្ត មាន ត្រឹមតែ ៥៥,៦ ភាគរយ បានឆ្លើយវិញ្ញាសារភាសាខ្មែរបានត្រឹមត្រូវ។ មុខវិជ្ជាគណិតវិទ្យាវិញ មានត្រឹមតែ ៤៤ ភាគរយ ប៉ុណ្ណោះឆ្លើយបានត្រឹមត្រូវ។ មុខវិជ្ជារូបវិទ្យា មានសិស្សត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ ដែល ផ្តល់ចម្លើយបានត្រឹមត្រូវ។ តេស្តទាំងអស់ សិស្សមួយភាគធំធ្វើតេស្តបានក្រោមកម្រិតមូលដ្ឋានប៉ុណ្ណោះ។ កត្តាជាច្រើន មានទំនាក់ទំនងជាមួយនឹងលទ្ធផលសិក្សារបស់សិស្ស ដូចជា ភេទ ទីតាំង ស្ថានភាព សង្គម-សេដ្ឋកិច្ច។ លទ្ធផលប្រឡងថ្នាក់ជាតិសម្រាប់បញ្ចប់មធ្យមសិក្សាទុតិយភូមិបានបង្ហាញពីនិន្នាការ គួរឱ្យព្រួយបារម្ភ។ ភាគរយសិស្សប្រឡងជាប់ថ្នាក់ទី១២ ដែលមានកម្រិតខ្ពស់រហូតទៅដល់ ៨៦,៨ ភាគរយ ឆ្នាំសិក្សា២០១៣-២០១៤ បានថយមកត្រឹម ៤០,៦ ភាគរយ ឆ្នាំសិក្សា២០១៣-២០១៤ និង បានកើនដល់ ៦៧,០៧ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨។ ភាគរយប្រឡងជាប់មានកម្រិតទាបប៉ុន្មាន ឆ្នាំចុងក្រោយ ដោយសារតែការធ្វើកំណែទម្រង់ការប្រឡងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

### *ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ*

ការផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជាផ្លូវការនៅកម្ពុជាបែងចែកជា ៤ កម្រិត ៖ (ក)កម្រិតវិញ្ញាបនបត្រ(វគ្គខ្លីៗចាប់ពីពីរបីសប្តាហ៍រហូតដល់ជិតមួយឆ្នាំដើម្បីអាចទទួលបានវិញ្ញាបនបត្រ) (ខ)កម្រិតឌីប្លូម៉ា (ការបណ្តុះបណ្តាលក្រោយថ្នាក់ទី៩ ដែលសិក្ខាកាមទទួលបានឌីប្លូម៉ា បន្ទាប់ពីបញ្ចប់ ការសិក្សា រយៈពេលមួយឆ្នាំដល់បីឆ្នាំ) (គ)កម្រិតឌីប្លូម៉ាជាន់ខ្ពស់ (ការសិក្សារយៈពេលពីរឆ្នាំ ក្រោយ បញ្ចប់ថ្នាក់ទី១២ ដើម្បីទទួលបានវិញ្ញាបនបត្រឌីប្លូម៉ាជាន់ខ្ពស់ពីវិទ្យាស្ថានពហុបច្ចេកទេស ឬ វិទ្យាស្ថាន បច្ចេកទេស) និង (ឃ)កម្រិតថ្នាក់បរិញ្ញាបត្រ (ក្រោយថ្នាក់ទី១២ បូករយៈពេលបួនឆ្នាំ (៤,៥ឆ្នាំ សម្រាប់ ជំនាញវិស្វកម្ម)ដែលនិស្សិតទទួលបានបរិញ្ញាបត្រឬឌីប្លូម៉ាបូកនឹងការបណ្តុះបណ្តាលរយៈពេល២ឆ្នាំ)។

កម្មវិធីការអប់រំបច្ចេកទេស និងវិជ្ជាជីវៈត្រូវបានផ្តល់នៅតាមវិទ្យាស្ថានពហុបច្ចេកទេស និង វិទ្យាស្ថានបច្ចេកទេស។ យោងតាមការពិនិត្យឡើងវិញលើគោលនយោបាយការអប់រំបច្ចេកទេស និង វិជ្ជាជីវៈឆ្នាំ២០១៣នៅកម្ពុជា ដែលធ្វើឡើងដោយអង្គការយូណេស្កូ មានវិទ្យាស្ថានពហុបច្ចេកទេស និង វិទ្យាស្ថានបច្ចេកទេស ១៤ កំពុងផ្តល់វគ្គសិក្សាអប់រំបច្ចេកទេស និងវិជ្ជាជីវៈកម្រិតវិញ្ញាបនបត្រ ឌីប្លូម៉ា និងបរិញ្ញាបត្រ។ ទិន្នន័យអំពីលក្ខណៈសំខាន់ៗនៃប្រព័ន្ធអប់រំបច្ចេកទេស និងវិជ្ជាជីវៈភាគច្រើន ពុំមាន នោះឡើយ។

សាលាមធ្យមសិក្សាមួយចំនួនតូច ក៏បានផ្តល់ការអប់រំបច្ចេកទេសផងដែរ។ ក្រសួងអប់រំ យុវជន និងកីឡា គ្រោងនឹងបញ្ចូលបំណិនជីវិតទៅក្នុងកម្មវិធីសិក្សាកម្រិតមធ្យមសិក្សា និងនៅត្រឹមឆ្នាំ២០១៨ នឹងមានសាលាមធ្យមសិក្សាទុតិយភូមិ ៣០ ភាគរយ អនុវត្តកម្មវិធីបំណិនជីវិត។

អ្នកផ្តល់សេវាជាច្រើនកំពុងចូលរួមផ្តល់កម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈក្រៅប្រព័ន្ធដែលមានស្ថាប័នរដ្ឋដូចជា វិទ្យាស្ថានបណ្តុះបណ្តាលថ្នាក់ខេត្ត មជ្ឈមណ្ឌលសិក្សាសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល មជ្ឈមណ្ឌលអភិវឌ្ឍន៍ដើម្បីស្ត្រី អ្នកផ្តល់សេវាបណ្តុះបណ្តាលឯកជន និងអាជីវកម្មខ្នាតតូចជាដើម។ មជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់ខេត្ត ២២ បានផ្តល់កម្មវិធីបណ្តុះបណ្តាលជំនាញកសិកម្ម សិប្បកម្ម និងវិជ្ជាជីវៈកម្រិតមូលដ្ឋាន។ មជ្ឈមណ្ឌលសិក្សាសហគមន៍ផ្តល់ការបណ្តុះបណ្តាលអក្ខរកម្ម និងការបណ្តុះបណ្តាលវិជ្ជាជីវៈកម្រិតមូលដ្ឋានសម្រាប់បង្កើនចំណូល។ លើសពីនេះ ក៏មានកម្មវិធីអភិវឌ្ឍជំនាញក្រៅផ្លូវការជាច្រើនដែលផ្តល់ដោយរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយក្រោមមូលនិធិបណ្តុះបណ្តាលនានា។

ក្នុងឆ្នាំ២០០៥ ការទទួលខុសត្រូវលើកម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈជាផ្លូវការត្រូវបានផ្ទេរពីក្រសួងអប់រំ យុវជន និងកីឡាទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានភារកិច្ចគ្រប់គ្រង និងធ្វើនិយ័តកម្មជាផ្លូវការលើកម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈផ្លូវការផង និងមិនផ្លូវការផង។ គណៈកម្មាធិការជាតិបណ្តុះបណ្តាលមានភារកិច្ចរៀបចំគោល-នយោបាយពិគ្រោះយោបល់ និងពិនិត្យតាមដានលើប្រព័ន្ធអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។ គណៈកម្មាធិការនេះមានមុខងារតាក់តែងគោលនយោបាយផង និងត្រួតពិនិត្យផង។ រាជរដ្ឋាភិបាលបានរៀបចំនូវក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ដែលមានគោលបំណងឱ្យអ្នកផ្តល់សេវាសាធារណៈ និងវិស័យឯកជន ក្រសួងនានា និងប្រព័ន្ធអប់រំបច្ចេកទេស និងវិជ្ជាជីវៈទាំងផ្លូវការ និងមិនផ្លូវការ អនុវត្តដំណើរការបញ្ជាក់ពីគុណវុឌ្ឍិឱ្យបានដូចៗគ្នា។ ថ្មីៗនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈទើបតែនឹងដាក់ចេញនូវគោលនយោបាយអប់រំបច្ចេកទេស និងវិជ្ជាជីវៈថ្មីរបស់ខ្លួន។

វិស័យអប់រំបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា ប្រឈមនឹងបញ្ហាជាច្រើនពាក់ព័ន្ធនឹងការទទួលបានសេវាគុណភាព និងសមត្ថភាពស្ថាប័ន។ ប្រព័ន្ធអប់រំបច្ចេកទេស និងវិជ្ជាជីវៈបច្ចុប្បន្ន នៅមានកម្រិត និងមិនទាន់ឆ្លើយតបនឹងតម្រូវការរបស់ឧស្សាហកម្មនៅឡើយ។ វិទ្យាស្ថានអប់រំបច្ចេកទេស និងវិជ្ជាជីវៈអាចទ្រទ្រង់ឱ្យនិស្សិតបញ្ចប់ការសិក្សាប្រកបដោយគុណវុឌ្ឍិប្រចាំឆ្នាំ បានតែ ២ ៥០០នាក់ ពោលគឺពុំទាន់គ្រប់គ្រាន់សម្រាប់បំពេញតម្រូវការជំនាញឡើយ។ ខណៈពេលដែលអត្រាបោះបង់ការសិក្សាខ្ពស់នៅបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នោះពុំអាចរកបានបេក្ខជនសមស្របគ្រប់ចំនួន ដើម្បីចូលរៀន

ឬ ចាប់អារម្មណ៍កម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈបានទេ។ វិទ្យាស្ថានអប់រំបច្ចេកទេស និងវិជ្ជាជីវៈជាច្រើន បានរាយការណ៍ថា គុណភាពសិស្សបញ្ចប់ការសិក្សាថ្នាក់ទី ៩ មានកម្រិតទាប ជាពិសេសពាក់ព័ន្ធនឹងអក្ខរកម្ម និងលេខនព្វន្ត។

កម្មវិធីស្ពានចម្លងអប់រំសម្រាប់ផ្តល់ឱកាសលើកទី២ដល់យុវជនក្រៅសាលា ក្នុងការបញ្ចប់ការអប់រំមធ្យមសិក្សា និងបន្តរៀនលើផ្នែកអប់រំបច្ចេកទេស និងវិជ្ជាជីវៈមានកម្រិតនៅឡើយ។ បញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ ដូចជា ថ្លៃសិក្សា ជាដើម បានបន្ទុចបង្អាក់ដល់ការចូលរៀន និងបញ្ចប់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈជាផ្លូវការ។ វិទ្យាស្ថានអប់រំបច្ចេកទេស និងវិជ្ជាជីវៈ អាចផ្តល់នូវកម្មវិធីថ្នាក់វិញ្ញាបនបត្រ និងឌីប្លូម៉ាសម្រាប់តែមុខវិជ្ជាមួយចំនួនតូចប៉ុណ្ណោះ និងពុំមានមុខវិជ្ជាច្រើនសម្រាប់ជ្រើសរើសឡើយ។ វគ្គសិក្សាជាច្រើន ផ្តោតតែទៅលើអាជីពការងាររបស់បុរសដែលមានលក្ខណៈបុរាណ និងផ្តល់ជម្រើសតិចតួចប៉ុណ្ណោះដល់ក្មេងស្រី និងស្ត្រី។ វិទ្យាស្ថានអប់រំបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈភាគច្រើនពុំមានឧបករណ៍ និងសម្ភារបរិក្ខារសម្រាប់ផ្តល់ការបណ្តុះបណ្តាល ឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្មឱ្យបានគ្រប់គ្រាន់ឡើយ និងគុណភាពនៃគ្រូបណ្តុះបណ្តាលក៏នៅមានកម្រិតទាប។ កម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈផ្លូវការ ផ្តោតភាគច្រើនលើខ្លឹមសារទ្រឹស្តី និងផ្តល់ឱកាសអនុវត្តជាក់ស្តែងតិចតួចប៉ុណ្ណោះ។ ការប្រើប្រាស់ព័ត៌មានទីផ្សារការងារ និងការអង្កេតសាកសួរព័ត៌មានពីនិយោជកក្នុងលក្ខណៈជាប្រព័ន្ធដើម្បីកំណត់ពីកង្វះជំនាញសម្រាប់យកមករៀបចំជាវគ្គសិក្សានានា មានកម្រិតតិចតួចនៅឡើយ។ ផ្អែកតាមការពិនិត្យឡើងវិញគោលនយោបាយអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ កម្មវិធីសម្រាប់អប់រំបច្ចេកទេស និងវិជ្ជាជីវៈ ប្រើប្រាស់អតិក្រមផ្តោតលើការផ្គត់ផ្គង់ និងទំនាក់ទំនងរវាងវិទ្យាស្ថានអប់រំបច្ចេកទេស និងវិជ្ជាជីវៈ និងសហគ្រាសនៅមានភាពទន់ខ្សោយនៅឡើយ។

ភាពទាក់ទាញនៃការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ គឺជាកង្វល់ដ៏ធំ។ យុវជនមិនសូវចាប់អារម្មណ៍ពីការចូលរៀនកម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ទោះបីជា កម្មវិធីទាំងនេះផ្តល់ដោយមិនគិតថ្លៃនៅតាមវិទ្យាស្ថានសាធារណៈក៏ដោយ។ យុវជនជាច្រើន ពុំចង់លះបង់ការងារ ដើម្បីមករៀនពេញម៉ោងនៅក្នុងកម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈនោះទេ។ លើសពីនេះ ក៏មានការយល់ឃើញអវិជ្ជមានជាទូទៅអំពីកម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈផងដែរ។ ពួកគេយល់ថា កម្មវិធីទាំងនេះសម្រាប់កម្មករ និងទទួលបានការងារដែលមានប្រាក់ឈ្នួលទាប។ កត្តានេះ នាំឱ្យពិបាកទាក់ទាញយុវជនឱ្យមកចូលរៀនក្នុងកម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ដោយសារតែពួកគេពុំមានឱកាសបន្តការសិក្សាទៅកម្រិតខ្ពស់ជាងនេះទៀតសម្រាប់ឯកទេសដែលកំពុងផ្តល់នាពេលបច្ចុប្បន្ននេះ។

ការពិនិត្យឡើងវិញលើគោលនយោបាយអប់រំបច្ចេកទេស និងវិជ្ជាជីវៈ បានកត់សម្គាល់ថា ការពុំមានការសម្របសម្រួលឱ្យបានជាប់ជាប្រចាំ និងការប្រើប្រាស់អភិក្រមដែលមានលក្ខណៈរឹងមាំ និងស៊ីសង្វាក់គ្នា ជាកត្តាដែលបន្ទុចបង្អាក់ដល់ការសម្រេចបានវឌ្ឍនភាពរបស់ស្ថាប័ននានានៅក្នុងផ្នែកសំខាន់ៗមួយចំនួន ដូចជាការកំណត់ពីតម្រូវការជំនាញ ការផ្តល់ និងការត្រួតពិនិត្យលើការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈក្រៅប្រព័ន្ធ ការកែលម្អការរៀបចំផែនការយុទ្ធសាស្ត្រ និងទំនាក់ទំនងរវាងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ និងការអប់រំមធ្យមសិក្សាចំណេះទូទៅ និងការរៀបចំ និងផ្តល់ការអប់រំកម្រិតមធ្យមសិក្សា។

### *ការអប់រំកម្រិតឧត្តមសិក្សា*

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ការអប់រំឧត្តមសិក្សា គឺជាយុទ្ធសាស្ត្រដ៏សំខាន់មួយដើម្បីសម្រេចនូវគោលដៅនៃការអភិវឌ្ឍរបស់ខ្លួន។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលបានអនុវត្តគំនិតផ្តួចផ្តើមជាច្រើន ក្នុងការពង្រីកការទទួលបានការអប់រំនៅកម្រិតឧត្តមសិក្សា។ ក្នុងរយៈពេល ៣ ទសវត្សរ៍ចុងក្រោយនេះ ចំនួនគ្រឹះស្ថានឧត្តមសិក្សា និងចំនួននិស្សិតដែលបានចូលរៀន មានការកើនឡើងច្រើន។ ផ្តើមចេញពីសាកលវិទ្យាល័យតែមួយក្នុងឆ្នាំ១៩៧៩ កើនដល់ ៨ គ្រឹះស្ថានឧត្តមសិក្សានៅឆ្នាំ១៩៩៧ ហើយមាន ៧០ នៅឆ្នាំ២០០៩ និង ១២១ នៅឆ្នាំ២០១៨។ ការចូលរៀនមានកម្រិតទាបខ្លាំង (ត្រឹមតែ ១ ភាគរយនៃយុវជនដល់អាយុសិក្សានៅមហាវិទ្យាល័យ) កាលពីដើមទសវត្សរ៍ ១៩៩០ អត្រារួមនៃការសិក្សានៅឧត្តមសិក្សាបានកើនដល់ ៦ ភាគរយ ឆ្នាំ២០០៦ និង ១០ ភាគរយ ឆ្នាំ២០១៨។ អត្រារួមនៃការសិក្សានៅឧត្តមសិក្សា គឺ១៥ ភាគរយ ឆ្នាំសិក្សា២០១៤-២០១៥ ហើយបានថយចុះមកវិញដោយសារតែការថយចុះនៃអត្រាប្រឡងជាប់ថ្នាក់ទី១២ តាមរយៈកំណែទម្រង់រឹតបន្តឹងការប្រឡង ដែលរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្ត។

ប្រព័ន្ធអប់រំឧត្តមសិក្សាកម្ពុជា រួមមានសាកលវិទ្យាល័យ វិទ្យាស្ថាន ឬវិទ្យាស្ថានបច្ចេកទេស និងរាជបណ្ឌិតសភា ដែលផ្តល់កម្មវិធីសិក្សាកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត។ គ្រឹះស្ថានទាំងនេះដំណើរការក្រោមក្របខណ្ឌក្រសួង ស្ថាប័នផ្សេងៗគ្នា។ គិតត្រឹមឆ្នាំ ១៩៩៧ គ្រឹះស្ថានឧត្តមសិក្សាទាំងអស់សុទ្ធតែជាគ្រឹះស្ថានសាធារណៈ។ បន្ទាប់ពីមានការផ្លាស់ប្តូរគោលនយោបាយថ្មីដែលអនុញ្ញាតឱ្យមានការបង្កើតគ្រឹះស្ថានឧត្តមសិក្សាក្នុងប្រទេស ចំនួនសាកលវិទ្យាល័យក្រៅប្រទេសដែលមានទំនាក់ទំនងជាមួយនឹងសាកលវិទ្យាល័យសាធារណៈ និងឯកជនមានការកើនឡើងយ៉ាងច្រើន។

អនុវិស័យឧត្តមសិក្សានៅតែប្រឈមនឹងបញ្ហាធំៗដូចជា លទ្ធភាពទទួលបានសេវា គុណភាព សមធម៌ ភាពឆ្លើយតប ថវិកាគាំទ្រ និងការគ្រប់គ្រង។ បញ្ហាប្រឈមទាំងនេះ ត្រូវបានចងក្រងទុកជាឯកសារក្នុងផែនទីបង្ហាញផ្លូវឧត្តមសិក្សាកម្ពុជា(២០១៧-២០៣០) ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡាកាលពីឆ្នាំ២០១៦។ ខណៈពេលដែលមានការពង្រីកការអប់រំឧត្តមសិក្សាយ៉ាងឆាប់រហ័ស ការពង្រីកនេះធ្វើឡើងដោយពុំមានផែនការ និងពុំមានការសម្របសម្រួលឱ្យបានត្រឹមត្រូវ និងពុំមានអន្តរាគមន៍គោលនយោបាយ ដែលមានលក្ខណៈជាយុទ្ធសាស្ត្ររយៈពេលវែង។ ក្រសួង-ស្ថាប័នជាច្រើនពាក់ព័ន្ធនឹងការផ្តល់ការអប់រំឧត្តមសិក្សា នាំឱ្យមានការពិបាកសម្របសម្រួលគ្នារវាងស្ថាប័នទាំងនោះ ក្នុងការត្រួតពិនិត្យគុណភាព ភាពត្រួតគ្នាខាងផ្នែកកិច្ចការរដ្ឋបាល និងការចែករំលែកព័ត៌មាន។ ការចូលរៀននៅឧត្តមសិក្សាកម្ពុជា មានកម្រិតទាបជាងគេ ក្នុងចំណោមប្រទេសអាស៊ានទាំង ១០ និងប្រទេសអាស៊ីបូព៌ា។

កន្លងមក ការអប់រំឧត្តមសិក្សាមិនសូវបានយកចិត្តទុកដាក់ និងការផ្តល់ថវិការដ្ឋសម្រាប់ការអប់រំឧត្តមសិក្សាមានកម្រិតទាប បើធៀបនឹងស្តង់ដាទាំងអស់ (ដូចជា ភាគរយនៃផ.ស.ស ភាគរយនៃចំណាយចរន្តរបស់រាជរដ្ឋាភិបាលសម្រាប់វិស័យអប់រំ ចំណាយក្នុងនិស្សិតម្នាក់ជាដើម)។ ការផ្តល់ថវិកាពីអ្នកផ្តល់ជំនួយខាងក្រៅសម្រាប់អនុវិស័យឧត្តមសិក្សាមានកម្រិតតិចតួច ឬ ពុំមាន។ ផែនទីបង្ហាញផ្លូវនេះកត់សម្គាល់ថា រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ពុំមានឆន្ទៈវិនិយោគលើការអប់រំឧត្តមសិក្សានៅឡើយ។ ទន្ទឹមគ្នានឹងមានការកើនឡើងនូវការទទួលបានសេវាអប់រំឧត្តមសិក្សា ក៏មិនមានសមធម៌យេនឌ័រ និងប្រការជាច្រើនដទៃទៀត នៅតែបន្តមាន។

គុណភាព និងភាពឆ្លើយតបនៃការអប់រំឧត្តមសិក្សានៅកម្ពុជា នៅតែជាបញ្ហាចោទ។ ការអប់រំឧត្តមសិក្សាពុំបានឆ្លើយតបទៅនឹងតម្រូវការនៃទីផ្សារការងារ និងតម្រូវការសង្គមនៅឡើយ។ ការចូលរៀនបានប្រមូលផ្តុំតែលើមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ធុរកិច្ច ច្បាប់ និងមនុស្សសាស្ត្រ ដែលមានបីភាគបួននៃចំនួននិស្សិតចូលរៀននៅឧត្តមសិក្សា ហើយនិស្សិតរៀនមុខជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យាមានតិចតួចប៉ុណ្ណោះ។ ព័ត៌មានតិចតួចប៉ុណ្ណោះបានបង្ហាញពីគុណភាពអប់រំនៅឧត្តមសិក្សា។ ផែនទីបង្ហាញផ្លូវសម្រាប់ការអប់រំឧត្តមសិក្សាបានកត់សម្គាល់ថា គ្រឹះស្ថានឧត្តមសិក្សាកម្ពុជាខ្វះសាស្ត្រាចារ្យដែលមានគុណវុឌ្ឍិ ដើម្បីពន្លឿនការកែលម្អប្រព័ន្ធឧត្តមសិក្សា។ សាស្ត្រាចារ្យភាគច្រើន បានទទួលការបណ្តុះបណ្តាលតិចតួចប៉ុណ្ណោះកម្រិតក្រោយបរិញ្ញាបត្រ ពោលគឺពួកគេអាចទទួលបានការសិក្សាកម្រិតក្រោយបរិញ្ញាបត្រមួយ ឬ ពីរឆ្នាំប៉ុណ្ណោះ បន្ទាប់ពីបញ្ចប់ការអប់រំកម្រិតបរិញ្ញាបត្រ។ ការបណ្តុះបណ្តាលតិចតួចបែបនេះ គឺពុំគ្រប់គ្រាន់ដើម្បីឱ្យសាស្ត្រាចារ្យទាំងនេះ អាច

មានសមត្ថភាពបង្រៀននៅកម្រិតឧត្តមសិក្សាឡើយ ព្រោះតែពួកគេពុំមានសមត្ថភាពធ្វើការស្រាវជ្រាវបានទេ។ ឧទាហរណ៍ ឆ្នាំ២០០៨ សាស្ត្រាចារ្យឧត្តមសិក្សាធម្មតាម្នាក់ បានទទួលការបណ្តុះបណ្តាលក្រោយមធ្យមសិក្សា ៥,៤ ឆ្នាំ នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងការបណ្តុះបណ្តាល ៥,៥ ឆ្នាំនៅគ្រឹះស្ថានឧត្តមសិក្សាឯកជន។

គ្រឹះស្ថានឧត្តមសិក្សាភាគច្រើន គឺជាសាកលវិទ្យាល័យដែលផ្តោតលើការបង្រៀន និងធ្វើការសិក្សាស្រាវជ្រាវ និងផ្សព្វផ្សាយតិចតួចប៉ុណ្ណោះ។ សាស្ត្រាចារ្យពុំបានទទួលការបណ្តុះបណ្តាលឱ្យបានគ្រប់គ្រាន់ដើម្បីធ្វើការសិក្សាស្រាវជ្រាវ ឬ នវានុវត្តន៍កម្រិតខ្ពស់ ហើយក៏ពុំមានការលើកទឹកចិត្ត និងការផ្តល់ការគាំទ្រឱ្យបំពេញមុខងារទាំងនោះដែរ។ ដើម្បីឱ្យការអប់រំឧត្តមសិក្សាមានគុណភាពខ្ពស់ និងឆ្លើយតបនឹងសេដ្ឋកិច្ចនិងសង្គមទាំងមូល មុខងារស្រាវជ្រាវ និងផ្សព្វផ្សាយ ត្រូវប្រចាប់បញ្ចូលគ្នា។

## ៣.៦ ការបន្សុីចំណុចដៅនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ទៅនឹងគោលនយោបាយអប់រំកម្ពុជា

ផ្អែកតាមព័ត៌មានតាមអនុវិស័យអប់រំខាងលើ ផ្នែកនេះមានគោលបំណងធ្វើការវាយតម្លៃដោយសង្ខេបអំពីកម្រិតសង្គតិភាពនៃចំណុចដៅ និងសមាសភាគនានានៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ និងគោលនយោបាយអប់រំជាតិបច្ចុប្បន្ន។ ផ្នែកនេះក៏ពិនិត្យមើលផងដែរពីគម្លាតរវាងចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ និងគោលនយោបាយ និងយុទ្ធសាស្ត្រអប់រំ ព្រមទាំងបង្ហាញពីផ្នែកដែលត្រូវយកចិត្តទុកដាក់។ ជាក់លាក់ជាងនេះទៀត ការវិភាគពីគម្លាតនេះត្រូវពិនិត្យមើលថាតើ ផែនការ និងកម្មវិធីបច្ចុប្បន្ន ត្រូវបានបន្សុីឱ្យស្របទៅតាមចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ទាំងខ្លឹមសារ និងកម្រិតដែលចង់ឱ្យសម្រេចបាន។ ការវិភាគនេះប្រៀបធៀបរវាងផែនការ និងកម្មវិធីដែលមានស្រាប់ជាមួយនឹងចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ រួមនឹងសមាភាគនានានៃចំណុចដៅទាំងនេះផងដែរ។ ការវិភាគនេះបង្ហាញឱ្យឃើញយ៉ាងច្បាស់ថា ទស្សនាទានអប់រំជាច្រើនដែលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ចង់ឱ្យសម្រេច គឺមានស្រាប់រួចហើយនៅក្នុងឯកសារគោលនយោបាយជាច្រើនរបស់កម្ពុជា។ ទោះជាយ៉ាងណា ចំណុចដៅមួយចំនួនដែលពុំទាន់បានគ្របដណ្តប់ដោយការប្រឹងប្រែង និងអន្តរាគមន៍បច្ចុប្បន្ន ហើយចាំបាច់ត្រូវបន្តការប្រឹងប្រែងបន្ថែមទៀតនាឆ្នាំខាងមុខ។

ការបន្សុីរវាងរបៀបវារៈអប់រំសកល និងគោលនយោបាយជាតិ មានវិធីសាស្ត្រច្រើនបែប។ ក្របខណ្ឌដើម្បីសម្រេចគោលបំណងនេះ ត្រូវបានស្នើដូចខាងក្រោម៖

ក. ការបន្ស៊ីផ្នែកទស្សនទាន ៖ ចំណុចនេះពិនិត្យមើលថាតើគោលនយោបាយអប់រំជាតិដែលមានបច្ចុប្បន្នបានគ្របដណ្តប់លើទស្សនទាន ឬ គំនិតផ្តួចផ្តើមអប់រំថ្មីៗដែលបានលើកឡើងនៅក្នុងរបៀបវារៈសកលដែរឬទេ (ឧទាហរណ៍ ភាពជាប្រជាពលរដ្ឋសកលជាដើម)។

ខ. ការបន្ស៊ីផ្នែកអាទិភាព ៖ តើអាទិភាពចម្បងនៃរបៀបវារៈសកលត្រូវបានចាត់ទុក ឬ អនុម័តថាជាអាទិភាពគោលនយោបាយជាតិដែរឬទេ? កម្រិតណា?

គ. ការបន្ស៊ីផ្នែកគោលនយោបាយ ៖ តើការផ្លាស់ប្តូរគោលនយោបាយដែលលើកឡើងដោយរបៀបវារៈសកល (ឧទាហរណ៍ កាតព្វកិច្ចសិក្សា ជាដើម) បានទទួលការយកចិត្តទុកដាក់ហើយឬនៅ?

ឃ. ការបន្ស៊ីផ្នែកសមិទ្ធផល ៖ ចំណុចនេះផ្តោតលើសមិទ្ធផលអប់រំបច្ចុប្បន្នធៀបនឹងចំណុចដៅដែលត្រូវបានលើកស្នើឡើងជាសកល។

ការបន្ស៊ីក្នុងទម្រង់ផ្សេងៗដូចជា ការវិភាគអំពីស្ថានភាពអប់រំត្រូវបានរៀបចំ។ លទ្ធផលនៃការវិភាគបង្ហាញថា ទស្សនទានអប់រំប្រកបដោយគុណភាព សមធម៌ សមភាពយេនឌ័រ បំណិន គ្រូបង្រៀនដែលមានសមត្ថភាពខ្ពស់សុទ្ធតែជាគោលការណ៍សំខាន់ៗដែលមាននៅក្នុងចំណុចដៅគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ផង និងឯកសារគោលនយោបាយបច្ចុប្បន្នរបស់កម្ពុជាផង (ឧទាហរណ៍ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ របាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិជាដើម)។ រីឯកម្រិតទស្សនទាន គឺអាចសង្កេតឃើញពីចំណុចប្រសព្វគ្នាក្នុងកម្រិតមួយខ្ពស់រវាងគោលបំណងគោលនយោបាយអប់រំជាតិ និងគោលបំណងអប់រំកម្រិតសកល។

ចំពោះការកំណត់អាទិភាព កម្ពុជាបានទទួលយកគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ទៅក្នុងគោលបំណងគោលនយោបាយចំនួនពីរនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨។ ដូចមាននៅក្នុងរបាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺគោលនយោបាយទី១ "ធានាការអប់រំឱ្យមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា" សម្រាប់រយៈពេលពាក់កណ្តាលអាណត្តិចុងក្រោយនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវសសរស្តម្ភ ៥ គឺ១) ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ២) ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា សៀវភៅសិក្សា និងការកែលម្អបរិស្ថានសិក្សា ៣) ការដាក់ឱ្យអនុវត្តអធិការកិច្ច ៤) ការពង្រឹងរង្វាយវាយតម្លៃលទ្ធផលសិក្សា មានរូបភាពផ្សេងៗដូចជា ការធ្វើតេស្តរង្វាយតម្លៃថ្នាក់ជាតិ

ថ្នាក់តំបន់ និងអន្តរជាតិ និង៥) ការកំណែទម្រង់ឧត្តមសិក្សា។ ឈរលើមូលដ្ឋាននៃសសរស្តម្ភ ៥នេះ ក្រសួងបានដាក់ចេញនូវវិធានការកំណែទម្រង់ ១៥ ចំណុច រួមមាន ៖ គ្រូបង្រៀន លទ្ធផលសិក្សា ការអប់រំមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ បរិយាកាសសិក្សា ការអប់រំបច្ចេកទេស ការដឹកនាំ និងអភិបាលកិច្ចសាលារៀន។ល។ ខ្លឹមសារនៃការវិភាគស្ថានភាពអប់រំបានបង្ហាញថា មិនមែនចំណុចដៅទាំងអស់ សុទ្ធតែត្រូវបានដាក់អាទិភាពដូចៗគ្នាក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំបច្ចុប្បន្ននេះឡើយ។ ចំណុចដៅមានអាទិភាពខ្ពស់នៅក្នុងអន្តរាគមន៍អប់រំបច្ចុប្បន្នគឺ ៤.១, ៤.២, ៤.៣ និង៤.គ ខណៈពេលដែល ៤.៥, ៤.៤, ៤.៧, ៤.ក និង៤.ខ ចាំបាច់ត្រូវទទួលបានការយកចិត្តទុកដាក់បន្ថែមទៀត។

ការបន្សុីគោលនយោបាយវិញ ចំណុចដៅមួយចំនួននៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ទាមទារនូវការធ្វើកំណែទម្រង់គោលនយោបាយសំខាន់ៗ ដែលអាចនាំឱ្យមានភាពចម្រូងចម្រាស់ផ្នែកនយោបាយ។ ឧទាហរណ៍ កាតព្វកិច្ចសិក្សា រយៈពេល ៩ឆ្នាំ និងកាតព្វកិច្ចសិក្សាមត្តេយ្យសិក្សា ១ ឆ្នាំ។ បញ្ហានេះបង្ហាញយ៉ាងច្បាស់ថា អាទិភាពអប់រំបច្ចុប្បន្ន គឺពុំទាន់មានកម្រិតគ្រប់គ្រាន់ ដើម្បីឆ្លើយតបនឹងការអំពាវនាវនៅកម្រិតសកលនៅឡើយ។ ចំណុចនេះបញ្ជាក់ថា នៅមានគម្លាតដែលទាមទារឱ្យមានការធ្វើកំណែទម្រង់ច្បាប់សំខាន់ៗ។ ការសម្រេចចំណុចដៅដែលពាក់ព័ន្ធនឹងការកំណែទម្រង់គោល-នយោបាយបែបនេះ ទាមទារឱ្យមានការប្រឹងប្រែងបន្ថែមទៀត។ បើគិតពីលទ្ធផលអប់រំដែលកម្ពុជាសម្រេចបាននាពេលបច្ចុប្បន្ន បង្ហាញឱ្យឃើញថាមានចំណុចខ្វះខាតនៅក្នុងផ្នែកជាច្រើន។ ខណៈពេលដែលចំណុចដៅបែបបរិមាណវិស័យពាក់ព័ន្ធនឹងចំណុច ៤.១, ៤.២, ៤.៣, ៤.៦ និង៤.គ ហាក់ដូចជាអាចសម្រេចទៅបាន ឬ កៀកនឹងសម្រេចបាន ចំណុចដៅដទៃទៀត ជាពិសេស ៤.៥, ៤.៤, ៤.៧, ៤.ក និង៤.ខ ទាមទារឱ្យមានការខិតខំប្រឹងប្រែងបន្ថែមទៀត។

ការវាយតម្លៃបែបគុណវិស័យ ក៏ត្រូវបានធ្វើឡើងផងដែរ ដើម្បីបញ្ជាក់ឱ្យបានច្បាស់ពីកម្រិតនៃភាពស្របគ្នារវាងចំណុចដៅនានានៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ និងផ្នែកតូចៗនៃចំណុចដៅទាំងនេះជាមួយនឹងគោលនយោបាយ និងកម្មវិធីអប់រំដែលកំពុងបន្តអនុវត្តនៅក្នុងប្រទេសកម្ពុជា។ តារាងទី៤ បង្ហាញពីលទ្ធផលនៃការវាយតម្លៃនេះ។ តារាងនេះ បង្ហាញពីផ្នែកជាច្រើនដែលបានដោះស្រាយ ឬ បានបន្សុីរួចហើយ ក៏ដូចជាផ្នែកដែលទាមទារឱ្យមានការបន្សុីគ្នាបន្ថែមទៀត។ ដូចបានបង្ហាញខាងលើ ចំណុចដៅជាច្រើននិងសមាសភាគតូចៗ ស្ថិតនៅចន្លោះរវាងបន្សុីបង្គួរនិងបន្សុីផ្នែកខ្លះៗ។

## តារាងទី៣៖ កម្រិតបន្សុីចំណុចដៅនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ឆ្នាំ២០៣០ ទៅនឹងគោលនយោបាយ និងកម្មវិធីអប់រំដែលកំពុងអនុវត្តនៅកម្ពុជា

| ចំណុចដៅ | ចំណុចដៅរង | បន្សុីបានទាំងស្រុង | បន្សុីបានបង្គួរ | បន្សុីបានផ្នែកខ្លះៗ | ត្រូវការបន្សុីគ្នា |
|---|---|---|---|---|---|
| ៤.១ | ការអប់រំសាធារណៈដោយមិនគិតថ្លៃរយៈពេល ១២ ឆ្នាំ | √ | | | |
| | កាតព្វកិច្ចសិក្សារយៈពេល ៩ឆ្នាំ | | | | √ |
| | ការបញ្ចប់ភូមិសិក្សាដោយសម្រេចបានលទ្ធផលសិក្សា | | | √ | |
| | ការលុបបំបាត់គម្លាតយេនឌ័រ | | √ | | |
| ៤.២ | ការទទួលបានការគាំពារ និងអប់រំកុមារតូច | | √ | | |
| | ការអប់រំមត្តេយ្យសិក្សាដោយមិនគិតថ្លៃរយៈពេលមួយឆ្នាំ | | √ | | |
| | កាតព្វកិច្ចសិក្សាសម្រាប់មត្តេយ្យសិក្សា | | | | √ |
| ៤.៣ | ការចូលរៀនអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | | √ | | |
| | ការអប់រំឧត្តមសិក្សា | | √ | | |
| | ការសិក្សាពេញមួយជីវិតសម្រាប់យុវជន និងមនុស្សពេញវ័យ | | | √ | |
| | ការកាត់បន្ថយគម្លាតរវាងការសិក្សា និងទីផ្សារការងារ | | | √ | |
| | ការចូលរៀនឧត្តមសិក្សាសម្រាប់មនុស្សពេញវ័យប្រកបដោយសមធម៌ | | | | √ |
| ៤.៤ | ការទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | | √ | | |
| | ការទទួលបានបំណិនដែលអាចប្រើប្រាស់គ្រប់កាលៈទេសៈដូចជា ជំនាញធ្វើការជាក្រុម ប្រាស្រ័យទាក់ទង ដោះស្រាយបញ្ហា។ល។ | | | √ | |
| ៤.៥ | គម្លាតយេនឌ័រនៅគ្រប់កម្រិត | √ | | | |
| | ការលុបបំបាត់ឧបសគ្គសម្រាប់ក្រុមដែលងាយរងគ្រោះ | | √ | | |

| | | | | | |
|---|---|---|---|---|---|
| ៤.៦ | ភាពស្ទាត់ជំនាញខាងអក្ខរកម្មវិជ្ជាជីវៈ និង លេខនព្វន្ត | | √ | | |
| ៤.៧ | ការធ្វើសមាហរណកម្មពេញលេញនៃ ការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយ ចីរភាព និងការអប់រំភាពជាពលរដ្ឋសកល | | | √ | |
| ៤.ក | សម្ភាររូបវន្តអប់រំគ្រប់គ្រាន់ | | √ | | |
| | ការលុបបំបាត់អំពើហិង្សា ការបៀតបៀន និងការរំលោភបំពាន | | | √ | |
| ៤.ខ | ការបង្កើនជំនួយសម្រាប់អាហាររូបករណ៍ | | | | NA |
| | ការបង្កើនចំនួនអ្នកជួបការលំបាក ដែល ទទួលបានសេវា | | √ | | |
| ៤.គ | គ្រូដែលមានគុណវុឌ្ឍិ និងបានទទួលការ បណ្តុះបណ្តាល | | √ | | |
| | ការបង្រៀនជាជម្រើសទីមួយ ដែល ទាក់ទាញ | | √ | | |
| | កិច្ចពិគ្រោះយោបល់គោលនយោបាយ រវាងរដ្ឋាភិបាល និងសហជីព | | | √ | |

## ៣.៧ សមិទ្ធផលអប់រំកម្ពុជា ៖ ទស្សនវិស័យប្រៀបធៀប

ផ្នែកនេះ គឺការប្រៀបធៀបសមិទ្ធផលអប់រំកម្ពុជា ជាមួយនឹងសមិទ្ធផលអប់រំរបស់ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ តាមរយៈការប្រើប្រាស់សូចនាករជាច្រើន។ ដូចបានបង្ហាញនៅក្នុងតារាងទី៣ កម្ពុជាសម្រេចបានលទ្ធផលយ៉ាងល្អប្រសើរពាក់ព័ន្ធនឹងអត្រាពិតនៃការសិក្សានៅបឋមសិក្សា និងអត្រាគង់វង្សថ្នាក់កម្រិតចុងក្រោយនៃបឋមសិក្សា។ កម្ពុជាមានអត្រាពិតនៃការសិក្សា ៩៨ ភាគរយ ខណៈពេលដែលសម្រាប់ប្រទេសចំណូលមធ្យម អត្រានេះមានត្រឹមតែ ៩៦ ភាគរយ ប៉ុណ្ណោះ ហើយអត្រាគង់វង្សថ្នាក់ចុងក្រោយនៃបឋមសិក្សាជិតស្មើគ្នា។ ចំពោះសូចនាករបីផ្សេងទៀតដូចជា អត្រាពិតនៃការសិក្សា អត្រារួមនៃការសិក្សានៅមត្តេយ្យសិក្សា និងអត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ សម្រាប់ប្រទេសចំណូលមធ្យមកម្រិតខ្ពស់ មានកម្រិតខ្ពស់ជាងកម្ពុជា។ ដូចនេះ កម្ពុជាចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់ន្ថែមទៀត ជាពិសេស ត្រូវបង្កើនអត្រានៃការចូលរៀននៅមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។ ការចូលរៀន កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា ក៏មានកម្រិតទាបផងដែរ បើគិតជាភាគរយនៃចំនួនសិស្សសរុបដែលបានចូលរៀននៅមធ្យមសិក្សា។ ក្នុង

ចំណោមសិស្សសរុបដែលចូលរៀននៅមធ្យមសិក្សាមានតែ ២ ភាគរយ ប៉ុណ្ណោះ ដែលកំពុងរៀនក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈធៀបនឹងជិត ១៨ ភាគរយ នៅអាស៊ីប៉ាស៊ីហ្វិក ឬ ១០ ភាគរយ ក្នុងប្រទេសដែលចំណូលមធ្យមកម្រិតខ្ពស់។

### តារាងទី៤៖ ការប្រៀបធៀបសូចនាករមួយចំនួនរបស់កម្ពុជា និងប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់

| សូចនាករ | កម្ពុជា បច្ចុប្បន្ន (%) | ប្រទេសចំណូលមធ្យមកម្រិតខ្ពស់បច្ចុប្បន្ន (%) | ចំណុចដៅនៃការអប់រំ ២០៣០ (%) |
|---|---|---|---|
| អត្រាពិតនៃការសិក្សា (មួយឆ្នាំមុនអាយុចូលរៀនបឋមសិក្សាជាផ្លូវការ) | ៦៦,៣៥ | ៧៧,៧៥ | ១០០ |
| អត្រារួមនៃការសិក្សានៅមត្តេយ្យសិក្សា | ៤១,០ | ៧៣,៧៤ | ១០០ |
| អត្រាពិតនៃការសិក្សានៅបឋមសិក្សា | ៩៧,៧ | ៩៥,៤៩ | ១០០ |
| អត្រាគង់វង្សថ្នាក់ចុងក្រោយនៃបឋមសិក្សា | ៧៨,៧ | ៧៩,៣២ | ១០០ |
| អត្រាពិតនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ៤១,៩ | ៩៣,០៣ | ១០០ |
| អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | ២៦,៥ | ៦៣,៦៦ | ១០០ |
| អត្រារួមនៃការសិក្សានៅឧត្តមសិក្សា | ១៤,០ | ៤៣,៨៥ | |
| ភាគរយសិស្សចូលរៀនក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈធៀបនឹងចំនួនសិស្សដែលបានចូលរៀននៅមធ្យមសិក្សា | ២,០ | ១០,០២ (១៧,៥% អាស៊ីប៉ាហ្វីក) | |

ទោះបី មានភាពប្រសើរឡើងថ្មីៗនេះក៏ដោយ កម្ពុជានៅមិនទាន់ទទួលបានថវិកាគ្រប់គ្រាន់សម្រាប់ចំណាយអប់រំសាធារណៈនៅឡើយ ហើយការចំណាយក្នុងសិស្សម្នាក់គឺត្រឹមតែ ២២៧ ដុល្លារអាមេរិកប៉ុណ្ណោះនៅកម្ពុជា ធៀបនឹង ១ ២០០ដុល្លារអាមេរិកនៅអាស៊ីប៉ាហ្វិច (តារាងទី៥)។ ចំណាយសិស្សម្នាក់នៅកម្ពុជាសម្រាប់បឋមសិក្សា គិតជាមធ្យម គឺ ២០៨ដុល្លារ ខណៈពេលដែលនៅវៀតណាមចំណាយ ១ ២០៧ ដុល្លាររអាមេរិកនិង ៣ ៥៦៤ ដុល្លារអាមេរិកនៅថៃ។ រីឯមធ្យមសិក្សាបឋមភូមិវិញចំណាយសម្រាប់សិស្សម្នាក់នៅកម្ពុជា គឺកើនដល់ ៤៦៧ ដុល្លារអាមេរិក ប៉ុន្តែចំណាយនៅវៀតណាមខ្ពស់ជាងកម្ពុជា៣ដង ហើយចំណាយនៅថៃខ្ពស់ជាងដល់ទៅ ៥ដង។

**តារាងទី៥៖ ការប្រៀបធៀបចំណាយសម្រាប់វិស័យអប់រំកម្ពុជា និងប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់**

| សូចនាករ | កម្ពុជា ២០១៦ | ប្រទេសចំណូលខ្ពស់មធ្យមបច្ចុប្បន្ន | គោលដៅអប់រំ ២០៣០ |
|---|---|---|---|
| % នៃចំណាយថវិកាអប់រំសាធារណៈនៃ ផ.ស.ស | ២,៣% | ៣,៧២% | ៤ ទៅ ៦% នៃ ផ.ស.ស. |
| ចំណាយវិស័យអប់រំគិតជា % នៃចំណាយសរុបរបស់រដ្ឋាភិបាល | ១៨,៣% | ១៣,៧% | ១៥% ទៅ ២០% |
| ចំណាយក្នុងសិស្សម្នាក់នៅកម្រិតបឋមសិក្សា | ២១៧,២ | ១ ២០០,៧ | |

ខណៈពេលដែលកម្ពុជា មានមហិច្ឆតាប្រែក្លាយទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០ ចាំបាច់ត្រូវតែកសាងនូវកម្លាំងពលកម្មដែលមានជំនាញកម្រិតខ្ពស់និងអាចប្រកួតប្រជែងជាមួយនឹងប្រទេសដទៃទៀតនៅអាស៊ាន និងពិភពលោក។ ដូចនេះ កម្ពុជាត្រូវការប្រព័ន្ធអប់រំមួយដ៏រឹងមាំ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រភេទផ្សេងមួយទៀត។ កម្ពុជាចាំបាច់ត្រូវបង្កើនភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព គុណភាព និងសមធម៌នៃប្រព័ន្ធអប់រំ ដើម្បីរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចប្រភេទផ្សេងមួយទៀត។ ជំពូកបន្ទាប់ រៀបរាប់ពីចក្ខុវិស័យ អាទិភាពគោលនយោបាយ និងយុទ្ធសាស្ត្រ ដែលកម្ពុជាត្រូវដាក់ចេញ ដើម្បីសម្រេចគោលបំណងនៃការអភិវឌ្ឍទាំងនេះ។

## ៤.  ចក្ខុវិស័យ អាទិភាពគោលនយោបាយ និងយុទ្ធសាស្ត្រវិស័យអប់រំ

### ៤.១  ទស្សនវិស័យនៃការអភិវឌ្ឍរបស់កម្ពុជា

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (២០១៤-២០១៨) និងដំណាក់កាលទី៤ (២០១៨-២០២៣) បានដាក់ចេញនូវចក្ខុវិស័យសេដ្ឋកិច្ច សង្គមកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកកម្ពស់ពីឋានៈនៃប្រទេសចំណូលទាបទៅប្រទេសចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០។ ក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ គឺមនុស្សត្រូវបានចាត់ទុកជាអាទិភាពខ្ពស់ បន្ទាប់មក ផ្លូវ ភ្លើង និងទឹក ហើយដំណាក់កាលទី៤ រាជរដ្ឋាភិបាលបានសម្រេចបន្តអាទិភាពទាំងបួនដដែល ដោយកំណត់យកមនុស្សជាអាទិភាពទី១។ គោលដៅយុទ្ធសាស្ត្រ ៤យ៉ាង គឺ **កំណើន ការងារ សមធម៌** និង**ប្រសិទ្ធភាព** ក្នុងគោលបំណងសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចយ៉ាងហោចណាស់ ៧ ភាគរយ ជារៀងរាល់ឆ្នាំ បង្កើតការងារឱ្យបានកាន់តែច្រើនឡើងៗសម្រាប់យុវជន កាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង ១ ភាគរយក្នុងមួយឆ្នាំ និងពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័ន និងការលើកកម្ពស់សេវាសាធារណៈ។ យុទ្ធសាស្ត្រចតុកោណ គឺជាឯកសារមគ្គុទ្ទេសក៏ច្បាស់លាស់សម្រាប់ "តម្រែតម្រង់សកម្មភាពរបស់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងគោលដៅបន្តនិងពង្រឹងកិច្ចអភិវឌ្ឍប្រកបដោយចីរភាពសម្រាប់រយៈពេលវែង សំដៅជំរុញកំណើនសេដ្ឋកិច្ច បន្តបង្កើតការងារ បែងចែកផលនៃកំណើនសេដ្ឋកិច្ចប្រកបដោយសមធម៌ និងធានាឱ្យបាននូវប្រសិទ្ធភាពនៃស្ថាប័នសាធារណៈ និងការគ្រប់គ្រងធនធានគ្រប់ប្រភេទ"។ អភិបាលកិច្ចល្អជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ និងជាអាទិភាពសម្រាប់ដំណាក់កាលទី៣ រួមមាន ៖ ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។ វិស័យជាអាទិភាព ៤ នឹងតម្រង់ទិសការខិតខំប្រឹងប្រែងអភិវឌ្ឍន៍ប្រទេស ដើម្បីឈានទៅសម្រេចគោលដៅខាងលើ រួមមាន (ក) ការលើកស្ទួយវិស័យកសិកម្ម (ខ) ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត (គ) ការអភិវឌ្ឍវិស័យឯកជន និងការងារ (ឃ) ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស។ ជារួម យុទ្ធសាស្ត្រទាំងនេះចង់ឱ្យប្រទេសកម្ពុជា ជាប្រទេសប្រកបដោយវិបុលភាពនិងមានខឿនសេដ្ឋកិច្ចរឹងមាំដែលត្រូវបានធ្វើពិពិធកម្ម រស់រវើក និងមានភាពធន់។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និង ២០១៩-២០២៣ បានដាក់ចេញនូវក្របខណ្ឌអភិវឌ្ឍន៍ និងផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងទី៤ និងបានបង្ហាញផងដែរនូវការប្តេជ្ញាចិត្តកម្រិតនយោបាយរបស់រដ្ឋាភិបាល ក្នុងការប្រែក្លាយបំណងប្រាថ្នាអភិវឌ្ឍន៍ឱ្យក្លាយទៅជាការពិត។ ដូចបានលើកឡើងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨គោលបំណងរួមរបស់រាជរដ្ឋាភិបាលកម្ពុជាគឺ "ថែរក្សាការពារសន្តិភាព ស្ថិរភាពនយោបាយ

សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម សម្រាប់លើកកម្ពស់ការអនុវត្តច្បាប់ និងការគោរពសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ គោរពគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស មានកំណើនសេដ្ឋកិច្ចរយៈពេលវែង និងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ”។ ដោយផ្អែកលើសមិទ្ធផលសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ បានកំណត់តម្រូវការចាំបាច់ក្នុងការបន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្សដែលជាផ្នែកអាទិភាពខ្ពស់ក្នុងចំណោមផ្នែកទាំង ៦។

គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ មានគោលបំណងជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ដែលរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។ គោលនយោបាយនេះ មានគោលបំណងកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជាពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ តាមរយៈភ្ជាប់ខ្សែចង្វាក់តម្លៃសកល សមាហរណកម្មទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡាគ្នា ទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក។ គោលនយោបាយនេះ ក៏មានបំណងអភិវឌ្ឍឧស្សាហកម្មទំនើបដែលផ្អែកជាសំខាន់លើមូលដ្ឋានបច្ចេកវិទ្យា និងចំណេះដឹង។ ក្នុងនោះ មានយុទ្ធសាស្ត្រមួយបានផ្តោតលើការអភិវឌ្ឍធនធានមនុស្ស និងការបណ្តុះបណ្តាលបច្ចេកទេស។ ជំនាញ និងបច្ចេកវិទ្យាមនុស្ស គឺមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការធ្វើសមាហរណកម្មឱ្យកាន់តែស៊ីជម្រៅរបស់កម្ពុជាទៅក្នុងតំបន់អាស៊ាន។

រាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ថា កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ច មិនអាចកាត់ផ្តាច់បានពីការប្រែប្រួលអាកាសធាតុឡើយ។ ការប្រឹងប្រែងឆ្លើយតបនឹងបញ្ហាប្រឈមសម្រាប់ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច និងសង្គម បម្រែបម្រួលអាកាសធាតុ គួរតែជាកត្តាសំខាន់ដែលត្រូវយកមកធ្វើការពិចារណា។ ក្នុងបរិបទនេះ ផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុកម្ពុជាឆ្នាំ២០១៤-២០២៣ មានគោលបំណងអភិវឌ្ឍកម្ពុជាឆ្ពោះទៅរកសង្គមមួយដែលបៃតងបញ្ចេញកាបូនតិច ធន់នឹងការប្រែប្រួលអាកាសធាតុ សមធម៌ ចីរភាព និងពឹងផ្អែកលើចំណេះដឹងជាគោល។

ឯកសារគោលនយោបាយជាច្រើនទាំងនេះចាត់ទុកថា វិស័យអប់រំជាវិស័យដ៏សំខាន់ក្នុងការដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងការអភិវឌ្ឍ។ តួនាទីវិស័យអប់រំ ជាចលករសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច កំណើនឧស្សាហកម្ម និងឧបករណ៍ ដើម្បីផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋក្រីក្រត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ។ សរុបមក ចក្ខុវិស័យរយៈពេលវែង គឺចង់ប្រែក្លាយកម្ពុជា ជាប្រទេសប្រកបដោយវិបុលភាព និងមានសមត្ថភាពប្រកួតប្រជែងលើឆាកអន្តរជាតិ មានសេដ្ឋកិច្ចដែលមាន

ភាពរស់រវើក ដោយមានការគាំទ្រពីកម្លាំងពលកម្មដែលមានសមត្ថភាព និងមានជំនាញ។ សមាសភាគស្នូលមួយនៃចក្ខុវិស័យនេះ គឺពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានមនុស្ស និងការបង្កើតសេដ្ឋកិច្ចពុទ្ធិ។ វិស័យអប់រំមានតួនាទីយ៉ាងសំខាន់ក្នុងការធានាឱ្យសម្រេចបាននូវបំណងប្រាថ្នាទាំងនេះ។

**ទស្សនវិស័យនៃការអភិវឌ្ឍរបស់កម្ពុជា**

គឺក្លាយជាប្រជាជាតិដែលមានចំណូលមធ្យមកម្រិតខ្ពស់ ប្រកបដោយវិបុលភាពត្រឹមឆ្នាំ ២០៣០។

ដើម្បីក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសដែលមានចំណូលខ្ពស់ ក្នុងឆ្នាំ២០៥០ និងប្រែក្លាយប្រទេសនេះទៅជាសង្គមពុទ្ធិ ប្រកបដោយសុខសន្តិភាព និងលទ្ធិប្រជាធិបតេយ្យ ដែលកាន់តែមានសមត្ថភាពប្រកួតប្រជែងនៅថ្នាក់តំបន់ និងអន្តរជាតិ។

## ៤.២ គោលបំណងនៃការអប់រំជាតិ

ប្រព័ន្ធអប់រំកម្ពុជាចង់សម្រេចគោលបំណងដូចខាងក្រោម ៖

១. បណ្ដុះមនសិការស្នេហាជាតិ មានស្មារតីទទួលខុសត្រូវ ស្មោះត្រង់ និងមោទនភាពជាតិ តាមរយៈការលើកកម្ពស់ការប្រកាន់នូវគំនិត គុណតម្លៃ បំណងប្រាថ្នារួមគ្នា ដើម្បីបង្កើតបាននូវសាមគ្គីភាពជាតិ និងអត្តសញ្ញាណជាតិ។

២. ផ្ដល់ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយដល់អ្នកសិក្សា ដើម្បីទទួលបានតុល្យភាពរវាងការអភិវឌ្ឍកាយសម្បទា បញ្ញា អារម្មណ៍ សោភណ្ឌភាព និងស្មារតី។

៣. ផលិតធនធានមនុស្សដែលមានចំណេះដឹង បំណិន និងសមត្ថភាព ដែលស្របទៅតាមតម្រូវការទីផ្សារការងារសម្រាប់សេដ្ឋកិច្ចពុទ្ធិប្រកបដោយពិពិធភាព ដែលអាចប្រកួតប្រជែងនៅថ្នាក់តំបន់ និងសកលលោក។

៤. រៀបចំអ្នកសិក្សាពេញមួយជីវិត ដើម្បីឱ្យពួកគេអាចចូលរួមក្នុងពិភពលោក ដែលមានទំនាក់ទំនងជាមួយគ្នា និងពឹងអាស្រ័យគ្នាទៅវិញទៅមក និងអាចធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលលោក ដើម្បីបង្កើតនូវពិភពលោកមួយឱ្យកាន់តែមានសុខសន្តិភាព និងប្រកបដោយចីរភាព។

## ៤.៣ ចក្ខុវិស័យវិស័យអប់រំ

ប្រព័ន្ធអប់រំមួយដ៏រឹងមាំ គឺជាមូលដ្ឋានគ្រឹះសម្រាប់ប្រជាជាតិមួយប្រកបដោយវិបុលភាព។ ឯកសារគោលនយោបាយកម្ពុជាបានទទួលស្គាល់ថា វិស័យអប់រំបំពេញតួនាទីយ៉ាងសំខាន់នៅក្នុងការប្រែក្លាយពីប្រទេសដែលមានចំណូលទាបទៅប្រទេសចំណូលមធ្យមកម្រិតខ្ពស់ និងសម្រេចបានឋានៈជាប្រទេសអភិវឌ្ឍន៍ប្រកបដោយសន្តិភាព បរិយាបន្ន និងលទ្ធិប្រជាធិបតេយ្យ។ ដើម្បីសម្រេចទស្សនវិស័យនេះ កម្ពុជាត្រូវមានប្រព័ន្ធអប់រំដ៏រឹងមាំ។ ចំណុចដៅ និងអាទិភាពអប់រំសម្រាប់ឆ្នាំ២០៣០ត្រូវបានកំណត់ដោយមានការពិភាក្សាថាតើសមាសភាគនីមួយៗនៃប្រព័ន្ធអប់រំគួរតែមានលក្ខណៈយ៉ាងដូចម្តេចនៅឆ្នាំ ២០៣០ និងក្រោយឆ្នាំ២០៣០។ ចក្ខុវិស័យជាបន្តបន្ទាប់ខាងក្រោមនេះ ត្រូវបានរៀបចំយ៉ាងហ្មត់ចត់តាមរយៈការពិនិត្យដោយល្អិតល្អន់លើឯកសារគោលនយោបាយជាច្រើន និងការពិភាក្សាជាមួយអ្នករៀបចំគោលនយោបាយ និងអ្នកអនុវត្តការងារដោយផ្ទាល់។

### *ក. ចក្ខុវិស័យសម្រាប់ប្រព័ន្ធអប់រំកម្ពុជាឆ្នាំ២០៣០*

ប្រព័ន្ធអប់រំកម្ពុជាឆ្នាំ២០៣០ គឺរឹងមាំ និងមានសមត្ថភាពប្រកួតប្រជែងថ្នាក់តំបន់សម្រាប់សង្គមពុទ្ធិ។

ចក្ខុវិស័យអប់រំជាតិ គឺរួមចំណែកបង្កើតនូវសង្គមពុទ្ធិ តាមរយៈការអភិវឌ្ឍធនធានមនុស្សដែលមានចំណេះដឹង និងសមត្ថភាព សម្បទាគ្រប់គ្រាន់ ជំនាញ ភាពច្នៃប្រឌិត នវានុវត្តន៍ ស្មារតីសហគ្រិនភាព និងក្រមសីលធម៌ខ្ពស់ ព្រមទាំងចងចាំជានិច្ចនូវបំណងប្រាថ្នារបស់ជាតិដើម្បីមានឯកភាពនិងសាមគ្គីភាពគ្នាជាធ្លុងមួយក្នុងប្រទេស។ កម្ពុជាមានគោលបំណងអភិវឌ្ឍប្រព័ន្ធអប់រំមួយដែលមានធនធានគ្រប់គ្រាន់ មានអភិបាលកិច្ចល្អ និងមានគុណភាព ដោយចាត់ទុកថា សមធម៌ បរិយាបន្ន ប្រសិទ្ធភាព និងស្តង់ដាគុណភាពខ្ពស់ ជាគោលការណ៍សំខាន់ៗរបស់ខ្លួន។ កម្ពុជានឹងជាប្រទេសដែលប្រជាពលរដ្ឋរបស់ខ្លួនមានការលើកទឹកចិត្ត និងមានសមត្ថភាព ក្លាយជាអ្នកសិក្សាពេញមួយជីវិត។ ដើម្បីសម្រេចគោលដៅនេះ កម្ពុជាត្រូវធ្វើកំណែទម្រង់ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយទូទាំងវិស័យ ដោយអនុវិស័យនីមួយៗ និងសមាសភាគទាំងអស់នៃប្រព័ន្ធអប់រំ នឹងត្រូវរៀបចំឡើងឱ្យឆ្លើយតបនឹងតម្រូវការនៃការសិក្សាពេញមួយជីវិតនៅគ្រប់ដំណាក់កាលទាំងអស់នៃជីវិត។ ក្នុងន័យនេះ គឺបង្កើតនូវឱកាសក្នុងការសិក្សាគ្រប់បរិបទ និងទម្រង់ (ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ)សម្រាប់ប្រជាពលរដ្ឋគ្រប់វ័យទាំងអស់។

### ខ. ចក្ខុវិស័យសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា

ចក្ខុវិស័យសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា គឺជាក្រសួងដែលមានឧត្តមភាពក្នុងការផ្តល់នូវការអប់រំ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ប្រកបដោយគុណភាព ដើម្បីក្លាយជាចលករក្នុងការឈានទៅសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច។

ក្រសួងអប់រំ យុវជន និងកីឡា នឹងក្លាយជាក្រសួងដែលមានសមត្ថភាពវិជ្ជាជីវៈក្នុងការបំពេញមុខងារទាំងផ្នែកបច្ចេកទេស (ឧទាហរណ៍ ការរៀបចំផែនការ ការពិនិត្យតាមដាន ការអភិវឌ្ឍកម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូ ការវាយតម្លៃ) ក៏ដូចជា មុខងារអភិបាលកិច្ចវិស័យ (ឧទាហរណ៍ គ្រប់គ្រង)។ សមត្ថភាពទាំងនេះនឹងត្រូវអភិវឌ្ឍ ដើម្បីឱ្យក្រសួងអាចរៀបចំ និងអនុវត្តគោលនយោបាយ ផែនការអប់រំ រៀបចំគោលបំណង និយាម និងស្តង់ដាសម្រាប់គ្រប់កម្រិត និងគ្រប់សមាសភាគនៃការអប់រំ និងសម្របសម្រួលការគ្រប់គ្រងកំណែទម្រង់ដែលជាធាតុផ្សំផ្សេងៗនៃវិស័យអប់រំ (រដ្ឋបាល កិច្ចការសិក្សាធិការ ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស)។ ក្រសួងរៀបចំទិសដៅនៃការអភិវឌ្ឍវិស័យអប់រំ ហើយធានាឱ្យបាននូវអភិបាលកិច្ចល្អសម្រាប់អ្នកផ្តល់សេវាអប់រំទាំងអស់ និងពិនិត្យតាមដានលទ្ធផលនៃប្រព័ន្ធអប់រំ ដើម្បីសម្រេចឱ្យបាននូវគោលបំណងនៃការអប់រំរបស់ប្រទេស។ ប្រព័ន្ធនេះ មានគោលបំណងធានាឱ្យបាននូវភាពប្រសើរឡើងលើការទទួលសេវាប្រកបដោយសមធម៌ គុណភាព និងភាពឆ្លើយតប ក៏ដូចជាអភិបាលកិច្ច និងការគ្រប់គ្រងគ្រឹះស្ថានអប់រំគ្រប់ប្រភេទទាំងអស់នៅគ្រប់កម្រិតថ្នាក់។

### គ. ចក្ខុវិស័យរបស់សាលារៀនកម្ពុជា ឆ្នាំ ២០៣០

សាលារៀន គឺជាគ្រឹះស្ថានសិក្សា ដែលធានាបាននូវការអប់រំប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។

សាលារៀនទាំងអស់នឹងមានស្វ័យភាពផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងមានគណនេយ្យភាពក្នុងការសម្រេចបាននូវលទ្ធផលសិក្សាប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។ សាលារៀននឹងទទួលបានគ្រូបង្រៀនដែលមានសមត្ថភាពវិជ្ជាជីវៈ និងការលើកទឹកចិត្ត ហើយមានអ្នកដឹកនាំការងារបង្រៀនប្រកបដោយចក្ខុវិស័យ និងផ្តល់នូវបរិយាកាសប្រកបដោយសុវត្ថិភាព អនាម័យ ឆ្លើយតបចំពោះយេនឌ័រ បរិយាបន្ន និងការរៀននិងបង្រៀនប្រកបដោយគុណភាពខ្ពស់ ដោយប្រើប្រាស់បច្ចេកវិទ្យាជាជំនួយ។

### ឃ. ចក្ខុវិស័យសម្រាប់គ្រូបង្រៀនកម្ពុជា ឆ្នាំ ២០៣០

គ្រូបង្រៀនកម្ពុជា មានសមត្ថភាព ទទួលបានការលើកទឹកចិត្ត និងទទួលបានការគាំទ្រគ្រប់គ្រាន់ ដើម្បីជួយគាំទ្រដល់អ្នកសិក្សាឱ្យទទួលបានការអប់រំប្រកបដោយគុណភាពខ្ពស់។

ប្រព័ន្ធអប់រំកម្ពុជានឹងមានគ្រូបង្រៀនដែលមានសមត្ថភាពវិជ្ជាជីវៈ ទទួលបានការលើកទឹកចិត្ត ទទួលបានការគាំទ្រ និងការបំប៉នចំណេះដឹងមុខវិជ្ជាជំនាញគ្រប់គ្រាន់ ព្រមទាំងជំនាញគរុកោសល្យ និងស្រលាញ់ការងារបង្រៀន និងសិស្សានុសិស្សរបស់ខ្លួន។ វិជ្ជាជីវៈគ្រូបង្រៀននឹងត្រូវបានលើកកម្ពស់ ដើម្បីឱ្យវិជ្ជាជីវៈនេះអាចទាក់ទាញ និងរក្សាបាននូវមនុស្សដែលមានគុណវុឌ្ឍិខ្ពស់បំផុត និងមានទឹកចិត្តបំពេញការងារបានល្អ។ គ្រូបង្រៀននឹងទទួលបានការគាំទ្រជាប្រចាំ ដើម្បីឱ្យពួកគេអាចអភិវឌ្ឍចំណេះដឹង និងសមត្ថភាពសម្រាប់លើកកម្ពស់ការសិក្សារៀនសូត្ររបស់សិស្ស។ ការបង្រៀន គឺជាវិជ្ជាជីវៈប្រកបដោយក្រមសីលធម៌ ក្នុងនោះ គ្រូបង្រៀនត្រូវបំពេញការងារប្រកបដោយស្តង់ដាវិជ្ជាជីវៈ និងសីលធម៌ខ្ពស់បំផុត ដើម្បីធានាឱ្យសិស្សគ្រប់រូបរបស់ខ្លួនអាចទទួលបានជោគជ័យ។

### ង. ចក្ខុវិស័យសម្រាប់បន្ទប់រៀនកម្ពុជា ឆ្នាំ ២០៣០

បន្ទប់រៀនកម្ពុជា ជាបន្ទប់រៀនវៃឆ្លាត ដែលផ្តល់ឱ្យសិស្សនូវឱកាសល្អបំផុតសម្រាប់ការរៀនសូត្រ។

បន្ទប់រៀនកម្ពុជាត្រូវប្រែក្លាយជាបណ្តើរៗទៅជាបន្ទប់រៀនវៃឆ្លាត ដោយបំពាក់ធនធានអប់រំ និងបច្ចេកវិទ្យា ដើម្បីផ្តល់នូវបរិយាកាសសិក្សាដែលមានការរៀបចំដោយប្រយ័ត្នប្រយែង មានសុវត្ថិភាព និងមានលក្ខណៈអំណោយផលសម្រាប់ការសិក្សាសម្រាប់ទាំងអស់គ្នា។ គ្រូបង្រៀននឹងប្តូរតួនាទីទៅជាអ្នកសម្របសម្រួលការរៀនសូត្រ ដោយបំពេញតួនាទីជាអ្នកបង្កើតឱកាសរៀនសូត្រសម្រាប់ទាំងអស់គ្នា តាមរយៈការប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបែបអន្តរកម្ម និងបែបសហការ និងវិធីសាស្ត្រចម្រុះ។

### ច. ចក្ខុវិស័យសម្រាប់សិស្សកម្ពុជា ឆ្នាំ ២០៣០

សិស្ស មានសុខភាពល្អ មានការលើកទឹកចិត្ត និងមានការប្តេជ្ញាចិត្តៈ អនាគតរបស់កម្ពុជា។

កម្ពុជានឹងមានសិស្សដែលមានសុខភាពល្អ ត្រៀមខ្លួនបានល្អ និងទទួលបានការលើកទឹកចិត្ត ក៏ដូចជាការប្តេជ្ញាចិត្តសិក្សារៀនសូត្រ ដោយមិនប្រកាន់ពីសាវតារខ្លួន និងទទួលបានបរិយាកាសសិក្សាដែលមានលក្ខណៈអំណោយផល។ សិស្សនឹងទទួលបានការគាំទ្រពីគ្រូបង្រៀនដែលមានសមត្ថភាព និងគុណវុឌ្ឍិវិជ្ជាជីវៈ ក៏ដូចជាពីសំណាក់សមាជិកគ្រួសារ និងសហគមន៍របស់ពួកគេ។ បន្ទាប់ពីបញ្ចប់ការសិក្សា ពួកគេនឹងមានជំនាញទាំងរឹង ទាំងទន់ ចេះធ្វើការវិនិច្ឆ័យ ប្រកបដោយក្រមសីលធម៌បានល្អ

មានភាពវៃឆ្លាតខាងអារម្មណ៍ ក៏ដូចជាមានស្មារតីជាតិ និងភាពជាប្រជាពលរដ្ឋសកលក្នុងកម្រិតមួយខ្ពស់ ដែលផ្តល់លទ្ធភាពឱ្យពួកគេអាចរួមចំណែក និងចូលរួមក្នុងសង្គមយ៉ាងសកម្ម។

## ៤.៤ គោលដៅរួមនៃផែនទីបង្ហាញផ្លូវសម្រាប់ការអប់រំឆ្នាំ ២០៣០

គោលដៅរួម គឺធានាឱ្យមានការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

## ៤.៥ អាទិភាពគោលនយោបាយសម្រាប់ឆ្នាំ ២០៣០

ផ្នែកនេះ បង្ហាញពីអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងវិស័យអប់រំសម្រាប់ឆ្នាំ ២០១៨ ដល់ ២០៣០។ ផ្នែកនេះក៏បង្ហាញពីលទ្ធផលដែលត្រូវសម្រេចតាមអាទិភាពនីមួយៗផងដែរ។ លទ្ធផលនីមួយៗ រៀបរាប់លម្អិតពីយុទ្ធសាស្រ្តដែលត្រូវអនុវត្ត។ អាទិភាពគោលនយោបាយ ៥ ត្រូវបានដាក់ចេញសម្រាប់ឆ្នាំ២០៣០ ផ្អែកតាមការពិនិត្យយ៉ាងហ្មត់ចត់លើចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ក៏ដូចជាការពិនិត្យឡើងវិញលើគោលនយោបាយ និងកម្មវិធីដែលបាននិងកំពុងអនុវត្តក្នុងវិស័យអប់រំ ព្រមទាំងការពិគ្រោះយោបល់ជាមួយនឹងអង្គភាពពាក់ព័ន្ធនានា។ ផ្នែកនេះបង្ហាញពីអាទិភាពគោលនយោបាយ លទ្ធផល យុទ្ធសាស្រ្ត និងសកម្មភាពតាមអាទិភាពនីមួយៗ។

**អាទិភាពទី ១ ៖** កុមារី និងកុមារាគ្រប់រូប ទទួលបានការគាំពារនិងការអប់រំកុមារតូច និងការអប់រំមត្តេយ្យសិក្សាប្រកបដោយគុណភាព និងបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន (បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) ដោយឥតបង់ថ្លៃ ប្រកបដោយសមធម៌ និងគុណភាព ដែលទទួលបានលទ្ធផលសិក្សាប្រកបដោយប្រសិទ្ធភាព និងភាពឆ្លើយតប។

**អាទិភាពទី ២ ៖** កុមារី និងកុមារាទាំងអស់ បញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិដោយទទួលបានលទ្ធផលសិក្សានិងភាពឆ្លើយតប ព្រមទាំងយុវជនជាច្រើនកាន់តែមានលទ្ធភាពចូលរៀនការអប់រំបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព។

**អាទិភាពទី ៣ ៖** ធានាឱ្យស្រ្តី និងបុរសទាំងអស់ មានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងឧត្តមសិក្សា ប្រកបដោយគុណភាព។

**អាទិភាពទី ៤ ៖** យុវជន និងមនុស្សពេញវ័យទាំងអស់ ទទួលបានចំណេះដឹងអក្ខរកម្ម និងលេខនព្វន្តព្រមទាំងអ្នកសិក្សាគ្រប់វ័យទាំងអស់កាន់តែមានឱកាសច្រើនឡើងៗ ក្នុងការសិក្សាពេញមួយជីវិត។

**អាទិភាពទី ៥ ៖** អភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំ មានភាពល្អប្រសើរជាងមុននៅគ្រប់កម្រិត។

### ៤.៥.១. អាទិភាពទី ១៖ ការអប់រំ និងការគាំពារកុមារតូច និងការអប់រំកម្រិតមូលដ្ឋាន

**អាទិភាពទី ១៖**

កុមារី និងកុមារាគ្រប់រូបទទួលបានការគាំពារនិងការអប់រំកុមារតូចនិងការអប់រំមត្តេយ្យសិក្សាប្រកបដោយគុណភាព និងបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន (បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) ដោយឥតបង់ថ្លៃ ប្រកបដោយសមធម៌ និងគុណភាពដែលទទួលបានលទ្ធផលសិក្សាប្រកបដោយប្រសិទ្ធភាព និងភាពឆ្លើយតប។

ការអប់រំប្រកបដោយគុណភាព គឺជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ តាមរយៈអន្តរាគមន៍គោលនយោបាយ ការអប់រំ គឺមានអនុភាពប្រែក្លាយជីវភាពរស់នៅរបស់ប្រជាជនឱ្យកាន់តែល្អប្រសើរជាងមុន ជំរុញកំណើនសេដ្ឋកិច្ច លើកកម្ពស់ជំនាញ បង្កើនសមភាពយេនឌ័រនិងបរិយាបន្នសង្គម ជំរុញនិរន្តរភាពផ្នែកបរិស្ថាន និងកែលម្អអភិបាលកិច្ច។ ដូចបានកំណត់ក្នុងរបៀបវារៈការអប់រំសកល រាជរដ្ឋាភិបាលកម្ពុជាខិតខំសម្រេចឱ្យបាននូវសកលកម្មនៃការទទួលបានសេវាគាំពារ និងអប់រំកុមារតូច និងការអប់រំមត្តេយ្យសិក្សា ក៏ដូចជាលើកកម្ពស់សកលកម្មនៃការបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន(បឋមសិក្សានិងមធ្យមសិក្សាបឋមភូមិ) ទន្ទឹមនឹងការធានាឱ្យបាននូវលទ្ធផលសិក្សាសម្រាប់កុមារគ្រប់រូបផងដែរ។ ក្របខណ្ឌនេះ ការទទួលបានសេវាគាំពារនិងអប់រំកុមារតូច និងការអប់រំមត្តេយ្យសិក្សា នឹងត្រូវពង្រីកសម្រាប់គ្រប់កុមារទាំងអស់ ខណៈពេលដែលវឌ្ឍនភាពក្នុងការផ្តល់សេវាអប់រំបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ នឹងត្រូវពង្រឹងបន្ថែមទៀតដោយផ្តោតជាសំខាន់លើសកលកម្មនៃការបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន។

អាទិភាពទី ១ នៃផែនទីបង្ហាញផ្លូវនេះ មានលទ្ធផលរំពឹងទុកដូចខាងក្រោម ៖

១.១ កុមារតូចគ្រប់រូបអាយុក្រោម ៥ ឆ្នាំ កាន់តែទទួលបានការគាំពារនិងអភិវឌ្ឍកុមារតូច និងការអប់រំមត្តេយ្យសិក្សាប្រកបដោយគុណភាព និងត្រៀមលក្ខណៈពេញលេញ ដើម្បីទទួលការអប់រំបឋមសិក្សា។

១.២ កុមារី និងកុមារាគ្រប់រូប បញ្ចប់ការអប់រំកម្រិតមូលដ្ឋាន (បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) ប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ ក្រោមការឧបត្ថម្ភពីរដ្ឋ និងផ្តល់ដោយឥតបង់ថ្លៃ និងទទួលបានបំណិនអក្ខរកម្មវិជ្ជាជីវៈផ្នែកអក្សរ និងលេខនព្វន្ត ក៏ដូចជាទទួលបានចំណេះដឹងមុខវិជ្ជា និងទទួលបានបំណិនពាក់ព័ន្ធនឹងការគិត និងបំណិនមិនពាក់ព័ន្ធនឹងការគិត ដែលផ្តល់លទ្ធភាពឱ្យពួកគេអាចអភិវឌ្ឍសក្តានុពលរបស់ពួកគេយ៉ាងពេញលេញ។

### *ក. ការអប់រំ និងគាំពារកុមារតូច និងការអប់រំមត្តេយ្យសិក្សា*

**លទ្ធផលរំពឹងទុក ១.១**

កុមារតូចគ្រប់រូបអាយុក្រោម ៥ ឆ្នាំ កាន់តែទទួលបានការគាំពារនិងអភិវឌ្ឍកុមារតូច និងការអប់រំមត្តេយ្យសិក្សាប្រកបដោយគុណភាព និងត្រៀមលក្ខណៈពេញលេញដើម្បីទទួលការអប់រំបឋមសិក្សា។

ការគាំពារនិងអភិវឌ្ឍកុមារតូច គឺជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍ សុខមាលភាពនិងសុខភាពរយៈពេលវែងរបស់កុមារ។ ការគាំពារ និងអប់រំកុមារតូច គឺជាសសរស្តម្ភគ្រឹះសម្រាប់ការសិក្សាពេញមួយជីវិតតាមរយៈការកសាងនូវសមត្ថភាព និងបំណិន ដែលផ្តល់លទ្ធភាពឱ្យមនុស្សអាចសិក្សាពេញមួយជីវិត និងរកចំណូលសម្រាប់ទ្រទ្រង់ជីវភាពរបស់ខ្លួន។ ការសិក្សាស្រាវជ្រាវជាលក្ខណៈអន្តរជាតិជាច្រើនបង្ហាញថា ការគាំពារនិងអភិវឌ្ឍកុមារតូចនៅក្នុងឆ្នាំដំបូងៗ គឺមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍនៅពេលបន្តបន្ទាប់ទៀតក្នុងជីវិត។ ការវិនិយោគលើធនធានមនុស្សសម្រាប់កុមារស្ថិតក្នុងវ័យចូលរៀននៅមត្តេយ្យសិក្សា គឺផ្តល់នូវផលមកវិញខ្ពស់បំផុត។ ភស្តុតាងនានាបង្ហាញថា កម្មវិធីគាំពារ និងអប់រំកុមារតូចផ្តល់ប្រយោជន៍យ៉ាងច្រើនដល់កុមារមកពីគ្រួសារជួបការលំបាក ដូចជា ជួយរៀបចំឱ្យពួកគេត្រៀមខ្លួនទទួលបានការអប់រំ ជួយឱ្យសម្រេចបានលទ្ធផលនៃការអប់រំកាន់តែល្អប្រសើរ (ពិន្ទុតេស្ត ការរៀនត្រួតថ្នាក់ ការបន្តរៀន) ធ្វើឱ្យសុខភាពនិងសុខមាលភាពរបស់ពួកគេកាន់តែល្អប្រសើរ សម្រេចបាននូវលទ្ធផលកាន់តែល្អសម្រាប់ទីផ្សារការងារ និងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ។ ការគាំពារ និងអប់រំកុមារតូច មានវិសាលភាពទូលំទូលាយជាងការអប់រំមត្តេយ្យសិក្សា។ ការគាំពារ និងអប់រំកុមារតូច មានលក្ខណៈគ្រប់ជ្រុងជ្រោយព្រោះបានបញ្ចូលការថៃទាំផង និងការក្មេងនៅផ្ទះផង ការផ្តល់អាហារដែលនាំមកនូវសុខភាពល្អ និងអាហារូបត្ថម្ភគ្រប់គ្រាន់ ទទួលបានការការពារពីអំពើហិង្សា ការផ្តល់នូវបរិយាកាសអំណោយផលក្នុងសហគមន៍ និងសាលារៀន និងការយកចិត្តទុកដាក់ចំពោះការអភិវឌ្ឍផ្នែកពុទ្ធិ ភាសា កាយសម្បទា និងចិត្តសង្គម។ កម្ពុជាចាំបាច់ត្រូវតែវិនិយោគលើការគាំពារ និងអប់រំកុមារតូចដើម្បីកសាងធនធានមនុស្ស ដែលមានសារៈសំខាន់ក្នុងការជួយឱ្យសម្រេចបាននូវចក្ខុវិស័យសេដ្ឋកិច្ចសង្គមកិច្ច ក៏ដូចជាដោះស្រាយភាពក្រីក្រនិងបញ្ហាលំបាកផ្សេងៗ។ គោលនយោបាយជាតិស្តីពីការគាំពារនិងអភិវឌ្ឍកុមារតូច គឺជាក្របខណ្ឌដើម្បីធានាឱ្យមានការអភិវឌ្ឍកុមារតូច ដោយប្រើប្រាស់អភិក្រមដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នា។ ដើម្បីសម្រេចគោលដៅនេះ ផែនទីបង្ហាញផ្លូវដាក់ចេញនូវយុទ្ធសាស្ត្រជាច្រើនដូចជា ការអនុវត្តគោលនយោបាយគាំពារ និងអប់រំកុមារតូចដែលមានលក្ខណៈពហុវិស័យ ការអនុម័តក្របខណ្ឌច្បាប់ និងការពង្រីកសេវាគាំពារ និងអប់រំកុមារតូច ដែលមាន

គុណភាព ជាពិសេសនៅតាមតំបន់ជនបទ និងតំបន់ជួបការលំបាក។ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវចាត់វិធានការជាជំហានៗដើម្បីឈានទៅកែលម្អគុណភាពនៃការគាំពារនិងអប់រំកុមារតូច ការអប់រំមត្តេយ្យសិក្សាតាមរយៈការត្រៀមរៀបចំបណ្តុះបណ្តាលវិជ្ជាជីវៈដល់អ្នកសម្របសម្រួល ការគាំពារនិងអប់រំកុមារតូច ការបង្កើតនូវបរិយាកាសសិក្សាដែលមានសុវត្ថិភាព និងបរិយាបន្ន ការជំរុញឱ្យមានការចូលរួមពីមាតាបិតា សហគមន៍ ការផ្តល់នូវសម្ភាររៀនសូត្រប្រកបដោយគុណភាព និងការសម្របសម្រួលឱ្យបានជិតស្និទ្ធជាមួយវិស័យដទៃទៀត ដើម្បីបង្កើតសំណាញ់សុវត្ថិភាពសម្រាប់សាលារៀន (ឧទាហរណ៍ ការពិនិត្យសុខភាពដំបូងមុនចូលរៀន ការផ្តល់អាហារតាមសាលារៀន កម្មវិធីសុខភាព)។ល។ អ្នកសម្របសម្រួលគាំពារនិងអប់រំកុមារតូច ការអប់រំមត្តេយ្យសិក្សាដែលមានគុណវុឌ្ឍិនិងបានទទួលការបណ្តុះបណ្តាលនឹងត្រូវបង្កើនឱ្យបន្ថែមទៀត។ គំនិតផ្តួចផ្តើមពិនិត្យតាមដានសមត្ថភាពអំណាន និងគណិតវិទ្យាដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននឹងត្រូវពង្រឹងបន្ថែមទៀត។ រាជរដ្ឋាភិបាលនឹងអនុវត្តការងារត្រៀមរៀបចំមួយចំនួនដើម្បីអនុវត្តកាតព្វកិច្ចសិក្សានៅមត្តេយ្យសិក្សា ដែលផ្តល់ដោយឥតបង់ថ្លៃ ស្របគ្នាជាមួយនឹងការអំពាវនាវរបស់សកលលោក។

ផ្អែកតាមការព្យាករណ៍បង្ហាញថា អត្រារួមនៃការសិក្សានៅមត្តេយ្យសិក្សានឹងកើនឡើងពីពេលបច្ចុប្បន្ន ៤១,៥ ភាគរយ ដល់ ៥១,៨ ភាគរយ ត្រឹមឆ្នាំ២០៣០ ដោយមានចំណុចដៅ ៤៥.៧ ភាគរយសម្រាប់ឆ្នាំ២០១៩-២០២៣ និង៥០,១ ភាគរយ សម្រាប់ឆ្នាំ២០២៤-២០២៨។ រាជរដ្ឋាភិបាលនឹងធានាថាកុមារដែលចូលរៀនថ្នាក់ទី១ បឋមសិក្សា មានបទពិសោធន៍ជាមួយនឹងការគាំពារ និងអប់រំកុមារតូចយ៉ាងហោចណាស់មួយប្រភេទ។ ការព្យាករណ៍បង្ហាញថា ៨២,៨ ភាគរយ នៃកុមារដែលចូលរៀននៅថ្នាក់ទី១នឹងបានទទួលការគាំពារ និងអប់រំកុមារតូចក្នុងប្រភេទផ្លូវការណាមួយត្រឹមឆ្នាំ២០៣០។ តារាងទី៦ បង្ហាញពីចំណុចដៅឆ្នាំ ២០៣០ និងចំណុចដៅសម្រាប់ឆ្នាំ ២០២៣ និង ២០២៨។

### តារាងទី ៦ ៖ ចំណុចដៅសំខាន់ៗសម្រាប់ការគាំពារ និងអប់រំកុមារ និងការអប់រំមត្តេយ្យសិក្សា

| សូចនាករ | ទិន្នន័យគោល ២០១៨ | ចំណុចដៅ ២០១៩-២០២៣ | ចំណុចដៅ ២០២៤-២០២៨ | ចំណុចដៅ ២០៣០ |
|---|---|---|---|---|
| អត្រារួមនៃការសិក្សានៅមត្តេយ្យសិក្សា | ៤១,៣% | ៤៥,៧% | ៥០,១% | ៥១,៨% |
| ភាគរយនៃកុមាររៀនថ្នាក់ទី ១ ដែលបានចូលរៀនក្នុងកម្មវិធីគាំពារ និងអប់រំកុមារតូចក្នុងប្រភេទណាមួយ | ៦៥,០% | ៧៤,៥% | ៨០,៣% | ៨២,៨% |

### *យុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវបានស្នើឡើង*

តារាងទី៧ បង្ហាញពីយុទ្ធសាស្ត្រ និងសកម្មភាពដែលនឹងត្រូវអនុវត្ត ដើម្បីសម្រេចបាននូវលទ្ធផលពាក់ព័ន្ធនឹងការគាំពារ និងអប់រំកុមារតូច ការអប់រំមត្តេយ្យសិក្សា។

**តារាងទី ៧៖ យុទ្ធសាស្ត្របង្កើនការចូលរៀន និងគុណភាពនៃការគាំពារនិងអប់រំកុមារតូច និងការអប់រំមត្តេយ្យសិក្សា**

| យុទ្ធសាស្ត្រ | សកម្មភាព |
|---|---|
| **១.១.១** រៀបចំ និងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រគាំពារ និងអប់រំកុមារតូចពហុវិស័យគ្រប់ជ្រុងជ្រោយ តាមរយៈការពង្រឹងការសម្របសម្រួលរវាងក្រសួងពាក់ព័ន្ធនានា ដែលទទួលខុសត្រូវលើវិស័យផ្សេងៗគ្នា និងធានាឱ្យមានការផ្តល់ធនធានឱ្យបានគ្រប់គ្រាន់សម្រាប់ការអនុវត្ត។ | **១.១.១ក** ពិនិត្យឡើងវិញលើគោលនយោបាយ និងយន្តការសម្របសម្រួលការគាំពារ និងអប់រំកុមារតូចដែលមានស្រាប់ និងរៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រគាំពារ និងអប់រំកុមារតូចពហុវិស័យសម្រាប់ពង្រឹងកិច្ចសហប្រតិបត្តិការ។ |
| ១.១.២ រៀបចំយុទ្ធសាស្ត្រ ក្របខណ្ឌច្បាប់ឱ្យបានសមស្រប និងកំណត់ពីតួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់ ដើម្បីធានាឱ្យមានការផ្តល់នូវកាតព្វកិច្ចសិក្សាកម្រិតមត្តេយ្យសិក្សាដោយឥតបង់ថ្លៃចំពោះកុមារអាយុ ៥ឆ្នាំ និងអនុវត្តកម្មវិធីកាតព្វកិច្ចសិក្សាកម្រិតមត្តេយ្យសិក្សាដោយឥតបង់ថ្លៃជាដំណាក់កាលៗ។ | **១.១.២ក** ធ្វើការសិក្សាលទ្ធភាព ដើម្បីពិនិត្យលើការដាក់ឱ្យអនុវត្តនូវកាតព្វកិច្ចសិក្សាកម្រិតមត្តេយ្យសិក្សាដោយឥតបង់ថ្លៃ ផ្តោតការយកចិត្តទុកដាក់ពិសេសចំពោះក្មេងស្រី កុមារពិការ កុមារជនជាតិភាគតិច កុមារដែលមកពីគ្រួសារក្រីក្រ និងជួបការលំបាកជាងគេ។ |
| | **១.១.២ខ** រៀបចំក្របខណ្ឌច្បាប់ពាក់ព័ន្ធ រួមនឹងផែនការឱ្យបានច្បាស់លាស់សម្រាប់ផ្តល់នូវកាតព្វកិច្ចសិក្សារយៈពេលមួយឆ្នាំដោយឥតបង់ថ្លៃជាដំណាក់កាលៗដែលធ្វើឱ្យការអប់រំមត្តេយ្យសិក្សាក្លាយជាផ្នែកមួយដ៏សំខាន់នៃការអប់រំមូលដ្ឋាន (ពីមត្តេយ្យសិក្សាដល់ថ្នាក់ទី ៩)។ |
| **១.១.៣** ពង្រីកការផ្តល់កម្មវិធី សេវានិងហេដ្ឋារចនាសម្ព័ន្ធគ្រប់ជ្រុងជ្រោយសម្រាប់គាំទ្រដល់ការគាំពារ និងអប់រំកុមារតូចដោយផ្តោតការយកចិត្តទុកដាក់លើតម្រូវការផ្នែកការអប់រំសុខភាព អាហារូបត្ថម្ភ និងកិច្ចការពារកុមារ ជាពិសេសសម្រាប់កុមារពិការ កុមារ | **១.១.៣ក** រៀបចំបង្កើតផែនទីសិក្សាថ្នាក់ជាតិ ដើម្បីធ្វើការវាយតម្លៃពីវិសាលភាពបច្ចុប្បន្ននៃសេវាគាំពារ និងអប់រំកុមារតូច។ |
| | **១.១.៣ខ** បង្កើតមណ្ឌល ឬ កន្លែងអប់រំកុមារតូចតាមតម្រូវការ (កម្មវិធីអប់រំតាមផ្ទះ មណ្ឌលសហគមន៍ ឬ |

| | |
|---|---|
| ជនជាតិភាគតិច និងកុមារដែលរស់នៅតាមសហគមន៍ជនបទ សហគមន៍ជួបការលំបាក និងគ្រួសារដែលមានជីវភាពក្រីក្របំផុត។ | មណ្ឌលសាធារណៈ ) ដែលផ្តល់ដោយសេវាគាំពារ និងអប់រំកុមារតូចគ្រប់ជ្រុងជ្រោយ ដូចជាអាហារ-រូបត្ថម្ភ ការថែទាំកុមារ និងសេវាសុខភាពផ្អែកទៅតាមទិន្នន័យដែលបានពីការរៀបចំផែនទីខាងលើ។ |
| | **១.១.៣គ** កែលម្អសម្ភារបរិក្ខារសម្រាប់ការគាំពារ និងអប់រំកុមារតូចដោយមានការយកចិត្តទុកដាក់ចំពោះកុមារ ពិការភាព និងយេនឌ័រ ដោយផ្តោតជាពិសេស តំបន់ជនបទដែលជួបការលំបាក និងសហគមន៍ជាតិភាគតិច។ |
| | **១.១.៣ឃ** រៀបចំ និងអនុវត្តកម្មវិធីអប់រំពហុភាសានៅតាមសហគមន៍ជនជាតិភាគតិច ដើម្បីធានាឱ្យកុមារទទួលបានការរៀនសូត្រនៅក្នុងឆ្នាំដំបូងៗជាភាសាដែលប្រើប្រាស់ក្នុងផ្ទះរបស់ពួកគេ។ |
| | **១.១.៣ង** អភិវឌ្ឍសមត្ថភាពដើម្បីបង្កើនភាពឆ្លើយតប និងគណនេយ្យភាពរបស់ស្ថាប័ននៅថ្នាក់មូលដ្ឋានក្នុងការអនុវត្តនូវកម្មវិធីអប់រំកុមារតូច ក្រោមដំណើរការវិមជ្ឈការ និងកៀរគរឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋាន និងមាតាបិតា។ |
| | **១.១.៣ច** រៀបចំក្របខណ្ឌគតិយុត្តសម្រាប់បង្កើតដំណើរការគ្រប់គ្រងកម្មវិធីគាំពារ និងអប់រំកុមារតូចក្នុងវិស័យសាធារណៈនិងវិស័យមិនមែនសាធារណៈ។ |
| **១.១.៤** បង្កើនគុណភាពនៃកម្មវិធីគាំពារនិងអប់រំកុមារតូច តាមរយៈការដាក់ចេញនូវស្តង់ដាគុណភាពសម្រាប់ការគាំពារនិងអប់រំកុមារតូចនៅថ្នាក់ជាតិ រៀបចំកម្មវិធី-សិក្សាជាតិសម្រាប់ការអប់រំកុមារតូច បង្កើនគុណភាពគុណវុឌ្ឍិវិជ្ជាជីវៈ ឋានៈនិងលក្ខខណ្ឌការងាររបស់បុគ្គលិកដែលផ្តល់សេវាគាំពារ និងអប់រំកុមារតូច និងធ្វើការពិនិត្យតាមដានស្តង់ដាគុណភាពរបស់អ្នកផ្តល់សេវាផ្សេងៗឱ្យបានជាប្រចាំ។ | **១.១.៤ក** រៀបចំស្តង់ដាគុណភាពសម្រាប់ការគាំពារ និងអប់រំកុមារតូចស្របទៅតាមគោលការណ៍នៃការប្រើប្រាស់គោលវិធីគ្រប់ជ្រុងជ្រោយសម្រាប់អភិវឌ្ឍកុមារតូច។ |
| | **១.១.៤ខ** រៀបចំ និងធ្វើបច្ចុប្បន្នភាពក្របខណ្ឌកម្មវិធី-សិក្សាជាតិ សម្រាប់ការគាំពារ និងអប់រំកុមារតូច។ |
| | **១.១.៤គ** រៀបចំ និងអនុវត្តកម្មវិធីដើម្បីបង្កើនគុណវុឌ្ឍិអប់រំ លក្ខខណ្ឌការងារ ការលើកទឹកចិត្ត និងការអនុវត្តវិជ្ជាជីវៈរបស់បុគ្គលិក ឬ អ្នកសម្រប- |

| | |
|---|---|
| | សម្រួលការគាំពារនិងអប់រំកុមារតូច ឬ ការអប់រំមត្តេយ្យសិក្សា ជាពិសេសអ្នកធ្វើការនៅតំបន់ជនបទ តំបន់ជួបការលំបាក។ |
| | **១.១.៤ឃ** រៀបចំ និងអនុវត្តកម្មវិធីអប់រំមាតាបិតា ដើម្បីបណ្តុះបណ្តាល ផ្តល់លទ្ធភាពឱ្យគ្រួសារអាច បំពេញតួនាទីជាអ្នកផ្តល់ការថៃទាំដំបូងបានប្រសើរ ដល់កុមារ។ |
| | **១.១.៤ង** ពិនិត្យតាមដាន វាយតម្លៃស្តង់ដាគុណភាព របស់អ្នកផ្តល់សេវាគាំពារ និងអប់រំកុមារតូច និងអ្នក ផ្តល់សេវាអប់រំមត្តេយ្យសិក្សាប្រភេទផ្សេងៗ(កម្មវិធី មត្តេយ្យសិក្សាតាមខ្នងផ្ទះ មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សាសាធារណៈ និងឯកជន)។ |
| | **១.១.៤ច** រៀបចំ និងអនុវត្តប្រព័ន្ធតាមដានដើម្បី វាស់វែងការត្រៀមខ្លួនចូលរៀននៅពេលកុមារដល់ វ័យសិក្សា ដូចជាការរៀនសូត្រ សុខមាលភាព ចិត្តសង្គមជាដើម។ |

## *ខ. ការអប់រំកម្រិតមូលដ្ឋាន*

**លទ្ធផលរំពឹងទុក ១.២**

កុមារី និងកុមារាគ្រប់រូប បញ្ចប់ការអប់រំកម្រិតមូលដ្ឋាន (បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) ប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ ក្រោមការឧបត្ថម្ភពីរដ្ឋ និងផ្តល់ដោយឥតបង់ថ្លៃ និង ទទួលបានបំណិនអក្ខរកម្មវិជ្ជាជីវៈផ្នែកអក្សរ និងលេខនព្វន្ត ក៏ដូចជាទទួលបានចំណេះដឹងមុខវិជ្ជា និងទទួលបានបំណិនពាក់ព័ន្ធនឹងការគិតនិងបំណិនមិនពាក់ព័ន្ធនឹងការគិត ដែលផ្តល់លទ្ធភាពឱ្យ ពួកគេអាចអភិវឌ្ឍសក្តានុពលរបស់ពួកគេយ៉ាងពេញលេញ។

មាត្រា ៦៥ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា "រដ្ឋត្រូវការពារ និងលើកស្ទួយសិទ្ធិ របស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំ ប្រកបដោយគុណភាពនៅគ្រប់កម្រិត និងត្រូវចាត់វិធានការ គ្រប់បែបយ៉ាងជាជំហានៗ ដើម្បីឱ្យការអប់រំនេះ បានដល់ប្រជាពលរដ្ឋគ្រប់រូប"។ រដ្ឋធម្មនុញ្ញក៏ធានានូវ ការអប់រំបឋមសិក្សា និងមធ្យមសិក្សារយៈពេល ៩ ឆ្នាំដោយឥតបង់ថ្លៃដល់ប្រជាពលរដ្ឋគ្រប់រូបផងដែរ។ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិជាច្រើន ដែលធានាសិទ្ធិផ្សេងៗ

របស់ប្រជាពលរដ្ឋ និងបានអំពាវនាវឱ្យមានការបញ្ចប់ការរើសអើង។ ស្របតាមកាតព្វកិច្ចដែលបានចែងក្នុងរដ្ឋធម្មនុញ្ញ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងពង្រីកឱកាសអប់រំដល់ប្រជាពលរដ្ឋរបស់ខ្លួន។ អត្រាពិតនៃការសិក្សានៅបឋមសិក្សាបានកើនដល់ ៩៧,៨ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨ ដែលបង្ហាញថា ប្រជាពលរដ្ឋស្ទើរតែទាំងអស់បានទទួលការអប់រំ។ ផ្អែកតាមសកលកម្មនៃការអប់រំបឋមសិក្សា រាជរដ្ឋាភិបាលកម្ពុជានឹងផ្តល់អាទិភាពលើការបង្កើនការចូលរៀននៅកម្រិតមូលដ្ឋាននៅទូទាំងប្រទេស។

ការបន្តផ្តោតការយកចិត្តទុកដាក់គឺ សិស្សនឹងទទួលបានជំនាញអក្ខរកម្មវិជ្ជាជីវៈ និងលេខនព្វន្ត ក៏ដូចជាការទទួលបានចំណេះដឹងស្របតាមខ្លឹមសារមុខវិជ្ជា ក៏ដូចជាបំណិននៃការគិតនិងបំណិនមិនពាក់ព័ន្ធនឹងការគិត។ គោលបំណងចម្បង គឺបង្កើនភាគរយសិស្សឱ្យសម្រេចបានតាមស្តង់ដាលទ្ធផលសិក្សាកម្រិតអប្បបរមា។ ទិន្នន័យគោលនឹងត្រូវរៀបចំឡើងក្នុងរយៈពេល ២ឆ្នាំដំបូងនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣។ ចំណុចផ្តោតការយកចិត្តទុកដាក់ គឺការបង្កើនភាគរយគ្រូបង្រៀនដែលបំពេញតាមស្តង់ដាគុណវុឌ្ឍិថ្មី និងគ្រូបង្រៀនដែលទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ។ រីឯនៅមធ្យមសិក្សាបឋមភូមិវិញ កិច្ចការបន្ទាន់ គឺបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធអប់រំតាមរយៈការកាត់បន្ថយការបោះបង់ការសិក្សា និងការរៀនត្រួតថ្នាក់។

ក្រសួងនឹងខិតខំបង្កើនអត្រាបញ្ចប់ការសិក្សាសម្រាប់ការអប់រំកម្រិតមូលដ្ឋាន ជាពិសេសសម្រាប់ក្រុមសិស្សមកពីគ្រួសារដែលមានជីវភាពក្រីក្រ និងជួបការលំបាកជាងគេ ក៏ដូចជា កាត់បន្ថយការរៀនត្រួតថ្នាក់ និងការបោះបង់ការសិក្សា។ យុទ្ធសាស្ត្រគោលនយោបាយគន្លឹះនឹងរួមបញ្ចូលការពង្រីកការអប់រំកម្រិតមូលដ្ឋាន ការដោះស្រាយគម្លាតគ្រប់រូបភាពតាមយេនឌ័រ ពិការភាព និងតំបន់ (ជនបទ ឬ ប្រជុំជន) ជនជាតិ ឬ ភាសា ឬ កម្រិតចំណូល កែលម្អសម្ភាររូបវន្តអប់រំដើម្បីគាំទ្រដល់កុមារពិការ និងយេនឌ័រ និងផ្តល់នូវបរិយាកាសសិក្សា ដែលមានសុវត្ថិភាព បរិយាបន្ន និងប្រសិទ្ធភាព ធានាឱ្យសាលារៀនទទួលបានគ្រូបង្រៀនដែលមានគុណវុឌ្ឍិវិជ្ជាជីវៈ ទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ មានទឹកចិត្តបំពេញការងារ និងទទួលបានការគាំទ្រសមស្រប។ កម្មវិធីសិក្សាតាមសាលារៀននឹងបញ្ចូលនូវចំណេះដឹង បំណិន និងគុណតម្លៃដែលចាំបាច់ សម្រាប់ឱ្យសិស្សរៀនរស់នៅប្រកបដោយនិរន្តរភាព និងបំពេញតួនាទីជាពលរដ្ឋសកល។ ផែនការជាដំណាក់កាលៗនឹងត្រូវរៀបចំឡើង ដើម្បីគាំទ្រដល់ការអនុវត្តក្របខណ្ឌកម្មវិធីសិក្សាថ្មី។ ប្រព័ន្ធវាយតម្លៃការសិក្សានឹងត្រូវពង្រឹង ដោយងាកចេញពីការវាយតម្លៃការសិក្សាបច្ចុប្បន្នទៅជាការវាយតម្លៃការសិក្សាដែលបញ្ចូលឧបករណ៍វាយតម្លៃតាមដំណាក់កាល និងវាយតម្លៃសរុប ដើម្បីវាស់វែងបំណិននៃការគិតផងនិងបំណិនមិនពាក់ព័ន្ធនឹងការគិតផង។ សាលារៀននឹងដឹកនាំដោយនាយក នាយិកាដែលបានទទួលការបណ្តុះបណ្តាលពីការគ្រប់គ្រងតាមសាលារៀន សាលារៀន

នឹងទទួលបានធនធានគ្រប់គ្រាន់ដើម្បីបង្កើតឱកាសសិក្សា ដែលឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកសិក្សា។ ក្រសួងអប់រំ យុវជន និងកីឡានឹងដាក់ចេញនូវមូលដ្ឋានចាំបាច់សម្រាប់អនុវត្តកាតព្វកិច្ចសិក្សានៅកម្រិតមូលដ្ឋានដោយឥតបង់ថ្លៃ។

### *ចំណុចដៅសំខាន់ៗសម្រាប់ការអប់រំបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ*

ស្របតាមចំណុចដៅ ៤.១ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤-ការអប់រំ ឆ្នាំ២០៣០ និងអាទិភាពរបស់រាជរដ្ឋាភិបាល កម្ពុជាស្នើឡើងនូវការសម្រេចសកលកម្មនៃការបញ្ចប់ការអប់រំបឋមសិក្សាត្រឹមឆ្នាំ២០៣០(តារាងទី៨)។ ដោយឡែកនៅមធ្យមសិក្សាបឋមភូមិ គឺបង្កើនអត្រាបញ្ចប់ការសិក្សាពីពេលបច្ចុប្បន្ន (៤៦,៥ ភាគរយ) ដល់ ៦១,១ ភាគរយ នៅឆ្នាំ ២០៣០។

### តារាងទី ៨៖ ចំណុចដៅសំខាន់ៗ សម្រាប់ការអប់រំបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ

| សូចនាករ | ទិន្នន័យគោល ២០១៨ | ចំណុចដៅ ឆ្នាំ ២០១៩-២០២៣ | ចំណុចដៅ ឆ្នាំ ២០២៤-២០២៨ | ចំណុចដៅ ២០៣០ |
|---|---|---|---|---|
| អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | ៨២,៧% | ៨៦,២% | ៨៩,៧% | ៩១,១% |
| អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ៤៦,៥% | ៥២,៦% | ៥៨,៧% | ៦១,១% |

### *យុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវបានស្នើឡើង*

តារាងទី៩ រៀបរាប់ពីយុទ្ធសាស្ត្រ និងសកម្មភាពដែលនឹងត្រូវអនុវត្ត ដើម្បីសម្រេចលទ្ធផលពាក់ព័ន្ធនឹងការអប់រំកម្រិតមូលដ្ឋាន (បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ)។

### តារាងទី ៩៖ យុទ្ធសាស្ត្រសម្រាប់កែលម្អការអប់រំកម្រិតមូលដ្ឋាន

| យុទ្ធសាស្ត្រ | សកម្មភាព |
|---|---|
| **១.២.១** រៀបចំគោលនយោបាយអប់រំបរិយាបន្នដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីឆ្លើយតបចំពោះតម្រូវការរបស់កុមារដែលជួបការលំបាក និងគ្រប់ទម្រង់ និងគ្រប់ប្រភេទ ដែលផ្ដោតការយកចិត្តទុកដាក់លើកុមារី កុមារពិការ កុមារជនជាតិភាគតិច និងកុមារដែលមកពីសហគមន៍ក្រីក្រ និងជួបការលំបាក។ | **១.២.១ក** វាយតម្លៃគោលនយោបាយ ផែនការ កម្មវិធីសិក្សា និងសៀវភៅសិក្សា ចរិកា ការបណ្ដុះបណ្ដាលគ្រូ និងសម្ភារដទៃទៀតចេញពីទស្សនវិស័យយេនឌ័រ និងសមធម៌ ដើម្បីធានាឱ្យការអប់រំកម្រិតមូលដ្ឋានចូលរួមលើកកម្ពស់សមភាព ការមិនរើសអើង សមភាពយេនឌ័រ និងយុត្តិធម៌។ |

| | |
|---|---|
| | **១.២.១ខ** រៀបចំគោលនយោបាយ ស្តង់ដា និងបទដ្ឋានចម្រុះដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីធានាឱ្យសាលារៀនជាសាលាកុមារមេត្រី មានសុវត្ថិភាព មានការគិតគូរពីយេនឌ័រ និងពិការភាព និងការពារកុមារឱ្យរួចផុតពីអំពើហិង្សានានា។ |
| | **១.២.១គ** រៀបចំ និងអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយអប់រំ ខ្លឹមសារអប់រំ។ល។ |
| **១.២.២** រៀបចំគោលនយោបាយ និងច្បាប់ដែលមានលក្ខណៈសមស្រប ដើម្បីធានាផ្តល់ការអប់រំដោយឥតបង់ថ្លៃ រយៈពេល ៩ ឆ្នាំ និងកាតព្វកិច្ចសិក្សាកម្រិតអប់រំមូលដ្ឋាន និងអនុវត្តជាដំណាក់កាលៗ។ | **១.២.២ក** ធ្វើការសិក្សាលទ្ធភាពសម្រាប់អនុវត្តការអប់រំកម្រិតមូលដ្ឋានរយៈពេល ៩ ឆ្នាំ និងរៀបចំផែនការសកម្មភាព ដើម្បីដាក់ឱ្យអនុវត្តនូវកាតព្វកិច្ចសិក្សាជាដំណាក់កាលៗ តាមរយៈការបែងចែកតួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់ សម្រាប់ស្ថាប័ននៅកម្រិតផ្សេងៗរបស់រដ្ឋាភិបាល និងការរៀបចំការផ្តល់ថវិកា។ |
| | **១.២.២ខ** រៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយ និងស្វែងរកការគាំទ្រ ដើម្បីអប់រំដល់សាធារណជនទូទៅ អំពីកាតព្វកិច្ចសិក្សា។ |
| **១.២.៣** បង្កើនលទ្ធភាពការចូលរួម និងការរក្សាកុមារឱ្យបន្តការសិក្សា នៅកម្រិតអប់រំកម្រិតមូលដ្ឋានតាមរយៈអន្តរាគមន៍សមស្រប។ | **១.២.៣ក** ដាក់ឱ្យអនុវត្តនូវកម្មវិធីអាហារូបករណ៍ ការផ្តល់អាហារថ្ងៃត្រង់និងអន្តរាគមន៍ផ្តោតចំគោលដៅផ្សេងទៀតជាពិសេសអន្តរាគមន៍ផ្តោតលើកុមារី កុមារពិការ កុមារជនជាតិភាគតិច កុមារក្រីក្រ និងកុមារជួបការលំបាកដោយផ្សារភ្ជាប់ទំនាក់ទំនងរវាងកាតព្វកិច្ចសិក្សាជាមួយនឹងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ។ |
| | **១.២.៣ខ** អនុវត្តប្រព័ន្ធរំលឹកជាមុន (ការកំណត់អត្តសញ្ញាណ និងទប់ស្កាត់ការបោះបង់ការសិក្សា) និងកសាងនូវប្រព័ន្ធគាំទ្រ និងអន្តរាគមន៍តាមសហគមន៍។ |
| | **១.២.៣គ** រៀបចំ និងអនុវត្តរបៀបបង្រៀនជាជម្រើសផ្សេងក្រៅប្រព័ន្ធដូចជាកម្មវិធីសមមូល និងកម្មវិធីស្ពានចម្លង ដើម្បីធានាឱ្យកុមារក្រៅសាលាអាចទទួលបានការអប់រំ។ |

| | |
|---|---|
| | **១.២.៣ឃ** រៀបចំនិងអនុវត្តផែនការកែលម្អសម្ភាររូបវ័ន្ត ដើម្បីធានាឱ្យសាលារៀនមានសម្ភាររូបវ័ន្តជាមូលដ្ឋាន (ទឹក អគ្គិសនី បង្គន់ដែលបែងចែកតាមយេនឌ័រ) ស្របតាមគោលការណ៍ណែនាំនានា និងបំពេញទៅតាមស្តង់ដាជាមូលដ្ឋាន។ |
| **១.២.៤** បង្កើនគុណភាព និងភាពឆ្លើយតបនៃការអប់រំកម្រិតមូលដ្ឋាន។ | **១.២.៤ក** ធ្វើការពិនិត្យឡើងវិញដោយមានការពិគ្រោះយោបល់លើកម្មវិធីសិក្សា ដើម្បីធានាឱ្យកម្មវិធីសិក្សាមានស្តង់ដាច្បាស់លាស់ ប្រទាក់ក្រឡាគ្នា ឆ្លើយតប និងគាំទ្រដោយយុទ្ធសាស្ត្រសិស្សមជ្ឈមណ្ឌល។ |
| | **១.២.៤ខ** កែលម្អកម្មវិធីសិក្សា ដែលកំណត់ឱ្យបានច្បាស់លាស់នូវលទ្ធផលសិក្សា ទាំងផ្នែកការគិត និងផ្នែកមិនមែនការគិត ព្រមទាំងគុណតម្លៃ បំណិន និងសមត្ថភាពផងដែរ។ |
| | **១.២.៤គ** ដាក់ឱ្យអនុវត្តនូវការវាយតម្លៃដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយតាមសាលារៀន ផ្អែកតាមស្តង់ដាធានាគុណភាពដែលត្រូវបានកំណត់ និងកសាងសមត្ថភាពសាលារៀនក្នុងការធ្វើស្វ័យវាយតម្លៃ និងកែលម្អក្នុងលក្ខណៈគ្រប់ជ្រុងជ្រោយ។ |
| | **១.២.៤ឃ** រៀបចំកម្មវិធីសិក្សា សម្ភារ ធនធានអំពីការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងការអប់រំភាពជាពលរដ្ឋសកល ឬ បញ្ចូលទៅក្នុងមុខវិជ្ជាដែលពាក់ព័ន្ធ។ |
| | **១.២.៤ង** គាំទ្រការឆ្លងភូមិសិក្សាសម្រាប់សិស្សមធ្យមសិក្សាបឋមភូមិទៅមធ្យមសិក្សាទុតិយភូមិ ឬ ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈការតម្រឹមកម្មវិធីសិក្សា ការផ្តល់ការណែនាំ ការប្រឹក្សាយោបល់ និងដំបូន្មានអប់រំ។ |
| | **១.២.៤ច** រៀបចំផែនការជាតិ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ |

| | |
|---|---|
| | និងការតភ្ជាប់បណ្ដាញតាមសាលារៀន និងការអភិវឌ្ឍសម្ភាររៀនសូត្រ ឌីជីថល ព្រមទាំងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ ដើម្បីកែលម្អគុណភាពនៃការរៀន និងបង្រៀន។ |
| | **១.២.៤ឆ** បណ្ដុះបណ្ដាល តម្រង់ទិសគ្រូឧទ្ទេស គ្រូបង្រៀន និងបុគ្គលិកអប់រំដទៃទៀត ដើម្បីលើកកម្ពស់បំណិនរបស់ពួកគេ ក្នុងការបញ្ចូលការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងការអប់រំភាពជាពលរដ្ឋសកលទៅក្នុងគោលនយោបាយអប់រំ ខ្លឹមសារកម្មវិធីសិក្សាការបណ្ដុះបណ្ដាលគ្រូ គរុកោសល្យ និងការវាយតម្លៃ។ |
| | **១.២.៤ជ** រៀបចំ និងអនុវត្តផែនការដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីពង្រឹងប្រព័ន្ធវាយតម្លៃជាតិបច្ចុប្បន្ន និងពង្រីកវិសាលភាពនៃការវាយតម្លៃ ដើម្បីគ្របដណ្ដប់លើបំណិនពាក់ព័ន្ធនឹងការគិត និងបំណិនមិនពាក់ព័ន្ធនឹងការគិត និងដាក់ឱ្យអនុវត្តពង្រឹងការវាយតម្លៃជាបណ្ដើរៗតាមសាលារៀន ព្រមទាំងការប្រើប្រាស់ទិន្នន័យដែលបានពីការវាយតម្លៃ ដើម្បីកែលម្អគោលនយោបាយកម្មវិធី និងការបង្រៀន។ |
| **១.២.៥** រៀបចំ ឬ បន្តពង្រឹងគោលនយោបាយ និងច្បាប់សមស្របដើម្បីបង្កើនឋានៈក្នុងសង្គម ភាពទាក់ទាញ និងគុណភាពនៃវិជ្ជាជីវៈបង្រៀន ព្រមទាំងការអភិវឌ្ឍវិជ្ជាជីវៈ ការផ្ដល់បៀវត្សដល់គ្រូបង្រៀន លក្ខខណ្ឌការងារ តាវកលិក សន្តិសុខសង្គម ការទទួលស្គាល់ គន្លងអាជីព និងកែលម្អការគ្រប់គ្រងគ្រូបង្រៀន។ | **១.២.៥ក** ពិនិត្យឡើងវិញការអនុវត្តលក្ខខណ្ឌគោល-នយោបាយដែលមានស្រាប់ ដែលតម្រូវឱ្យគ្រូបង្រៀនមានគុណវុឌ្ឍិកាន់តែខ្ពស់ជាងមុន។ |
| | **១.២.៥ខ** ពិនិត្យឡើងវិញ និងពង្រឹងប្រព័ន្ធគ្រប់គ្រងគ្រូបង្រៀន ដូចជាការជ្រើសរើសដែលមានលក្ខណៈប្រកួតប្រជែង អធិការកិច្ច ការវាយតម្លៃសមិទ្ធផល ការទទួលស្គាល់សមិទ្ធផលដែលមានភាពស័ក្ដិសិទ្ធិ ការឡើងឋានៈក្នុងអាជីព និងរៀបចំយុទ្ធសាស្ត្រពង្រាយគ្រូ ដើម្បីធានាឱ្យមានការបែងចែកគ្រូបង្រៀនតាមតំបន់ផ្សេងៗប្រកបដោយសមធម៌។ |
| | **១.២.៥គ** ពង្រឹងស្ដង់ដាគ្រឹះស្ថាន ឬ ប្រព័ន្ធបណ្ដុះបណ្ដាលគ្រូ (បណ្ដុះបណ្ដាល និងវិក្រឹតការ) ដូចជា |

| | |
|---|---|
| | គ្របខណ្ឌគុណវុឌ្ឍិ គ្រូបង្រៀន អ្នកអប់រំគ្រូ គ្រូឧទ្ទេស និងបុគ្គលិកអប់រំផ្សេងទៀត។ |
| | **១.២.៥ឃ** បង្កើនលទ្ធភាពដល់គ្រូបង្រៀនឱ្យទទួលបានការរៀនសូត្រនៅនឹងកន្លែងធ្វើការជាក់ស្តែង តាមរយៈកម្មវិធីគាំទ្រវិជ្ជាជីវៈ កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ កម្មវិធីហ្វឹកហាត់ ការគាំទ្រតាមប្រព័ន្ធអនឡាញ កម្មវិធីស្វ័យសិក្សា និងការស្រាវជ្រាវដែលមានការចូលរួម។ |
| | **១.២.៥ង** លើកកម្ពស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូដោយបំពាក់នូវសម្ភារបរិក្ខារទំនើប ធនធានបណ្ណាល័យ បន្ទប់កំព្យូទ័រ និងធនធានអនឡាញ។ |
| | **១.២.៥ច** កែលម្អកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូ ទាំងបណ្តុះបណ្តាល និងវិក្រឹតការ ដើម្បីបញ្ចូលគោលវិធីគរុកោសល្យថ្មីៗដែលមានលក្ខណៈទំនើប ក៏ដូចជាដើម្បីបញ្ចូលខ្លឹមសារបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ ការអប់រំភាពជាពលរដ្ឋសកល និងការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ |
| **១.២.៦** កែលម្អគុណភាពនៃការបង្រៀន និងរៀនសម្រាប់ការអប់រំកាយ និងកែលម្អសម្ភារបរិក្ខារកីឡានៅតាមគ្រប់សាលារៀនទាំងអស់។ | **១.២.៦ក** ផ្តល់គ្រូបង្រៀនឱ្យគ្រប់ចំនួន ក៏ដូចជាការគាំទ្រ និងការបណ្តុះបណ្តាលគ្រូ ធនធានកម្មវិធីសិក្សា ដើម្បីអនុវត្តកម្មវិធីសិក្សាអប់រំកាយប្រកបដោយជោគជ័យ។ |
| | **១.២.៦ខ** កែលម្អទីលានកីឡា សម្ភារបរិក្ខារកីឡា និងបរិក្ខារកីឡានៅតាមគ្រប់សាលារៀនទាំងអស់។ |

### *៤.៥.២. ការអប់រំមធ្យមសិក្សាទុតិយភូមិ*

**អាទិភាពទី ២៖**

កុមារី និងកុមារាទាំងអស់ បញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិដោយទទួលបានលទ្ធផលសិក្សា និងភាពឆ្លើយតប ហើយយុវជនជាច្រើនកាន់តែមានលទ្ធភាពចូលរៀនការអប់រំបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព។

ការអប់រំមធ្យមសិក្សា ពិសេស មធ្យមសិក្សាទុតិយភូមិ បំពេញតួនាទីយ៉ាងសំខាន់ចន្លោះពីការអប់រំបឋមសិក្សា និងការអប់រំឧត្តមសិក្សា និងទីផ្សារការងារ។ ការអប់រំកម្រិតនេះ គឺកំណត់ពីឱកាសអប់រំ និង

ឱកាសការងារនាពេលអនាគតសម្រាប់យុវជន។ ការចូលរៀននៅមធ្យមសិក្សាមានតួនាទីយ៉ាងសំខាន់ក្នុងការកំណត់ពីបរិមាណធនធានមនុស្សដែលមានគុណវុឌ្ឍិ និងជំនាញដែលត្រូវការអភិវឌ្ឍសេដ្ឋកិច្ចជាតិឱ្យបានជោគជ័យ។ ប៉ុន្តែ អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាកម្ពុជា នៅមានកម្រិតទាបជាងប្រទេសដែលមានចំណូលមធ្យមនៅឡើយ។ ដូចនេះ ការអប់រំមធ្យមសិក្សាទុតិយភូមិត្រូវបានចាត់ទុកជាអាទិភាពដ៏សំខាន់នៅក្នុងផែនទីបង្ហាញផ្លូវនេះ និងដាក់ចេញនូវយុទ្ធសាស្ត្រជាច្រើន ដើម្បីបង្កើនការចូលរៀន និងគុណភាពអប់រំមធ្យមសិក្សាទុតិយភូមិ។ តារាងទី១០ បង្ហាញពីចំណុចដៅសំខាន់ៗពាក់ព័ន្ធនឹងការអប់រំមធ្យមសិក្សាទុតិយភូមិ។

### តារាងទី ១០៖ ចំណុចដៅសំខាន់ៗសម្រាប់ការអប់រំមធ្យមសិក្សាទុតិយភូមិ

| សូចនាករ | ទិន្នន័យគោល ២០១៨ | ចំណុចដៅ ២០១៩-២០២៣ | ចំណុចដៅ ២០២៤-២០២៨ | ចំណុចដៅ ២០៣០ |
|---|---|---|---|---|
| អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | ២៣,៦% | ៣២,៥% | ៤១,៤% | ៤៥,0% |
| អត្រារួមនៃការសិក្សាក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (១៥ ដល់ ២៤ ឆ្នាំ) | 0,0៣% | ១៨,៧% | ៣0,៣% | ៣៥% |

### *លទ្ធផលរំពឹងទុក*

អាទិភាពទី២ មានលទ្ធផលរំពឹងទុក ២ ដូចខាងក្រោម ៖

២.១ កុមារី និងកុមារាគ្រប់រូប បញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិ ប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ ក្រោមការឧបត្ថម្ភពីរដ្ឋ និងផ្តល់ដោយឥតបង់ថ្លៃ និងទទួលបានបំណិនអក្ខរកម្មវិជ្ជាជីវៈផ្នែកអក្សរ និងលេខនព្វន្ត ក៏ដូចជាទទួលបានចំណេះដឹងមុខវិជ្ជា និងទទួលបានបំណិនពាក់ព័ន្ធនឹងការគិត និងបំណិនមិនពាក់ព័ន្ធនឹងការគិត ដែលផ្តល់លទ្ធភាពឱ្យពួកគេអាចអភិវឌ្ឍសក្តានុពលរបស់ពួកគេយ៉ាងពេញលេញ។

២.២ យុវជនជាច្រើន កាន់តែមានលទ្ធភាពចូលរៀនការអប់រំបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព។

## *គ. ការអប់រំមធ្យមសិក្សាទុតិយភូមិ*

**លទ្ធផលរំពឹងទុក ២.១**

កុមារី និងកុមារាគ្រប់រូប បញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិ ប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ ក្រោមការឧបត្ថម្ភពីរដ្ឋ និងផ្តល់ដោយឥតបង់ថ្លៃ និងទទួលបានបំណិនអក្ខរកម្មវិជ្ជាជីវៈ ផ្នែកអក្សរ និងលេខនព្វន្ត ក៏ដូចជាទទួលបានចំណេះដឹងមុខវិជ្ជា និងទទួលបានបំណិនពាក់ព័ន្ធនឹងការគិត និងបំណិនមិនពាក់ព័ន្ធនឹងការគិត ដែលផ្តល់លទ្ធភាពឱ្យពួកគេអាចអភិវឌ្ឍសក្តានុពលរបស់ពួកគេយ៉ាងពេញលេញ។

ដូចបានចែងនៅក្នុងរបៀបវារៈគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤-ការអប់រំឆ្នាំ២០៣០ សកលកម្មនៃការបញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិប្រកបដោយគុណភាព គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពសំខាន់ៗនៃវិស័យអប់រំកម្ពុជា។ ដើម្បីសម្រេចគោលដៅនេះ យុទ្ធសាស្ត្រជាច្រើនត្រូវបានដាក់ឱ្យអនុវត្តដូចជា ការផ្តល់សេវាអប់រំមធ្យមសិក្សាទុតិយភូមិប្រកបដោយបរិយាបន្ន ក្រោមការឧបត្ថម្ភពីរដ្ឋដោយឥតបង់ថ្លៃ ជាដើម។ បន្ទាប់ពីបញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិ សិស្សទទួលបានបំណិនផ្នែកអក្សរ និងលេខនព្វន្តជាមូលដ្ឋាន ក៏ដូចជាទទួលបានចំណេះដឹងខ្លឹមសារមុខវិជ្ជា និងបំណិនដែលពាក់ព័ន្ធនឹងការគិត និងបំណិនមិនពាក់ព័ន្ធនឹងការគិត។ ការផ្តល់សេវាអប់រំមធ្យមសិក្សាទុតិយភូមិដោយឥតបង់ថ្លៃ គួរលុបបំបាត់ផងដែរនូវចំណាយផ្សេងៗដែលរាំងដល់ការទទួលបានការអប់រំមធ្យមសិក្សា និងផ្តល់អាហារូបករណ៍ឱ្យចំគោលដៅ។ យុទ្ធសាស្ត្រអប់រំបរិយាបន្នត្រូវអនុវត្តផងដែរ ដើម្បីធានាឱ្យកុមារគ្រប់រូបទទួលបានការអប់រំមធ្យមសិក្សាទុតិយភូមិ ដោយមិនគិតពីភេទ ជនជាតិ ភាសាដើមកំណើត ពិការភាព និងស្ថានភាពងាយរងគ្រោះ។ គោលនយោបាយត្រឹមត្រូវ និងអន្តរាគមន៍ កម្មវិធីសម្រាប់ប្រព័ន្ធទាំងមូល ត្រូវបញ្ជ្រាប ឬ លើកកម្ពស់ពីការអប់រំភាពជាពលរដ្ឋសកល និងការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពទៅក្នុងកម្មវិធីអប់រំផ្លូវការ មិនផ្លូវការ និងក្រៅប្រព័ន្ធ (គោលនយោបាយអប់រំ ការបណ្តុះបណ្តាលគ្រូ កម្មវិធីសិក្សា គរុកោសល្យ ការវាយតម្លៃ)។ សាលារៀនគួរទទួលបាននូវសម្ភារបង្រៀននិងរៀនឱ្យបានគ្រប់គ្រាន់ ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តផ្សេងៗដែលមានលក្ខណៈបរិយាបន្ន គិតគូរពីយេនឌ័រ និងងាយស្រួលប្រើប្រាស់។ កំណែទម្រង់ជាច្រើនដែលបាននិងកំពុងអនុវត្ត ដើម្បីបង្កើនគុណភាពគ្រូបង្រៀន ចាំបាច់ត្រូវពង្រឹងឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀត។ សាលារៀនត្រូវទទួលបានកំព្យូទ័រ អគ្គិសនី និងការភ្ជាប់អ៊ីនធឺណិត ព្រមទាំងបណ្ណាល័យ និងបន្ទប់ពិសោធន៍វិទ្យាសាស្ត្រផងដែរ។ សិស្សមធ្យមសិក្សាទុតិយភូមិកាន់តែច្រើនឡើងៗនឹងចូលរៀនមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។

ផ្អែកតាមការធ្វើចំណោលបង្ហាញថា អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ នឹងកើនឡើងពី ២៣,៦ ភាគរយ នាពេលបច្ចុប្បន្នដល់ ៤៥ ភាគរយ នៅឆ្នាំ២០៣០។

### *យុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវបានស្នើឡើង*

តារាងទី១១ បង្ហាញពីយុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវបានស្នើឡើង ដើម្បីសម្រេចលទ្ធផលពាក់ព័ន្ធនឹងការអប់រំមធ្យមសិក្សាទុតិយភូមិ។

**តារាងទី ១១៖ យុទ្ធសាស្ត្រ សម្រាប់លើកកម្ពស់ការអប់រំមធ្យមសិក្សាទុតិយភូមិ**

| យុទ្ធសាស្ត្រ | សកម្មភាព |
|---|---|
| **២.១.១** បង្កើនការចូលរៀន និងបន្តការសិក្សានៅមធ្យមសិក្សាទុតិយភូមិ តាមរយៈអន្តរាគមន៍គោលនយោបាយសមស្រប។ | **២.១.១ក** រៀបចំយុទ្ធនាការបង្កើនការយល់ដឹងជាទ្រង់ទ្រាយធំទូទាំងប្រទេស និងយុទ្ធនាការប្រមូលកុមារចូលរៀន ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយគ្រប់រូបភាពរាប់បញ្ចូលទាំងប្រព័ន្ធផ្សព្វផ្សាយសង្គម យុទ្ធនាការតាមផ្ទះ។ល។ ដើម្បីពន្យល់ពីតម្លៃនៃការអប់រំមធ្យមសិក្សាទុតិយភូមិ។ |
| | **២.១.១ខ** ដាក់ឱ្យអនុវត្តនូវកម្មវិធីអាហារូបករណ៍ ការផ្តល់អាហារថ្ងៃត្រង់ និងអន្តរាគមន៍ផ្តោតចំគោលដៅផ្សេងទៀត ជាពិសេសអន្តរាគមន៍ផ្តោតលើកុមារី កុមារពិការ កុមារជនជាតិភាគតិចកុមារក្រីក្រ និងកុមារជួបការលំបាក។ |
| | ២.១.១គ អនុវត្តប្រព័ន្ធរំលឹកជាមុន (ការកំណត់អត្តសញ្ញាណ និងទប់ស្កាត់ការបោះបង់ការសិក្សា) និងកសាងនូវប្រព័ន្ធគាំទ្រនិងអន្តរាគមន៍តាមសហគមន៍។ |
| | ២.១.១ឃ រៀបចំ និងអនុវត្តរបៀបបង្រៀនជាជម្រើសផ្សេង ឬ ក្រៅប្រព័ន្ធដូចជាកម្មវិធីសមមូល និងកម្មវិធីស្ពានចម្លង ដើម្បីធានាឱ្យកុមារក្រៅសាលាអាចចូលរួមក្នុងការអប់រំ។ |
| | ២.១.១ង រៀបចំ និងអនុវត្តផែនការកែលម្អសម្ភាររូបវន្ត ដើម្បីធានាឱ្យសាលារៀនមានសម្ភាររូបវន្តជាមូលដ្ឋាន (ថ្នាក់រៀន បណ្ណាល័យ បន្ទប់ពិសោធន៍ ទឹក អគ្គិសនី បង្គន់បែងចែកទៅតាមយេនឌ័រ...) ដែលគិតគូរពីកុមារ |

| | |
|---|---|
| | យេនឌ័រ និងពិការភាព ក៏ដូចជាកិច្ចការពារកុមារពីអំពើហិង្សា។ |
| **២.១.២** បង្កើនគុណភាព និងភាពឆ្លើយតបនៃការអប់រំ មធ្យមសិក្សាទុតិយភូមិ។ | **២.១.២ក** ពិគ្រោះយោបល់ដើម្បីពិនិត្យឡើងវិញនូវកម្មវិធីសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិ ដើម្បីធានាឱ្យកម្មវិធីសិក្សានេះផ្អែកតាមស្តង់ដា ច្បាស់លាស់ ប្រទាក់ក្រឡា និងឆ្លើយតប ក៏ដូចជាផ្តល់ការគាំទ្រដោយយុទ្ធសាស្ត្រសិស្សមជ្ឈមណ្ឌល។ |
| | **២.១.២ខ** កែលម្អកម្មវិធីសិក្សាដោយកំណត់ឱ្យបានច្បាស់ពីលទ្ធផលសិក្សាពាក់ព័ន្ធនឹងការគិត និងមិនពាក់ព័ន្ធនឹងការគិត ព្រមទាំងគុណតម្លៃ បំណិន និងសមត្ថភាព រួមនឹងការអប់រំភាពជាពលរដ្ឋសកល និងការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ |
| | **២.១.២គ** ដាក់ឱ្យអនុវត្តការវាយតម្លៃសាលារៀនដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយប្រើប្រាស់ស្តង់ដាធានាគុណភាព និងកសាងសមត្ថភាពសាលារៀនឱ្យធ្វើស្វ័យវាយតម្លៃ និងកែលម្អខ្លួនឯងឱ្យបានគ្រប់ជ្រុងជ្រោយ។ |
| | **២.១.២ឃ** ធ្វើការពិនិត្យឡើងវិញក្នុងលក្ខណៈជាប្រព័ន្ធលើសាលារៀនជំនាន់ថ្មី និងរៀបចំយុទ្ធសាស្ត្រពង្រីកសាលារៀនជំនាន់ថ្មី ដោយរៀបចំផែនការវិនិយោគឱ្យច្បាស់លាស់ ព្រមទាំងចងក្រងនូវឧត្តមានុវត្ត ដើម្បីបង្កើនគុណភាពនៅតាមសាលារៀនសាធារណៈ។ |
| | **២.១.២ង** គាំទ្រការឆ្លងភូមិសិក្សាសម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិទៅឧត្តមសិក្សា ឬ ការអប់រំបណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈការតម្រឹមកម្មវិធីសិក្សា ការផ្តល់ការណែនាំ ការប្រឹក្សាយោបល់ និងសេវាអប់រំនានា។ |
| | **២.១.២ច** ប្រើប្រាស់ទិន្នន័យដែលបានពីការវាយតម្លៃថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីកែលម្អគោលនយោបាយ កម្មវិធី ការបង្រៀន។ |

| | |
|---|---|
| | **២.១.២ឆ** រៀបចំផែនការជាតិដើម្បីបង្កើតហេដ្ឋារចនា-សម្ព័ន្ធ បច្ចេកវិទ្យានិងសារគមនាគមន៍ និងការតភ្ជាប់បណ្តាញតាមសាលារៀន និងរៀបចំឯកសាររៀនតាមប្រព័ន្ធឌីជីថល។ |
| | **២.១.២ជ** ពង្រឹងការរៀននិងបង្រៀនមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ជាពិសេសសិស្សស្រី តាមរយៈការបង្កើតនូវបរិយាកាសជាវិជ្ជមាន និងផ្តល់ការលើកទឹកចិត្តដល់សិស្ស បង្កើនការយល់ដឹងអំពីអាជីពនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ពង្រឹងទំនាក់ទំនងរវាងសាលារៀន និងឧស្សាហកម្ម។ |
| **២.១.៣** រៀបចំ ឬ បន្តពង្រឹងគោលនយោបាយ និងច្បាប់ដើម្បីបង្កើនឋានៈក្នុងសង្គម ភាពទាក់ទាញ និងគុណភាពនៃវិជ្ជាជីវៈបង្រៀន រួមទាំងការអភិវឌ្ឍវិជ្ជាជីវៈ បៀវត្ស លក្ខខណ្ឌការងារ គាំពារកាលិកសន្តិសុខសង្គម ការទទួលស្គាល់គន្លងអាជីព និងកែលម្អការគ្រប់គ្រងគ្រូបង្រៀន។ | **២.១.៣ក** ធានាឱ្យមានការផ្គត់ផ្គង់គ្រូបង្រៀនដែលមានគុណវុឌ្ឍិ និងបានបណ្តុះបណ្តាលត្រឹមត្រូវ សម្រាប់គ្រប់មុខវិជ្ជានៅតាមសាលាមធ្យមសិក្សាទុតិយភូមិទាំងអស់។ |
| | **២.១.៣ខ** កែសម្រួល និងពង្រឹងប្រព័ន្ធគ្រប់គ្រងគ្រូបង្រៀន ដូចជាការជ្រើសរើសដោយមានការប្រកួតប្រជែងត្រឹមត្រូវ ការធ្វើអធិការកិច្ច ការវាយតម្លៃ ការបំពេញការងារ ការទទួលស្គាល់ប្រសិទ្ធភាព និងការបំពេញការងារ ការតម្លើងឋានៈ និងរៀបចំយុទ្ធសាស្ត្រពង្រាយគ្រូបង្រៀន ដើម្បីធានាឱ្យការបែងចែកគ្រូបង្រៀនប្រកបដោយសមធម៌តាមតំបន់ទាំងអស់។ |
| | **២.១.៣គ** ផ្តល់ឱកាសបន្ថែមឱ្យគ្រូបង្រៀនទទួលបានការរៀនសូត្រនៅនឹងកន្លែងធ្វើការផ្ទាល់ តាមរយៈកម្មវិធីគាំទ្រវិជ្ជាជីវៈ កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការជួយគាំទ្រគ្រូបង្រៀន ការគាំទ្រតាមប្រព័ន្ធអនឡាញ កម្មវិធីស្វ័យសិក្សា និងការស្រាវជ្រាវតាមបែបចូលរួម។ |
| | **២.១.៣ឃ** កែលម្អកម្មវិធីសិក្សាអប់រំគ្រូ ទាំងកម្មវិធីបណ្តុះ-បណ្តាល និងវិក្រឹតការ ដើម្បីបញ្ចូលនូវវិធីសាស្ត្រថ្មីៗតាមបែបទំនើប និងបញ្ចូលមុខវិជ្ជាបច្ចេកវិទ្យានិងសារគមនាគមន៍  ការអប់រំភាពជាពលរដ្ឋសកល និងការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ |

## *ខ. ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិ*

**លទ្ធផលរំពឹងទុក ២.២**

យុវជនជាច្រើន កាន់តែមានលទ្ធភាពចូលរៀនការអប់រំបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព។

ខណៈពេលដែលកម្ពុជាខិតខំជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សារៈសំខាន់នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈបានស្តែងចេញឱ្យឃើញច្បាស់ក្នុងរបៀបវារៈអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលបានទទួលស្គាល់ជាយូរមកហើយថា កម្លាំងពលកម្មដែលមានជំនាញគឺជាគន្លឹះសម្រាប់សម្រេចបំណងប្រាថ្នាផ្នែកសេដ្ឋកិច្ចរបស់យុវជន។ យុទ្ធសាស្រ្តជាច្រើនដែលរាជរដ្ឋាភិបាលដាក់ឱ្យអនុវត្តសម្រាប់ការអភិវឌ្ឍធនធានមនុស្ស រួមមានការបង្កើតកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ បច្ចុប្បន្ន វិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសនៅខេត្តចំនួន ៣ បាននិងកំពុងផ្តល់វគ្គសិក្សាអប់រំបច្ចេកទេស និងវិជ្ជាជីវៈផ្នែកមុខជំនាញជាច្រើន។ ក្រសួងអប់រំ យុវជន និងកីឡាមានបំណងពង្រីកសាលារៀនបន្ថែម ឱ្យបានយ៉ាងហោចណាស់ ៧ នៅត្រឹមឆ្នាំ ២០១៨។ សិស្សមធ្យមសិក្សាទុតិយភូមិមួយភាគតូចប៉ុណ្ណោះ ចូលរៀនតាមសាលាបណ្តុះបណ្តាលអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។ ផែនការគោលសម្រាប់ការអប់រំបច្ចេកទេស នៅមធ្យមសិក្សាទុតិយភូមិ នឹងធ្វើបច្ចុប្បន្នភាព និងជំរុញការអនុវត្តសំដៅបង្កើនការតម្រង់ទិសការសិក្សាទៅកាន់អាជីព និងពង្រីកការអប់រំបច្ចេកទេសឱ្យមានវិសាលភាពគ្របដណ្តប់ទូទាំងប្រទេស តាមទស្សនាទាន “**ខេត្តមួយមានវិទ្យាល័យចំណេះទូទៅ និង បច្ចេកទេសមួយយ៉ាងតិច សម្រាប់រយៈពេលមធ្យម និងស្រុកមួយមានវិទ្យាល័យចំណេះទូទៅ និង បច្ចេកទេសមួយយ៉ាងតិច សម្រាប់រយៈពេលវែង**” ព្រមទាំងលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ជាពិសេសតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

គោលបំណងសំខាន់ គឺត្រៀមរៀបចំកម្លាំងពលកម្ម ដោយផ្តល់ឱ្យពួកគេនូវបំណិនជាមូលដ្ឋានឱ្យបានរឹងមាំ ផ្នែកអក្សរ និងលេខនព្វន្តកម្រិតមូលដ្ឋាន ក៏ដូចជាជំនាញប្រាស្រ័យទាក់ទង ការដោះស្រាយបញ្ហា បច្ចេកវិទ្យានិងសារគមនាគមន៍។ល។ កម្មវិធីសិក្សាអប់រំបច្ចេកទេសវិជ្ជាជីវៈកម្រិតមធ្យមសិក្សាទុតិយភូមិ នឹងត្រូវធ្វើបច្ចុប្បន្នភាព ឬ រៀបចំឡើងដោយផ្អែកលើសមត្ថភាព និងនិន្នាការនៃការអភិវឌ្ឍវិស័យឯកជន ព្រមទាំងឧស្សាហកម្ម និយោជក និងគ្រឹះស្ថានឧត្តមសិក្សា។ ទន្ទឹមនោះដែរ ត្រូវផ្តោតខ្លាំងលើការបណ្តុះបណ្តាលបែបអនុវត្តជាក់ស្តែង។ លើសពីនេះ ក៏មានការវាយតម្លៃលើភាពឆ្លើយតបនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈកម្រិតមធ្យមសិក្សាទុតិយភូមិនេះផងដែរ។

យោងតាមទិន្នន័យឆ្នាំ ២០១៥ បានបង្ហាញថា អត្រារួមនៃការសិក្សាសម្រាប់បណ្តុំមុខវិជ្ជាបណ្តុះបណ្តាលអប់រំបច្ចេកទេស និងវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិ មានកម្រិតទាប ត្រឹមតែ ០,០៣ ភាគរយ ប៉ុណ្ណោះ។ ផ្អែកតាមស្ថានភាពចាប់ផ្តើមទាបបែបនេះ ក្រសួងអប់រំ យុវជន និងកីឡា មានផែនការពង្រីកការចូលរៀនក្នុងកម្មវិធីអប់រំបច្ចេកទេស បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យបានច្រើនថែមទៀត។ ផ្អែកតាមការព្យាករណ៍បង្ហាញថា ត្រឹមឆ្នាំ២០៣០ អត្រារួមនៃការសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមិនឹងកើនឡើងដល់ ៣៥ ភាគរយ។

### *យុទ្ធសាស្រ្ត និងសកម្មភាពដែលត្រូវបានស្នើឡើង*

តារាងទី១២ បង្ហាញពីយុទ្ធសាស្រ្ត និងសកម្មភាពដែលត្រូវដាក់ឱ្យអនុវត្ត ដើម្បីសម្រេចលទ្ធផលពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។

**តារាងទី១២៖ យុទ្ធសាស្រ្តសម្រាប់លើកកម្ពស់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈនៅមធ្យមសិក្សាទុតិយភូមិ**

| យុទ្ធសាស្រ្ត | សកម្មភាព |
| --- | --- |
| **២.២.១** បង្កើនការចូលរៀនរបស់សិស្សឱ្យបានច្រើនក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ | **២.២.១ក** រៀបចំយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយ កម្មវិធីបង្កើនការយល់ដឹង ដើម្បីលើកកម្ពស់មុខមាត់នៃការអប់រំបណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបង្កើនភាពទាក់ទាញនៃកម្មវិធីនេះសម្រាប់សិស្ស និស្សិត និងគ្រួសាររបស់ពួកគេ និយោជក និងអ្នកពាក់ព័ន្ធដទៃទៀត។ |
| | **២.២.១ខ** ពង្រីក និងពង្រឹងសាលាអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបំពាក់សម្ភាររូបវន្តចាំបាច់ សម្ភារឧបករណ៍ បន្ទប់ពិសោធន៍ និងរោងជាង និងធានាឱ្យសម្ភាររូបវន្តសម្រាប់ការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈទាំងនេះ ឆ្លើយតបទៅតាមស្តង់ដាគុណភាព។ |
| | **២.២.១គ** រៀបចំ និងអនុវត្តគម្រោងគាំទ្រសិស្ស ការផ្តល់ការលើកទឹកចិត្ត ឬ អាហារូបករណ៍ ជាពិសេសកុមារី កុមារមកពីគ្រួសារក្រីក្រ និងសហគមន៍ជួបការលំបាក។ |
| **២.២.២** បង្កើនគុណភាព និងភាពឆ្លើយតបនៃកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្រិតមធ្យមសិក្សាទុតិយភូមិ | **២.២.២ក** រៀបចំស្តង់ដាគុណភាពសម្រាប់កម្មវិធីអប់រំបណ្តុះ-បណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អ្នកបណ្តុះបណ្តាល សម្ភាររូបវន្ត និងសិស្សដែលបញ្ចប់ការសិក្សាពីកម្មវិធីនេះ។ |

| | |
|---|---|
| | **២.២.២ខ** តម្រឹមកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឱ្យស្របទៅតាមក្របខណ្ឌគុណវុឌ្ឍិកម្ពុជា និងរៀបចំឱ្យមានគន្លងបត់បែនសម្រាប់សិស្សដែលចូលរួមក្នុងកម្មវិធីនេះ។ |
| | **២.២.២គ** រៀបចំ កែសម្រួល និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា សៀវភៅសិក្សា និងធនធានរៀនសម្រាប់កម្មវិធីអប់រំបណ្តុះ-បណ្តាលវិជ្ជាជីវៈ តាមមុខវិជ្ជានានា ដើម្បីបំពេញតម្រូវការទីផ្សារការងារ។ |
| | **២.២.២ឃ** ធ្វើបច្ចុប្បន្នភាពគុណវុឌ្ឍិ និងគុណវុឌ្ឍិវិជ្ជាជីវៈគ្រូបង្រៀន និងអ្នកបណ្តុះបណ្តាលក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។ |
| | **២.២.២ង** រៀបចំ និងអនុវត្តកម្មវិធីអន្តរកាលពីសាលារៀនទៅកន្លែងធ្វើការ។ |

### *៤.៥.៣. ការអប់រំកម្រិតឧត្តមសិក្សា*

**អាទិភាពទី ៣៖**

ធានាឱ្យស្ត្រី និងបុរសទាំងអស់ មានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងឧត្តមសិក្សា ប្រកបដោយគុណភាព។

ការអប់រំឧត្តមសិក្សា គឺជាកម្លាំងចលករដ៏សំខាន់នៃការប្រកួតប្រជែងសេដ្ឋកិច្ចនៅក្នុងបរិបទសេដ្ឋកិច្ចពុទ្ធិសកលលោកបច្ចុប្បន្ន។ ការអប់រំឧត្តមសិក្សារួមចំណែកដល់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចតាមរយៈការកសាងធនធានមនុស្ស ការអភិវឌ្ឍចំណេះដឹង និងការផ្ទេរចំណេះដឹង។ វិសាលភាព និងសារៈសំខាន់នៃការអប់រំឧត្តមសិក្សាមានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ ការអប់រំឧត្តមសិក្សាកាន់តែសម្បូរបែប និងគ្រប់ប្រភេទនៃគ្រឹះស្ថានសិក្សាដូចជាសាកលវិទ្យាល័យ វិទ្យាស្ថានពហុបច្ចេកទេស ឬ ពហុបច្ចេកវិទ្យាជាដើម។ គ្រឹះស្ថានឧត្តមសិក្សា អាចបំពេញតម្រូវការនៃធនធានមនុស្សគ្រប់ប្រភេទ និងគ្រប់កម្រិតទាំងអស់របស់ខ្លួន។ ផ្អែកតាមចក្ខុវិស័យកម្ពុជាដែលក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់ឆ្នាំ២០៥០ គឺជាពេលវេលាសមស្របសម្រាប់កម្ពុជារៀបចំនូវចក្ខុវិស័យដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡាគ្នាអំពីការអប់រំឧត្តមសិក្សានាពេលអនាគត និងតម្រង់ទិសការអភិវឌ្ឍការអប់រំឧត្តមសិក្សាឱ្យស្របជាមួយនឹងគោលដៅសង្គម និងសេដ្ឋកិច្ចរបស់ប្រទេស។ ដូចនេះ ត្រូវធានាថា គ្រឹះស្ថានឧត្តមសិក្សាមានសមត្ថភាព

គ្រប់គ្រាន់ មិនត្រឹមតែសម្រាប់ការបង្រៀន និងរៀនប៉ុណ្ណោះទេ ថែមទាំងការស្រាវជ្រាវ និងការអភិវឌ្ឍ ព្រមទាំងនវានុវត្តន៍ផងដែរ។ ចំណុចសំខាន់បំផុត គឺចាំបាច់ត្រូវមានការប្ដេជ្ញាចិត្តកម្រិតជាតិ ដើម្បីបង្កើន គុណភាព និងភាពឆ្លើយតប ក៏ដូចជាធានានូវសមធម៌នៃការអប់រំឧត្តមសិក្សា។ ក្នុងន័យនេះ រាជរដ្ឋាភិបាល មានបំណងលើកកម្ពស់ការទទួលបានការអប់រំវិជ្ជាជីវៈ និងការអប់រំកម្រិតឧត្តមសិក្សា ព្រមទាំងការអប់រំ នៅតាមសាកលវិទ្យាល័យផង ប្រកបដោយគុណភាពសម្រាប់បុរស និងស្ត្រីគ្រប់រូប ដែលជាចំណុចដៅ មួយនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។

### *គ. ការអប់រំឧត្តមសិក្សា*

**លទ្ធផលរំពឹងទុក ៣.១**

ស្ត្រី និងបុរសគ្រប់រូបកាន់តែទទួលបានការអប់រំឧត្តមសិក្សាប្រកដោយគុណភាព។

ការអប់រំឧត្តមសិក្សា ជារឿយៗ ត្រូវបានចាត់ទុកជាចលករនៃការអភិវឌ្ឍនៅក្នុងសេដ្ឋកិច្ចពុទ្ធិ សម័យថ្មី។ បែបផែនថ្មីៗនៃផលិតកម្មសេដ្ឋកិច្ចកាន់តែពឹងអាស្រ័យលើចំណេះដឹង និងបច្ចេកវិទ្យា ព័ត៌មាន។ បទពិសោធន៍ពីបណ្ដាប្រទេសអាស៊ីបូព៌ាមួយចំនួន បង្ហាញថា ការវិនិយោគទ្រង់ទ្រាយធំលើ ការអប់រំចំណេះទូទៅ និងជាពិសេសការអប់រំឧត្តមសិក្សា រួមចំណែកពន្លឿនកំណើនសេដ្ឋកិច្ចឱ្យកាន់តែ ឆាប់រហ័ស។ ការអប់រំឧត្តមសិក្សាមានសារៈសំខាន់ ជាពិសេសក្នុងពេលដែលប្រទេសកំពុងខិតខំធ្វើ ទំនើបកម្ម និងពិពិធកម្មសេដ្ឋកិច្ចរបស់ខ្លួន និងបោះជំហានទៅរកគំរូផលិតកម្មដែលមានគុណតម្លៃ កាន់តែខ្ពស់។ ប៉ុន្តែគួរកត់សម្គាល់ថា ការវិនិយោគលើការអប់រំឧត្តមសិក្សាតែឯង គឺមិនទាន់គ្រប់គ្រាន់ នោះឡើយ។ សំខាន់ដូចគ្នានឹងការវិនិយោគលើការអប់រំឧត្តមសិក្សាដែរ ចាំបាច់ត្រូវមានការយកចិត្ត ទុកដាក់លើប្រសិទ្ធភាព និងភាពស័ក្ដិសិទ្ធិនៃការវិនិយោគនោះ ដូចជា ធានាឱ្យមានការភ្ជាប់ទំនាក់ទំនង បានសមស្របជាមួយនឹងតម្រូវការទីផ្សារការងាររបស់សេដ្ឋកិច្ច។ បរិបទនេះ និងស្របតាមចំណុចដៅ ៤.៣ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤-ការអប់រំឆ្នាំ២០៣០ កម្ពុជាបានលើកឡើងពីការ បង្កើនលទ្ធភាពទទួលបានការអប់រំឧត្តមសិក្សា ប្រកបដោយគុណភាពសម្រាប់ស្ត្រី និងបុរសគ្រប់រូប។

កម្ពុជាបានពង្រីកបរិមាណនៃការអប់រំឧត្តមសិក្សាយ៉ាងឆាប់រហ័ស ក្នុងរយៈពេលប៉ុន្មានឆ្នាំ ចុងក្រោយនេះ។ ក្នុងគោលបំណងកែលម្អគុណភាពនៃការអប់រំឧត្តមសិក្សា និងបង្កើនភាពឆ្លើយតបនៃ ការអប់រំឧត្តមសិក្សាទៅនឹងតម្រូវការនៃទីផ្សារការងារ និងសង្គម កម្ពុជាបានរៀបចំនូវផែនទីបង្ហាញផ្លូវ សម្រាប់ការអប់រំឧត្តមសិក្សា និងបានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់ជាច្រើន ដើម្បីធ្វើឱ្យប្រសើរ ឡើងនូវការសម្របសម្រួល អភិបាលកិច្ច ការផ្ដល់ហិរញ្ញប្បទាន និងស្វ័យភាព។ ផែនទីបង្ហាញផ្លូវនេះ

មានគោលបំណងសម្រេចឱ្យបាននូវគុណភាពនៃការអភិវឌ្ឍការអប់រំឧត្តមសិក្សា។ យុទ្ធសាស្ត្រជាច្រើនត្រូវបានស្នើឡើងដើម្បីអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា ឱ្យក្លាយជាមជ្ឈមណ្ឌលឧត្តមភាពដែលជំរុញឱ្យមាននវានុវត្តន៍ ដើម្បីបំពេញទៅតាមតម្រូវការកម្លាំងពលកម្ម ពង្រឹងសមត្ថភាពស្រាវជ្រាវ បង្កើនចំណេះដឹង តាមរយៈការបង្កើនឱកាសអប់រំឧត្តមសិក្សាដល់យុវជន។

ទន្ទឹមនោះដែរ ក៏មានការទទួលស្គាល់ថា ការអប់រំឧត្តមសិក្សាត្រូវបានគ្រប់គ្រងបានល្អនិងសម្របសម្រួលសមស្រប ដែលផ្តល់ឱ្យនិស្សិតទទួលបានការអប់រំ ប្រកបដោយបរិយាបន្ន និងសមធម៌។ ការអប់រំឧត្តមសិក្សា ក៏មានច្រើនមុខជំនាញ និងអាចធានាបាននូវនិរន្តរភាពផ្នែកហិរញ្ញវត្ថុ ដោយសារតែមានកម្មវិធីផ្តល់ហិរញ្ញប្បទានសមស្រប និងភាពជាដៃគូជាច្រើន។ សម្ព័ន្ធភាពជាដៃគូនឹងត្រូវបង្កើតឡើងជាមួយនឹងសាកលវិទ្យាល័យថ្នាក់តំបន់ និងអន្តរជាតិ ដើម្បីពង្រឹងសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាទាក់ទិនទៅនឹងគុណភាព ការស្រាវជ្រាវរួមគ្នា និងការបណ្តុះបណ្តាលសាស្ត្រាចារ្យ។ល។ កម្មវិធីអាហារូបករណ៍ និងកម្មវិធីផ្តល់កម្ចីសិក្សាដល់និស្សិតនឹងត្រូវអនុវត្តដើម្បីផ្តល់លទ្ធភាពឱ្យនិស្សិតស្រី និស្សិតមកពីគ្រួសារក្រីក្រ និស្សិតជនជាតិដើមភាគតិច និងនិស្សិតពិការទទួលបានឱកាសសិក្សា។ លើសពីនេះ នឹងមានការផ្តោតការយកចិត្តទុកដាក់លើការបង្កើនសមត្ថភាពស្រាវជ្រាវ និងអភិវឌ្ឍន៍ ដើម្បីជំរុញលើកកម្ពស់វប្បធម៌នវានុវត្តន៍ ដែលជួយគាំទ្រដល់ការផ្លាស់ប្តូរសេដ្ឋកិច្ចរបស់ប្រទេស។ លើសពីនេះទៀត ក៏នឹងមានការផ្តោតការយកចិត្តទុកដាក់ផងដែរលើការស្រាវជ្រាវប្រកបដោយគុណភាពខ្ពស់តាមរយៈការសហការជាមួយនឹងវិស័យឯកជន។ គុណភាពនៃការស្រាវជ្រាវ និងការបណ្តុះបណ្តាលនឹងត្រូវពង្រឹងបន្ថែម ជាពិសេសផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។ មូលនិធិស្រាវជ្រាវជាតិនឹងត្រូវបង្កើតឡើងដើម្បីជំរុញលើកទឹកចិត្តឱ្យមានការស្រាវជ្រាវ និងនវានុវត្តន៍។

ផ្អែកតាមការព្យាករណ៍បង្ហាញថា ចំនួននិស្សិតឧត្តមសិក្សាកម្ពុជានឹងកើនឡើងទ្វេដងនៅឆ្នាំ ២០៣០ បើធៀបនឹងចំនួននិស្សិតចូលរៀននៅឆ្នាំ ២០១៥ (តារាងទី១៣)។ អត្រារួមនៃការសិក្សានៅឧត្តមសិក្សាបច្ចុប្បន្ន គឺត្រឹមតែ ១១,៦ ភាគរយ ប៉ុណ្ណោះ ហើយការធ្វើចំណោលថា នឹងកើនឡើង ២៥ ភាគរយ ឆ្នាំ ២០៣០។

### តារាងទី ១៣៖ ចំណុចដៅសំខាន់ៗ សម្រាប់ការអប់រំឧត្តមសិក្សា

| សូចនាករ | ទិន្នន័យគោល | ចំណុចដៅ ២០១៩-២០២៣ | ចំណុចដៅ ២០២៤-២០២៨ | ចំណុចដៅ ២០៣០ |
|---|---|---|---|---|
| អត្រារួមនៃការសិក្សានៅកម្រិតឧត្តមសិក្សា | ១១,៦% (២០១៨) | ១៦,៩% | ២២,៧% | ២៥,0% |

*យុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវបានស្នើឡើង*

តារាងទី១៤ រៀបរាប់ពីយុទ្ធសាស្ត្រ និងសកម្មភាពដែលរួមចំណែកដល់ការកែលម្អការអប់រំនៅឧត្តមសិក្សា។

**តារាងទី ១៤៖ យុទ្ធសាស្ត្រសម្រាប់កែលម្អការអប់រំឧត្តមសិក្សា**

| យុទ្ធសាស្ត្រ | សកម្មភាព |
|---|---|
| **៣.១.១** ពង្រីកការផ្តល់សេវាអប់រំកម្រិតឧត្តមសិក្សាតាមរយៈអន្តរាគមន៍ជាច្រើន ដើម្បីបង្កើនចំនួននិស្សិតដែលចូលរៀននៅឧត្តមសិក្សា តាមរយៈការផ្តល់លទ្ធភាពឱ្យនិស្សិតក្រីក្រ និងនិស្សិតដែលមានសមត្ថភាពអាចទទួលបានការអប់រំឧត្តមសិក្សាដោយមិនគិតពីសាវតារសង្គម និងសេដ្ឋកិច្ចរបស់ពួកគេ។ | **៣.១.១ក** អភិវឌ្ឍ កែលម្អហេដ្ឋរចនាសម្ព័ន្ធនៅតាមគ្រឹះស្ថានឧត្តមសិក្សា ដើម្បីបង្កើនសមត្ថភាពគ្រឹះស្ថានក្នុងការទទួលយកនិស្សិតចូលរៀនឱ្យបានច្រើន ដូចជាការផ្តល់សេវាគាំទ្រដល់និស្សិតជាដើម (ការផ្តល់ប្រឹក្សាបណ្ណាល័យ អន្តេវាសិកដ្ឋាន សម្ភារូបវ័ន្តផ្នែកវេជ្ជសាស្ត្រ)។ |
| | **៣.១.១ខ** រៀបចំ និងអនុវត្តកម្មវិធីអាហារូបករណ៍ទៅតាមតម្រូវការ និងទៅតាមលក្ខណៈសម្បត្តិរបស់សិស្ស និងបង្កើតកម្មវិធីផ្តល់កម្ចីនិស្សិតនៅកម្រិតឧត្តមសិក្សាដែលផ្តោតគោលដៅលើនិស្សិតស្រី និស្សិតពិការ និស្សិតក្រីក្រ និងនិស្សិតជួបការលំបាក។ |
| | **៣.១.១គ** បង្កើតកម្មវិធីអាហារូបករណ៍ថ្នាក់ជាតិតាមរយៈការកៀរគរធនធានពីវិស័យឯកជន ដៃគូអភិវឌ្ឍ អង្គការអន្តរជាតិ សប្បុរសជន និងអង្គការសង្គមស៊ីវិល ដើម្បីបង្កើនចំនួនអាហារូបករណ៍សិក្សាក្នុងប្រទេស និងក្រៅប្រទេសតាមមុខវិជ្ជាសំខាន់ៗ ជាការឆ្លើយតបទៅនឹងគោលនយោបាយឧស្សាហកម្ម។ |
| **៣.១.២** បង្កើនគុណភាពនៃកម្មវិធីអប់រំឧត្តមសិក្សាតាមរយៈកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈ អភិវឌ្ឍសមត្ថភាពអប់រំរបស់សាស្ត្រាចារ្យ កែលម្អកម្មវិធីសិក្សា និងតម្រឹមកម្មវិធីសិក្សាឱ្យស្របទៅតាមការផ្លាស់ប្តូរតម្រូវការនៃសកលលោក ក៏ដូចជាកែលម្អសម្ភារូបវ័ន្តដែលប្រើប្រាស់សម្រាប់ការសិក្សា។ | **៣.១.២ក** អភិវឌ្ឍសាកលវិទ្យាល័យ គ្រឹះស្ថានសិក្សាមួយចំនួនឱ្យក្លាយទៅជាមជ្ឈមណ្ឌលឧត្តមភាព ដើម្បីលើកកម្ពស់គុណភាពនៃការបង្រៀន ការស្រាវជ្រាវនវានុវត្តន៍ និងការរៀនសូត្រដែលមានគុណភាពខ្ពស់ ដែលអាចបំពេញទៅតាមស្តង់ដានៅថ្នាក់តំបន់ អន្តរជាតិ។ |
| | **៣.១.២ខ** អនុវត្តកម្មវិធីអភិវឌ្ឍន៍សមត្ថភាពសាស្ត្រាចារ្យដើម្បីបំពាក់បំប៉នឱ្យពួកគេនូវគោលវិធី វិធីសាស្ត្រ និងបច្ចេកទេសគរុកោសល្យតាមបែបទំនើប និងបង្កើន |

| | |
|---|---|
| | សមត្ថភាពប្រើប្រាស់បច្ចេកវិទ្យានិងសារគមនាគមន៍របស់ពួកគេ។ |
| | **៣.១.២គ** អភិវឌ្ឍ កែលម្អ កែសម្រួលកម្មវិធីសិក្សា សៀវភៅ-សិក្សា និងឯកសាររៀន ដើម្បីតម្រឹមការអប់រំឧត្តមសិក្សាឱ្យស្របទៅតាមតម្រូវការទីផ្សារការងារ ព្រមទាំងបញ្ចូលបំណិនពាក់ព័ន្ធនឹងការគិត និងបំណិនមិនពាក់ព័ន្ធនឹងការគិត គុណតម្លៃ សមត្ថភាពទៅក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិរបស់ប្រទេសកម្ពុជា។ |
| | **៣.១.២ឃ** បង្កើតភាពបត់បែននៃការរៀនសូត្រ តាមរយៈគម្រោងផ្ទេរក្រេឌីតពេញលេញ ដែលអនុញ្ញាតឱ្យនិស្សិតអាចប្តូររវាងការងារ និងការអប់រំឧត្តមសិក្សា និងអនុញ្ញាតឱ្យគេបន្តការសិក្សាកំឡុងពេលពួកគេកំពុងធ្វើការងារ។ |
| | **៣.១.២ង** ពង្រឹងមុខងារស្រាវជ្រាវនៅឧត្តមសិក្សា និងតាមសាកលវិទ្យាល័យ និងអភិវឌ្ឍសមត្ថភាពបុគ្គលិក និងនិស្សិតឱ្យចេះធ្វើការស្រាវជ្រាវ ព្រមទាំងដាក់ឱ្យអនុវត្តនូវកម្មវិធីថ្នាក់បណ្ឌិតសម្រាប់មុខវិជ្ជាជាអាទិភាព និងកែលម្អទំនាក់ទំនងរវាងសាកលវិទ្យាល័យ និងឧស្សាហកម្ម។ |
| | **៣.១.២ច** លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យានៅឧត្តមសិក្សា ដូចជាវគ្គសិក្សាចំហរតាមប្រព័ន្ធអ៊ីនធឺណិត និងវគ្គសិក្សាទម្រង់ផ្សេងទៀត។ |
| | **៣.១.២ឆ** លើកកម្ពស់ការអប់រំវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យានៅឧត្តមសិក្សាតាមរយៈការពង្រឹងការបង្រៀន និងរៀនមុខវិជ្ជាទាំងនោះ និងពង្រីកកម្មវិធីនេះដើម្បីបំពេញទៅតាមតម្រូវការនៃការអភិវឌ្ឍជាតិ។ |
| | **៣.១.២ជ** បង្កើតមូលនិធិជាតិសម្រាប់ស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីជំរុញលើកទឹកចិត្តឱ្យមានការស្រាវជ្រាវ និងនវានុវត្តន៍។ |

| | |
|---|---|
| **៣.១.៣** លើកកម្ពស់អភិបាលកិច្ច និងការគ្រប់គ្រងអនុវិស័យឧត្តមសិក្សា តាមរយៈការពង្រឹងការសម្របសម្រួល ការរៀបចំផែនការហិរញ្ញប្បទានមុខងាររដ្ឋបាល និងមុខងារពិនិត្យតាមដាន។ | **៣.១.៣ក** រៀបចំក្របខណ្ឌច្បាប់សមស្រប ផ្តោតការសម្របសម្រួលជារួម ការដឹកនាំ និងអភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា សាកលវិទ្យាល័យ និងបង្កើតយន្តការសម្រាប់ស្វ័យភាព និងគណនេយ្យភាពស្ថាប័ន។ |
| | **៣.១.៣ខ** ពង្រឹងសមត្ថភាពស្ថាប័ននិយ័តកម្ម និងស្ថានប័នត្រួតពិនិត្យ ដើម្បីធ្វើការគ្រប់គ្រង ផ្តល់ការទទួលស្គាល់គុណភាពត្រួតពិនិត្យនិងផ្តល់ការគាំទ្រដល់ការអភិវឌ្ឍអនុវិស័យឧត្តមសិក្សា ព្រមទាំងបុគ្គលិកគ្រប់គ្រងនិងបុគ្គលិកដែលមិនធ្វើការពាក់ព័ន្ធនឹងការសិក្សា។ |
| | **៣.១.៣គ** រៀបចំបង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងឧត្តមសិក្សា និងដាក់ឱ្យអនុវត្តប្រព័ន្ធធានាគុណភាព (ផ្ទៃក្នុង និងខាងក្រៅ)។ |
| **៣.១.៤** លើកកម្ពស់ការធ្វើអន្តរជាតិភាវូបនីយកម្មនៃការអប់រំឧត្តមសិក្សា ដើម្បីពង្រឹងគុណភាពសមត្ថភាពប្រកួតប្រជែង ការផ្សព្វផ្សាយ និងនវានុវត្តន៍ ជាពិសេសតាមរយៈការសហការជាមួយនឹងគ្រឹះស្ថានឧត្តមសិក្សានានា នៅក្នុងតំបន់អាស៊ាន។ | **៣.១.៤ក** លើកកម្ពស់ឱ្យមានការប្តូរនិស្សិតនិងសាស្ត្រាចារ្យខាងក្នុងនិងក្រៅប្រទេស។ |
| | **៣.១.៤ខ** រៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីផ្តល់សញ្ញាបត្ររួមគ្នា ការរៀបចំការបណ្តុះបណ្តាលនៅសាកលវិទ្យាល័យពីរក្នុងពេលតែមួយ និងបង្កើតកម្មវិធីដែលជាសាខារបស់សាកលវិទ្យាល័យបរទេស និងរៀបចំឱ្យមានការផ្ទេរក្រេឌីតជាមួយនឹងសាកល-វិទ្យាល័យបរទេស ជាពិសេសសាកលវិទ្យាល័យនៅអាស៊ាន និងអាស៊ីប៉ាស៊ីហ្វិច។ |

### *ខ. ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ*

**លទ្ធផលរំពឹងទុក ៣.២**

ស្ត្រី និងបុរសគ្រប់រូប កាន់តែអាចទទួលបានការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយគុណភាព និងទទួលបានជំនាញពាក់ព័ន្ធសម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់ទីផ្សារការងារ។

ប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលរបស់កម្ពុជាពុំទាន់បានឆ្លើយតបទៅនឹងតម្រូវការឧស្សាហកម្ម និងសហគ្រាសនៅឡើយ ហើយបញ្ហាប្រឈមខ្លះៗកើតឡើងដោយសារអត្រាបោះបង់ការសិក្សាខ្ពស់

អត្រាបញ្ចប់ការសិក្សាក្នុងកម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈមានកម្រិតទាប កម្មវិធីសិក្សាមិនទាន់ឆ្លើយតបសង្គមផ្តល់តម្លៃទាបដល់ការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ និងទំនាក់ទំនងរវាងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ និងឧស្សាហកម្មមានកម្រិតខ្សោយ។ កម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ផ្តោតតែលើជំនាញពាក់ព័ន្ធនឹងការងារមួយចំនួនតូចតែប៉ុណ្ណោះ ដែលធ្វើឱ្យសិស្សនិស្សិតពិបាកនឹងសម្របខ្លួនទៅតាមការផ្លាស់ប្តូរយ៉ាងឆាប់រហ័សក្នុងទីផ្សារការងារ។

ផែនទីបង្ហាញផ្លូវលើកឡើងថា កម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈគួរតែរៀបចំតាមតម្រូវការពោលគឺ ត្រូវផ្តល់ជំនាញ និងសមត្ថភាពឆ្លើយតបនឹងត្រូវការការងារ។ កម្មវិធីសិក្សាអប់រំបច្ចេកទេស និងវិជ្ជាជីវៈនឹងត្រូវកែសម្រួល និងធ្វើបច្ចុប្បន្នភាពដើម្បីធានាឱ្យកម្មវិធីសិក្សាអាចផ្តល់នូវសមត្ថភាព និងឆ្លើយតបទៅតាមតម្រូវការនៃទីផ្សារការងារ។ កម្មវិធីជាអាទិភាព គឺកម្មវិធីដែលផ្តោតលើបំណិនពាក់ព័ន្ធនឹងការគិត និងបំណិនមិនពាក់ព័ន្ធនឹងការគិតកម្រិតខ្ពស់ ឬ បំណិននានាទាក់ទងនឹងភាពច្នៃប្រឌិតការដោះស្រាយបញ្ហា ការធ្វើការងារជាក្រុម ការប្រាស្រ័យទាក់ទង និងដោះស្រាយជម្លោះ។ ដូចនេះកម្ពុជាបានស្នើឱ្យមានការរៀបចំរចនាសម្ព័ន្ធអនុវិស័យនេះសារជាថ្មី ដើម្បីអាចផ្តល់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈឱ្យកាន់តែឆ្លើយតបប្រកបដោយគុណភាពខ្ពស់ និងធានាឱ្យមានកម្មករជំនាញដែលអាចបំពេញតាមស្តង់ដាអប់រំបច្ចេកទេស និងវិជ្ជាជីវៈនៅកម្រិតអន្តរជាតិ និងកម្រិតអាស៊ាន។ ទន្ទឹមនេះដែររំពឹងថា ការទទួលបានការអប់រំបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាពនឹងកើនឡើង និងសិស្សនិស្សិតដែលរៀនចប់ពីកម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈនឹងទទួលបានជំនាញកាន់តែឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។

### *យុទ្ធសាស្ត្រ និងសកម្មភាពដែលបានស្នើឡើង*

យុទ្ធសាស្ត្រជាច្រើនត្រូវបានលើកឡើង ដើម្បីសម្រេចលទ្ធផលដែលពាក់ព័ន្ធនឹងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ (តារាងទី១៥)។

**តារាងទី ១៥៖ យុទ្ធសាស្ត្រសម្រាប់កែលម្អការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ**

| យុទ្ធសាស្ត្រ | សកម្មភាព |
|---|---|
| **៣.២.១** ពង្រីកការផ្តល់សេវាអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ដោយផ្តោតការយកចិត្តទុកដាក់ ជាពិសេសលើតម្រូវការរបស់ស្ត្រី ក្រុមបាត់បង់ឱកាស យុវជនក្រីក្រ និងអ្នកបោះបង់ការសិក្សា។ | **៣.២.១ក** បង្កើតគន្លងសិក្សាដែលមានភាពបត់បែនដូចដែលបានលើកឡើងក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិតាមរយៈការទទួលស្គាល់ចំណេះដឹងកន្លងមក កម្មវិធីស្ពានចម្លង និងការរៀបចំកាលវិភាគសិក្សាដែលមានលក្ខណៈច្នៃប្រឌិតថ្មី។ល។ |

| | |
|---|---|
| | **៣.២.១ខ** បង្កើតកម្មវិធីអាហារូបករណ៍ ដោយកំណត់គោលនយោបាយស្តីពីថ្លៃសេវាឱ្យបានច្បាស់លាស់ និងកម្មវិធីផ្តល់កម្ចីសិក្សា ដើម្បីជួយដល់និស្សិតក្រីក្រ ជាពិសេសសិស្សស្រី និងនិស្សិតស្រី។ |
| | **៣.២.១គ** លើកកម្ពស់មុខមាត់នៃការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីបង្កើនភាពទាក់ទាញដល់សិស្ស និស្សិត គ្រួសារ និយោជក និងអ្នកពាក់ព័ន្ធដទៃទៀត និងបង្កើនការយល់ដឹងអំពីប្រព័ន្ធអប់រំបច្ចេកទេស វិជ្ជាជីវៈ និងសារៈសំខាន់នៃប្រព័ន្ធនេះនៅក្នុងគ្រប់កម្រិតទាំងអស់នៃសង្គម តាមរយៈកម្មវិធីបង្កើនការយល់ដឹងតាមប្រព័ន្ធផ្សព្វផ្សាយ ការពិគ្រោះយោបល់ ការផ្តល់ការណែនាំអាជីព ការចុះអប់រំផ្សព្វផ្សាយដល់សហគមន៍។ល។ |
| **៣.១.២** បង្កើនគុណភាព និងភាពឆ្លើយតបនៃកម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីបំពេញតម្រូវការទីផ្សារការងារ។ | **៣.១.២ក** ពង្រឹងការអនុវត្តប្រព័ន្ធធានាគុណភាព ផ្អែកតាមក្របខណ្ឌគុណវុឌ្ឍិកម្ពុជា។ |
| | **៣.១.២ខ** កែលម្អកម្មវិធីសិក្សាអប់រំបច្ចេកទេស និងវិជ្ជាជីវៈ និងកម្មវិធីបណ្តុះបណ្តាលនានាដើម្បីបង្កើនគុណភាព ភាពពាក់ព័ន្ធនិងភាពឆ្លើយតប តាមរយៈការបញ្ចូលជំនាញដែលពាក់ព័ន្ធនឹងការងារ ជំនាញធ្វើការងារជាក្រុម ប្រាស្រ័យទាក់ទង ដោះស្រាយបញ្ហា ព្រមទាំងជំនាញសហគ្រិនភាព និងជំនាញបច្ចេកវិទ្យា និងសារគមនាគមន៍។ |
| | **៣.១.២គ** រៀបចំ និងដាក់ឱ្យអនុវត្តនូវកម្មវិធីបណ្តុះ-បណ្តាលដើម្បីបង្កើនគុណភាពគ្រូនិងអ្នកបណ្តុះបណ្តាលអំពីវិធីសាស្ត្របង្រៀន ការវាយតម្លៃការសិក្សា និងការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ ព្រមទាំងជំនាញបច្ចេកទេសផងដែរ។ |
| **៣.១.៣** លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន និងពង្រឹងភាពជាដៃគូជាមួយអ្នកផ្តល់សេវានានា។ | **៣.១.៣ក** ពិនិត្យឡើងវិញលើភាពជាដៃគូរវាងសាធារណៈនិងឯកជន និងពង្រឹងភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ដើម្បីបង្កើនការផ្លាស់ប្តូរ |

| | |
|---|---|
| | ការចែករំលែក និងការចូលរួមក្នុងការអភិវឌ្ឍកម្មវិធី-សិក្សាសម្រាប់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ កម្មវិធីហាត់ការ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ល។ |
| **៣.១.៤** ពង្រឹងការគ្រប់គ្រង ការសម្របសម្រួល និងអភិបាលកិច្ច ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។ | **៣.១.៤ក** រៀបចំផែនការកែលម្អ និងពង្រឹងការរៀបចំផែនការ ការអភិវឌ្ឍគោលនយោបាយ និងការពិនិត្យតាមដាន និងការវាយតម្លៃការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ។ |
| | **៣.១.៤ខ** រៀបចំ និងពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ និងប្រព័ន្ធព័ត៌មានទីផ្សារការងារ និងប្រើប្រាស់ព័ត៌មាននេះសម្រាប់រៀបចំផែនការ និងកម្មវិធីនានា។ |
| | **៣.១.៤គ** ពង្រឹងតួនាទីរបស់គណៈកម្មាធិការជាតិបណ្ដុះបណ្ដាលដើម្បីលើកកម្ពស់ក្នុងការសម្របសម្រួលរវាងក្រសួងជំនាញ ស្ថាប័នពាក់ព័ន្ធ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។ |

### *៤.៥.៤. អក្ខរកម្មយុវជន និងមនុស្សពេញវ័យ*

***អាទិភាពទី ៤៖***

យុវជន និងមនុស្សពេញវ័យទាំងអស់ ទទួលបានចំណេះដឹងអក្ខរកម្ម និងលេខនព្វន្ត ហើយអ្នកសិក្សាគ្រប់វ័យទាំងអស់កាន់តែមានឱកាសច្រើនឡើងក្នុងការសិក្សាពេញមួយជីវិត។

អក្ខរកម្ម គឺជាសិទ្ធិមនុស្សជាមូលដ្ឋាន និងជាគ្រឹះសម្រាប់ការសិក្សាពេញមួយជីវិត។ អក្ខរកម្មមានតួនាទីយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ព្រមទាំងជួយធ្វើឱ្យជីវិតមានការផ្លាស់ប្ដូរ។ ចំពោះបុគ្គល គ្រួសារ និងសង្គម អក្ខរកម្ម គឺជាមធ្យោបាយផ្ដល់សិទ្ធិអំណាចដែលជួយលើកកម្ពស់សុខភាព បង្កើនប្រាក់ចំណូល និងលើកកម្ពស់ទំនាក់ទំនងរវាងមនុស្សម្នាក់ៗជាមួយនឹងពិភពលោកទាំងមូល។ ចំណេះដឹងនិងបំណិនអក្ខរកម្មកម្រិតមូលដ្ឋាន គឺមិនទាន់គ្រប់គ្រាន់នៅឡើយសម្រាប់ពិភពលោកបច្ចុប្បន្ន។ ឆ្លើយតបនឹងស្ថានភាពការងារប្រែប្រួល សកលភាវូបនីយកម្មទីផ្សារ និងការធ្វើអន្តរកាលទៅរកសេដ្ឋកិច្ចផ្អែកលើព័ត៌មាន ការចេះអាននិងសរសេរ គឺមិនទាន់គ្រប់គ្រាន់ដើម្បីអាចធ្វើការងារឱ្យបានល្អនោះឡើយ។ មនុស្សពេញវ័យដែលមានបំណិនអក្ខរកម្មអក្សរ និងលេខនព្វន្តនៅកម្រិតទាប

ត្រូវជួបការលំបាកច្រើន។ បំណិនអក្ខរកម្មកម្រិតទាប គឺជាកង្វល់របស់ប្រទេសជាច្រើន រាប់បញ្ចូលទាំងប្រទេសដែលមានចំណូលមធ្យម និងប្រទេសដែលមានចំណូលខ្ពស់ផងដែរ។ ហេតុនេះ បានជាចំណុចដៅ ៤.៦ លើកឡើងថា "ត្រឹមឆ្នាំ២០៣០ យុវជន និងមនុស្សពេញវ័យគ្រប់រូបទូទាំងពិភពលោក ត្រូវសម្រេចឱ្យបាននូវបំណិនអក្ខរកម្មវិជ្ជាជីវៈផ្នែកអក្សរ និងលេខនព្វន្ត ដែលមានកម្រិតសមមូលនឹងការបញ្ចប់ការអប់រំកម្រិតមូលដ្ឋានប្រកបដោយជោគជ័យ"។

### *ក. អក្ខរកម្មវិជ្ជាជីវៈ*

**លទ្ធផលរំពឹងទុក ៤.១**

យុវជន និងមនុស្សពេញវ័យ ត្រូវសម្រេចឱ្យបាននូវបំណិនអក្ខរកម្មវិជ្ជាជីវៈផ្នែកអក្សរ និងលេខនព្វន្ត ដែលពាក់ព័ន្ធក្នុងកម្រិតដែលមានការទទួលស្គាល់សមមូលនឹងការបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន ប្រកបដោយជោគជ័យ។

អក្ខរកម្មមានតួនាទីយ៉ាងសំខាន់សម្រាប់ការទទួលបានជោគជ័យនៅក្នុងសម័យទំនើប និង ត្រូវបានចាត់ទុកថាជាសិទ្ធិមនុស្សជាមូលដ្ឋាន។ អក្ខរកម្មផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការសិក្សាពេញមួយជីវិត។ អក្ខរកម្មផ្តល់នូវអត្ថប្រយោជន៍ផ្នែកសង្គម និងសេដ្ឋកិច្ចជាច្រើន។ អក្ខរកម្មរួមចំណែកធ្វើឱ្យមានកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ លើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងជំរុញការចូលរួមរបស់ពលរដ្ឋ ក៏ដូចជាបង្ការជម្ងឺនានា។ បំណិនអក្ខរកម្មមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការការពារបរិស្ថាន ការអភិវឌ្ឍសង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព។ មនុស្សពេញវ័យដែលមានបំណិនអក្ខរកម្មលេខនព្វន្ធ និងអក្សរក្នុងកម្រិតមួយទាប ជួបនឹងការលំបាកច្រើនយ៉ាង។ អក្ខរកម្មគឺ ជាទស្សនាទានដែលមានលក្ខណៈរស់រវើក និងមានបំណិនហួសពីការអាន និងសរសេរទៅទៀត។ ក្នុងបរិបទនេះ របៀបវារៈអប់រំឆ្នាំ២០៣០ អំពាវនាវឱ្យមានការធានាថា យុវជន និងមនុស្សពេញវ័យគ្រប់រូបទទួលបានបំណិនវិជ្ជាជីវៈក្នុងកម្រិតដែលសមមូលទៅនឹងការអប់រំកម្រិតមូលដ្ឋាន។ ស្របតាមរបៀបវារៈសកលក្រសួងអប់រំ យុវជន និងកីឡាព្យាករណ៍ថា អត្រាអក្ខរកម្មមនុស្សពេញវ័យនឹងត្រូវកើនពី ៨២,៥ ភាគរយដល់ ៩៥,៧ ភាគរយ។

យុទ្ធសាស្ត្រលើកកម្ពស់អក្ខរកម្មត្រូវផ្តោតលើការកាត់បន្ថយគម្លាតតាមយេនឌ័រ ក្រុមអាយុ ទីតាំងភូមិសាស្ត្រ (ជនបទ ប្រជុំជន) និងក្រុមជនជាតិដើមភាគតិច។ មជ្ឈមណ្ឌលសិក្សាសហគមន៍នឹងបំពាក់នូវធនធានចាំបាច់ដូចជាបរិក្ខារបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ជាដើម។ អ្នកសម្របសម្រួលកម្មវិធីអក្ខរកម្មនឹងទទួលបានការបណ្តុះបណ្តាលផ្នែកតាមបទដ្ឋាននិងស្តង់ដាថ្នាក់ជាតិ។ ស្តង់ដាអក្ខរកម្ម

និងត្រូវរៀបចំ និងពង្រីកវិសាលភាពនៃកម្មវិធីសិក្សាអក្ខរកម្ម ដើម្បីបញ្ចូលអក្ខរកម្មចម្រុះដូចជា អក្ខរកម្មឌីជីថល អក្ខរកម្មហិរញ្ញវត្ថុ ជាដើម។ ការវាយតម្លៃអក្ខរកម្មនឹងត្រូវធ្វើឡើងជាទៀងទាត់ ដើម្បីពិនិត្យតាមដានប្រសិទ្ធភាពនៃកម្មវិធី។ វប្បធម៌នៃការសិក្សាពេញមួយជីវិតនឹងត្រូវបានគាំទ្រតាមរយៈការបង្កើនលទ្ធភាពទទួលបានឯកសារផ្សេងៗសម្រាប់អ្នកសិក្សា។ ចំណុចដៅសំខាន់ៗនៃការលើកកម្ពស់អក្ខរកម្មត្រូវបានបង្ហាញក្នុងតារាងទី១៦។

### តារាងទី ១៦ ៖ ចំណុចដៅសំខាន់ៗ សម្រាប់អក្ខរកម្មមនុស្សពេញវ័យ

| សូចនាករ | ទិន្នន័យគោល | ចំណុចដៅ ២០១៩-២០២៣ | ចំណុចដៅ ២០២៤-២០២៨ | ចំណុចដៅ ២០៣០ |
|---|---|---|---|---|
| អត្រាអក្ខរកម្មមនុស្សពេញវ័យ (អាយុចាប់ពី ១៥ឆ្នាំឡើងទៅ) | ៨២,៥% (២០១៧) | ៨៨,0% | ៩៣,៥% | ៩៥,៧% |

### *យុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវបានស្នើឡើង*

តារាងទី១៧ បង្ហាញដោយសង្ខេបពីយុទ្ធសាស្ត្រ និងសកម្មភាពនានាដែលត្រូវអនុវត្ត ដើម្បីបង្កើនអក្ខរកម្មយុវជន និងមនុស្សពេញវ័យ។

### តារាងទី១៧ ៖ យុទ្ធសាស្ត្រសម្រាប់លើកកម្ពស់អក្ខរកម្មយុវជន និងមនុស្សពេញវ័យ

| យុទ្ធសាស្ត្រ | សកម្មភាព |
|---|---|
| **៤.១.១** បង្កើនលទ្ធភាពរបស់យុវជន និងមនុស្សពេញវ័យក្នុងការទទួលបានបំណិនអក្ខរកម្មវិជ្ជាជីវៈ អក្សរ និងលេខនព្វន្ត និងឱកាសសិក្សាពេញមួយជីវិត។ | **៤.១.១ក** ពង្រីកការអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ ផ្នែកអក្សរ និងលេខនព្វន្ត ក៏ដូចជាកម្មវិធីអក្ខរកម្ម កម្មវិធីសមមូល និងកម្មវិធីចូលរៀនឡើងវិញដោយផ្តោតជាពិសេសលើយុវជន ស្ត្រី ជនពិការ ក្រុមជួបការលំបាក ។ល។ តាមរយៈមជ្ឈមណ្ឌលសិក្សាសហគមន៍។ ពង្រីកកម្មវិធីអក្ខរកម្ម និងកម្មវិធីបំណិន ដោយជំរុញឱ្យមានការចូលរួមពីសង្គមស៊ីវិល ឧស្សាហកម្ម និងសហគ្រាស។ |
| | **៤.១.១ខ** ផ្សារភ្ជាប់កម្មវិធីជំនាញជាមួយនឹងកម្មវិធីអក្ខរកម្ម និងពង្រីកសកម្មភាពតាមរយៈការជំរុញឱ្យមានការចូលរួមពីសង្គមស៊ីវិល ឧស្សាហកម្ម និងសហគ្រាស។ |

| | |
|---|---|
| | **៤.១.១គ** មជ្ឈមណ្ឌលសិក្សាសហគមន៍ ត្រូវបានបំពាក់ធនធានរូបវន្ត ធនធានអប់រំ បច្ចេកវិទ្យា និងធនធានមនុស្ស ដើម្បីអភិវឌ្ឍមជ្ឈមណ្ឌលទាំងនេះ ឱ្យក្លាយជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងធានាឱ្យទីកន្លែងរៀនសូត្រមានសុវត្ថិភាព កុមារមេត្រី ក៏ដូចជាការយកចិត្តទុកដាក់លើយេនឌ័រ និងពិការភាព។ |
| | **៤.១.១ឃ** កែលម្អ ពង្រឹងប្រព័ន្ធទិន្នន័យអប់រំក្រៅប្រព័ន្ធ ដូចជាទិន្នន័យស្តីពីកម្រិតអក្ខរកម្ម អក្សរនិងលេខនព្វន្ត ដោយបែងចែកតាមយេនឌ័រសម្រាប់ជួយដល់ការរៀបចំផែន និងការពិនិត្យតាមដាន។ |
| **៤.១.២** អនុវត្តអភិក្រមទូទាំងប្រព័ន្ធសម្រាប់ផ្តល់កម្មវិធីអក្ខរកម្ម និងការសិក្សាពេញមួយជីវិត ដោយពង្រឹងតួនាទីនៃអភិក្រមនេះ ក្នុងប្រព័ន្ធអប់រំជាតិតាមរយៈការបញ្ចូលអភិក្រមនេះទៅក្នុងបទដ្ឋានគតិយុត្ត ក្របខណ្ឌស្ថាប័នដែលសមស្រប ក៏ដូចជាលើកកម្ពស់អភិបាលកិច្ច ការសម្របសម្រួលការផ្តល់ហិរញ្ញប្បទានសម្រាប់ការអនុវត្តអភិក្រមនេះ។ល។ | **៤.១.២ក** កំណត់តួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់ចំពោះអង្គភាពពាក់ព័ន្ធ នៅក្នុងបរិបទនៃការសិក្សាពេញមួយជីវិត និងរៀបចំគោលការណ៍ណែនាំស្តីពីភាពជាដៃគូ ក៏ដូចជាពង្រឹងការសម្របសម្រួលភាពជាដៃគូ និងការសហការរវាងក្រសួងស្ថានប័នពាក់ព័ន្ធ វិស័យឯកជន អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់អក្ខរកម្ម និងការសិក្សាពេញមួយជីវិត។ |
| | **៤.១.២ខ** កែសម្រួល និងពង្រឹងក្របខណ្ឌគុណវុឌ្ឍិកម្ពុជា និងបន្តអភិវឌ្ឍក្របខណ្ឌនេះឱ្យក្លាយទៅជាក្របខណ្ឌចម្បង សម្រាប់ប្រមូលផ្តុំគុណវុឌ្ឍិទាំងអស់ដែលទទួលបានពីការអប់រំតាមសាលារៀន កម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ការអប់រំឧត្តមសិក្សា ការអប់រំក្រៅប្រព័ន្ធ បញ្ចូលទៅក្នុងប្រព័ន្ធតែមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងផ្តល់ការគាំទ្រដល់គន្លងដែលមានភាពបត់បែនរវាងវិស័យនានា និងការសិក្សាពេញមួយជីវិត។ |
| | ៤.១.២គ អភិវឌ្ឍទីក្រុងរៀនសូត្រឱ្យក្លាយជាយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ការសិក្សាពេញមួយជីវិត និងអនុវត្តសាកល្បងយុទ្ធសាស្ត្រនេះ។ |

| | |
|---|---|
| ៤.១.៣ បង្កើនគុណភាព និងភាពឆ្លើយតបនៃកម្មវិធី អក្ខរកម្ម និងកម្មវិធីក្រោយអក្ខរកម្ម និងឱកាសសិក្សាពេញមួយជីវិត។ | ៤.១.៣ក កែសម្រួល ធ្វើបច្ចុប្បន្នភាព និងកែលម្អកម្មវិធីសិក្សាអក្ខរកម្ម អក្សរ និងលេខនព្វន្ត ដើម្បីបង្កើនគុណភាព និងភាពឆ្លើយតប តាមរយៈការបញ្ចូលនូវបំណិនជីវិត សមត្ថភាព គុណតម្លៃ រួមទាំងការអប់រំសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងការអប់រំភាពជាពលរដ្ឋសកល។ |
| | ៤.១.៣ខ បង្កើនគុណភាព និងការលើកទឹកចិត្តដល់អ្នកសម្របសម្រួល ឬ គ្រូបង្រៀនក្នុងកម្មវិធីអក្ខរកម្ម តាមរយៈការផ្តល់នូវការអភិវឌ្ឍវិជ្ជាជីវៈ ការបង្កើនការលើកទឹកចិត្ត និងការគាំទ្រនានា។ |
| | ៤.១.៣គ ជំរុញឱ្យមានការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ បច្ចេកវិទ្យាទូរស័ព្ទចល័តក្នុងកម្មវិធីអក្ខរកម្មអក្សរ និងលេខនព្វន្ត។ |
| | ៤.១.៣ឃ រៀបចំក្របខណ្ឌ និងឧបករណ៍វាយតម្លៃអក្ខរកម្ម ដើម្បីវាស់ស្ទង់កម្រិតអក្ខរកម្ម។ |

### *៤.៥.៥. អភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំ*

**អាទិភាពទី ៥៖**

អភិបាលកិច្ច និងការគ្រប់គ្រង មានការកែលម្អនៅគ្រប់កម្រិតទាំងអស់។

ដំណើរការ និងយន្តការអភិបាលកិច្ចបានដាក់ចេញនូវលក្ខខណ្ឌ និងក្របខណ្ឌការងារជាមូលដ្ឋានដើម្បីឱ្យមុខងារអប់រំអាចដំណើរការបានប្រកបដោយគណនេយ្យភាព តម្លាភាព ការចូលរួមពីអ្នកពាក់ព័ន្ធ ប្រសិទ្ធភាព និងភាពស្មោះត្រង់វិជ្ជាជីវៈក្នុងកម្រិតមួយដែលចង់បាន។ គោលនយោបាយ ការសម្រេចចិត្ត និងកម្មវិធីអប់រំដែលរៀបចំនៅថ្នាក់ជាតិ អាចមានផលប៉ះពាល់ដល់ការរៀនសូត្រតាមសាលារៀន។ ការរួមចំណែកនៃធនធានអប់រំដូចជា កម្មវិធីសិក្សា សៀវភៅសិក្សា គ្រូបង្រៀន សម្ភារសិក្សា ធនធានហិរញ្ញវត្ថុ ឬ សមាភាគផ្សេងទៀតចំពោះការអប់រំប្រកបដោយសមធម៌ ប្រសិទ្ធភាព ភាពឆ្លើយតប គឺអាស្រ័យលើគុណភាព និងប្រសិទ្ធភាពនៃអភិបាលកិច្ច និងការគ្រប់គ្រង។ អភិបាលកិច្ចវិស័យអប់រំ មានច្រើនកម្រិតចាប់ពីថ្នាក់ជាតិរហូតដល់ថ្នាក់សាលារៀន ដោយមានការចូលរួមពីតួអង្គពាក់ព័ន្ធជាច្រើនដែលមានអំណាច និងផលប្រយោជន៍ក្នុងកម្រិតខុសៗគ្នា។ ដើម្បីឱ្យការរៀនសូត្រអាចធ្វើទៅបាន

ប្រកបដោយគុណភាព តួអង្គពាក់ព័ន្ធនៅគ្រប់កម្រិតនៃប្រព័ន្ធអប់រំត្រូវបំពេញតួនាទីសំខាន់របស់ខ្លួន។ ដូចនេះ កិច្ចការសំខាន់បំផុត ត្រូវបង្កើនសមត្ថភាពអភិបាលកិច្ច និងគ្រប់គ្រងនៅគ្រប់កម្រិតនៃវិស័យអប់រំ។ ការសម្រេចគោលដៅនេះទាមទារឱ្យមានការពង្រឹងនិងអភិវឌ្ឍន៍សមត្ថភាពបុគ្គល ស្ថាប័ន និងប្រព័ន្ធ ដើម្បីធានាឱ្យវិស័យអប់រំមានបុគ្គលិកដែលមានសមត្ថភាពគ្រប់គ្រាន់។

### *ក. ការកែលម្អការគ្រប់គ្រងសាលារៀន*

**លទ្ធផលរំពឹងទុក ៥.១**

សាលារៀន គ្រឹះស្ថានសិក្សា ត្រូវបានអភិវឌ្ឍក្លាយទៅជាគ្រឹះស្ថានដែលមានស្វ័យភាព វិជ្ជាជីវៈ និងគណនេយ្យភាពច្រើនជាងមុន។

គុណភាពនៃការអប់រំ ក៏ដូចជាកត្តាដទៃទៀត គឺអាស្រ័យទៅលើគោលវិធីនៃអភិបាលកិច្ច និងគ្រប់គ្រងសាលារៀន។ សមត្ថភាពនៃសាលារៀនក្នុងការកែលម្អការបង្រៀន និងរៀន គឺពឹងផ្អែកជាសំខាន់លើគុណភាពនៃការដឹកនាំរបស់គណៈគ្រប់គ្រងសាលារៀន(នាយកសាលា)។ការស្រាវជ្រាវជាច្រើនអំពីប្រសិទ្ធភាពនៃសាលារៀនបានបង្ហាញថា សកម្មភាពដែលកើតឡើងនៅកម្រិតសាលារៀនអាចកំណត់ល្បឿននៃការរៀនសូត្រ។អភិបាលកិច្ច គឺជាកត្តាធានាបាននូវគ្រូបង្រៀនដែលមានគុណវុឌ្ឍិមានការលើកទឹកចិត្ត និងមានគណនេយ្យភាព អ្នកសិក្សាទទួលបានឯកសារនិងកម្មវិធីសិក្សាដែលមានគុណភាពខ្ពស់ និងមានឱកាសចូលរួមក្នុងការរៀនសូត្រ ក៏ដូចជាការទទួលបានការគាំទ្រគ្រប់គ្រាន់ពីគ្រូបង្រៀន ឪពុកម្តាយនិងសមាជិកសហគមន៍មូលដ្ឋានចូលរួមសម្រេចចិត្ត និងរួមចំណែកក្នុងដំណើរការសិក្សា ហើយសាលារៀនផ្តល់នូវសុវត្ថិភាពផ្លូវកាយនិងចិត្ត និងបរិយាកាសគាំទ្រដល់ការសិក្សារបស់សិស្ស។

ក្នុងបរិបទនេះ ក្រសួងអប់រំ យុវជន និងកីឡា កំពុងឈានទៅប្រើប្រាស់អភិក្រមគ្រប់គ្រងនៅតាមសាលារៀន ដែលតម្រូវឱ្យមានការអភិវឌ្ឍសាលារៀនឱ្យក្លាយជាគ្រឹះស្ថានស្វ័យភាពផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ។ ដូចនេះ តម្រូវឱ្យតួអង្គពាក់ព័ន្ធ (ដូចជាគ្រូបង្រៀន មាតាបិតាសិស្ស សមាជិកសហគមន៍) ចូលរួមធ្វើការសម្រេចចិត្តអំពីបញ្ហាសំខាន់ៗសម្រាប់ការអភិវឌ្ឍសាលារៀន និងការធ្វើសេចក្តីសម្រេចចិត្តកាន់តែខិតជិតទៅនឹងសាលារៀន។ដើម្បីឱ្យសាលារៀនមានស្វ័យភាព គឺគ្រូបង្រៀន និងសាលារៀនត្រូវតែទទួលខុសត្រូវចំពោះលទ្ធផលការងាររបស់ខ្លួន។ ក្រសួងអប់រំ យុវជន និងកីឡា នឹងអភិវឌ្ឍសមត្ថភាពគ្រប់គ្រង និងដឹកនាំការបង្រៀនរបស់នាយកសាលាផងដែរ។ ប្រសិទ្ធភាពនៃការដឹកនាំ និងការគ្រប់គ្រងសាលារៀន ឬ គ្រឹះស្ថានសិក្សា នឹងបង្កើតឱ្យមានបរិយាកាសអំណោយផលសម្រាប់ការរៀនសូត្រ។ កន្លងមក មានការបង្កើតរចនាសម្ព័ន្ធនៅមូលដ្ឋាន ដែលផ្តល់លទ្ធភាពឱ្យមាន

ការចូលរួមពីមាតាបិតាសិស្ស គ្រូបង្រៀន និងសមាជិកសហគមន៍ក្នុងការកៀរគរ និងការអភិវឌ្ឍធនធាននានា។ ការចូលរួមរបស់សហគមន៍លើការងារអភិបាលកិច្ចសាលារៀននឹងលើកកម្ពស់បន្ថែមទៀត និងផ្តល់ឱកាសកាន់តែច្រើនឱ្យមាតាបិតាសិស្ស និងសមាជិកសហគមន៍ចូលរួមក្នុងការគ្រប់គ្រងសាលារៀន។ ប្រព័ន្ធអធិការកិច្ចសាលារៀន ត្រូវអនុវត្តដើម្បីធានាឱ្យការងារសំខាន់ៗនៃដំណើរការសាលារៀន ដូចជាការដឹកនាំនិងការគ្រប់គ្រង ការបង្រៀននិងរៀន ការរៀនសូត្រនិងលទ្ធផលសិក្សារបស់សិស្ស ការវាយតម្លៃសាលារៀននិងផែនការអភិវឌ្ឍន៍សាលារៀន។ល។ គាំទ្រការសម្រេចគោលបំណងរួមរបស់សាលារៀន។ ផែនទីបង្ហាញផ្លូវនេះលើកឡើងមានការអនុវត្តឱ្យបានកាន់តែស៊ីជម្រៅ និងពង្រឹងបន្ថែមទៀតលើគំនិតផ្តួចផ្តើមជាច្រើន ដែលកំពុងអនុវត្តក្នុងគោលបំណងកសាងសមត្ថភាពស្ថាប័ននៅកម្រិតសាលារៀន។

### *យុទ្ធសាស្ត្រនិងសកម្មភាពដែលត្រូវបានស្នើឡើង*

តារាងទី ១៨ បង្ហាញពីយុទ្ធសាស្ត្រ និងសកម្មភាពសម្រាប់កែលម្អការគ្រប់គ្រងសាលារៀន។

**តារាងទី ១៨ ៖ យុទ្ធសាស្ត្រសម្រាប់កែលម្អការគ្រប់គ្រងសាលារៀន**

| យុទ្ធសាស្ត្រ | សកម្មភាព |
|---|---|
| **៥.១.១** បង្កើនសមត្ថភាពសាលារៀនដើម្បីបំពេញការងារជាគ្រឹះស្ថានដែលមានស្វ័យភាព។ | **៥.១.១ក** រៀបចំយុទ្ធសាស្ត្រជាតិសម្រាប់ធ្វើវិមជ្ឈការមុខងារអប់រំ និងការគ្រប់គ្រងតាមសាលារៀន តាមរយៈការផ្តល់អំណាច និងការទទួលខុសត្រូវបន្ថែមទៀតដល់សាលារៀន និងផ្តល់ឱ្យសាលារៀននូវស្វ័យភាព និងភាពបត់បែនកាន់តែច្រើនក្នុងដំណើរការប្រចាំថ្ងៃ ការគ្រប់គ្រងថវិកា ការគ្រប់គ្រងធនធាន និងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀន។ |
| | **៥.១.១ខ** កំណត់សារជាថ្មីនូវតួនាទី ការទទួលខុសត្រូវរបស់នាយកសាលា ដើម្បីពង្រឹងតួនាទីរដ្ឋបាល និងតួនាទីដឹកនាំការបង្រៀនរបស់ពួកគេ ដោយផ្តល់ឱ្យពួកគេនូវការលើកទឹកចិត្តឱ្យបានកាន់តែច្រើន ការបណ្តុះបណ្តាល អំណាច និងគណនេយ្យភាពកាន់តែច្រើនជាងមុន។ |
| | **៥.១.១គ** អភិវឌ្ឍស្តង់ដាវិជ្ជាជីវៈសម្រាប់នាយកសាលា និងរៀបចំអនុវត្តកម្មវិធីអភិវឌ្ឍភាពជាអ្នកដឹកនាំ។ |

| | |
|---|---|
| | **៥.១.១ឃ** ពង្រឹងតួនាទីគណៈគ្រប់គ្រងសាលារៀន (គណៈកម្មការគ្រប់គ្រងសាលារៀន) ក្នុងការសម្រេចចិត្តរបស់សាលារៀន ដោយមានការជំរុញឱ្យមានការចូលរួមបន្ថែមទៀតពីមាតាបិតា។ |

### *ខ. ការលើកកម្ពស់អភិបាលកិច្ចវិស័យអប់រំ*

**លទ្ធផលរំពឹងទុក ៥.២**

អភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំមានតម្លាភាព គណនេយ្យភាព មានការចូលរួម មានប្រសិទ្ធភាព និងធ្វើឡើងប្រកបដោយសមត្ថភាព។

លទ្ធផលរំពឹងទុកនេះ គឺពាក់ព័ន្ធជាមួយនឹងអភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំ ដើម្បីធានាឱ្យសម្រេចបានតាមគោលបំណង និងលទ្ធផលប្រកបដោយប្រសិទ្ធភាព។ អភិបាលកិច្ចល្អក្នុងវិស័យអប់រំ លើកកម្ពស់ដល់ការផ្តល់សេវាអប់រំប្រកបដោយប្រសិទ្ធភាព ដែលទាមទារឱ្យដំណើរការអភិបាលកិច្ច និងការគ្រប់គ្រងត្រូវធ្វើឡើងប្រកបដោយតម្លាភាព គណនេយ្យភាព និងការចូលរួម និងមានប្រសិទ្ធភាព។ ក្នុងនោះ កត់សម្គាល់ឃើញថា ការបំពេញការងារនៃស្ថាប័នក្នុងវិស័យអប់រំទទួលឥទ្ធិពលពីបរិបទអភិបាលកិច្ចរួម និងប្រសិទ្ធភាពនៃអភិបាលកិច្ចរបស់ប្រទេសកម្ពុជា។ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងអភិបាលកិច្ចក្នុងវិស័យសាធារណៈ។ កំណែទម្រង់ការគ្រប់គ្រងសាធារណៈ មានគោលបំណងកសាងនូវរចនាសម្ព័ន្ធ និងដំណើរការអភិបាលកិច្ចដែលមានគណនេយ្យភាព អាចព្យាករណ៍បាន និងមានតម្លាភាពចំពោះសាធារណជនទូទៅ ព្រមទាំងគោរពនីតិរដ្ឋ លើកទឹកចិត្តឱ្យមានការចូលរួមពីពលរដ្ឋ ក៏ដូចជាការពារ និងលើកកម្ពស់សិទ្ធិមនុស្ស។ គំនិតផ្តួចផ្តើមដទៃទៀតជាច្រើនដូចជាកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ការចូលរួមរបស់សង្គមស៊ីវិល សុទ្ធតែរួមចំណែកដល់កំណែទម្រង់អភិបាលកិច្ច។ យន្តការរៀបចំផែនការ និងថវិកាផ្អែកតាមលទ្ធផលដែលកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ គឺជាជំហានដ៏សំខាន់ក្នុងការឈានទៅកែលម្អការផ្តល់សេវាអប់រំ។ យុទ្ធសាស្ត្រសម្រាប់កែលម្អអភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំ ត្រូវបានផ្សារភ្ជាប់ទៅនឹងគំនិតផ្តួចផ្តើមជាច្រើន ដែលរាជរដ្ឋាភិបាលកំពុងអនុវត្តនាពេលបច្ចុប្បន្ន។ ការគ្រប់គ្រងគោលនយោបាយ ព័ត៌មាន ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ក្នុងប្រព័ន្ធអប់រំទាំងមូលនឹងត្រូវកែលម្អបន្ថែមទៀត ដើម្បីធានាឱ្យមានការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

កន្លងមក មានការប្រឹងប្រែងជាច្រើនដើម្បីបង្កើនសមត្ថភាពបុគ្គលិកអប់រំនៅគ្រប់កម្រិត (ឧទាហរណ៍ មន្ត្រីនៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក អ្នកឯកទេសផ្នែកកម្មវិធីសិក្សា អ្នកសរសេរសៀវភៅសិក្សា អ្នករៀបចំផែនការ អ្នកជំនាញខាងអប់រំក្រៅប្រព័ន្ធ អ្នកជំនាញខាងពិនិត្យតាមដាន និងវាយតម្លៃជាដើម)។ កម្មវិធីអភិវឌ្ឍសមត្ថភាព គួរធ្វើឡើងដោយផ្អែកតាមចក្ខុវិស័យរយៈពេលវែងនៃការអភិវឌ្ឍវិស័យអប់រំ។ ដូចនេះ ក្រសួងអប់រំ យុវជន និងកីឡាត្រូវរៀបចំនិងអនុវត្តកម្មវិធីអភិវឌ្ឍសមត្ថភាពឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈបុគ្គលិកអប់រំ តាមរយៈការប្រើប្រាស់អភិក្រមចម្រុះច្រើនប្រភេទ។

### *យុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវបានស្នើឡើង*

តារាងទី១៩ បង្ហាញពីយុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវអនុវត្ត ដើម្បីពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំ។

**តារាងទី ១៩៖ យុទ្ធសាស្ត្រសម្រាប់ពង្រឹងអភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំ**

| យុទ្ធសាស្ត្រ | សកម្មភាព |
|---|---|
| **៥.២.១** បង្កើតយន្តការ នីតិវិធី និងសមត្ថភាពបច្ចេកទេស ដើម្បីដឹកនាំសម្របសម្រួល និងជំរុញការអនុវត្តអន្តរាគមន៍សម្រាប់អភិវឌ្ឍវិស័យអប់រំនៅកម្រិតផ្សេងៗ និងឆ្លងវិស័យ ពង្រឹងយន្តការសម្របសម្រួលជំរុញឱ្យមានការចូលរួមពីដៃគូក្នុងការរៀបចំផែនការ ការអនុវត្ត និងការពិនិត្យតាមដានគោលនយោបាយ និងយុទ្ធសាស្ត្រវិស័យអប់រំ។ | **៥.២.១ក** ធ្វើការពិនិត្យមុខងារឡើងវិញ (ការវិភាគ ស្ថាប័ន) របស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាស្ថាប័ន និងអង្គភាពរបស់ខ្លួន (ទាំងខ្សែបណ្តោយ និងខ្សែទទឹង) និងដំណើរការគ្រប់គ្រងដើម្បីបញ្ជាក់ឱ្យបានច្បាស់ថាតើរចនាសម្ព័ន្ធ និងដំណើរការដែលកំពុងមាននាពេលបច្ចុប្បន្ន ផ្តល់នូវកម្លាំងជួប និងបរិយាកាសអំណោយផលដើម្បីសម្រេចលទ្ធផលអប់រំកាន់តែប្រសើរឡើង។ |
| | **៥.២.១ខ** រៀបចំផែនការអភិវឌ្ឍសមត្ថភាពដោយមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដើម្បីពង្រឹងសមត្ថភាពបុគ្គលិកអប់រំនៅគ្រប់លំដាប់ថ្នាក់។ |
| | **៥.២.១គ** ពង្រឹងសមត្ថភាពអង្គភាពថ្នាក់ជាតិក្នុងការរៀបចំគោលនយោបាយ និងផែនការទូទាំងវិស័យ ព្រមទាំងវិភាជន៍ធនធានហិរញ្ញវត្ថុ និងធានាឱ្យក្របខណ្ឌគតិយុត្តឆ្លុះបញ្ចាំងពីទិសដៅជាយុទ្ធសាស្ត្រ ស្រាវជ្រាវនិងផ្សព្វផ្សាយលទ្ធផល និងផ្តល់ការគាំទ្រដល់ការអភិវឌ្ឍ និងដំណើរការនៃវិស័យអប់រំ។ |

| | |
|---|---|
| | **៥.២.១ឃ** ពង្រឹងសមត្ថភាពថ្នាក់ខេត្ត និងថ្នាក់ស្រុក ក្នុងការផ្តល់សេវាអប់រំ ធ្វើអធិការកិច្ចសាលារៀន ដើម្បីធានាឱ្យមានការអនុវត្តស្តង់ដា និងបទដ្ឋានគតិយុត្តជាតិ និងធ្វើការពិនិត្យតាមដានជាប្រចាំ ក៏ដូចជាធ្វើការរាយការណ៍ឱ្យបានសុក្រឹតអំពីការបំពេញការងាររបស់សាលារៀន។ |
| | **៥.២.១ង** ពង្រឹងប្រព័ន្ធគណនេយ្យភាពតាមរយៈការកំណត់ឱ្យបានច្បាស់នូវចំណុចដៅ ឬ ស្តង់ដានៃការបំពេញការងារ និងប្រមូលព័ត៌មានឱ្យបានគ្រប់គ្រាន់អំពីការផ្តល់សេវាអប់រំ ដើម្បីពិនិត្យតាមដានការបំពេញការងារ។ |
| | **៥.២.១ច** ជំរុញឱ្យមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និង ឬ ស្ថាប័នដែលត្រូវធ្វើវិមជ្ឈការ ពង្រឹងសមត្ថភាពស្ថាប័នទាំងនោះ និងបញ្ជាក់ឱ្យបានច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេ ក្នុងការផ្តល់សេវាអប់រំ។ |
| | **៥.២.១ឆ** រៀបចំគោលនយោបាយឱ្យបានច្បាស់លាស់ និងបង្កើតភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនក្នុងការផ្តល់សេវាអប់រំ ផ្អែកតាមមេរៀនពិសោធន៍ដែលទទួលបានពីគំនិតផ្តួចផ្តើមសាលារៀនជំនាន់ថ្មី។ |

*គ. កែលម្អប្រព័ន្ធគ្រប់គ្រងព័ត៌មាន*

**លទ្ធផលរំពឹងទុក ៥.៣**

ទិន្នន័យសុក្រឹត និងជឿទុកចិត្តបាន ត្រូវផលិតបានទាន់ពេលវេលា សម្រាប់រៀបចំផែនការ និងតាក់តែងគោលនយោបាយអប់រំ។

ទិន្នន័យសុក្រិត មានសុពលភាព អាចជឿទុកចិត្តបាន និងទាន់ពេលវេលា គឺលក្ខខណ្ឌចាំបាច់សម្រាប់ការរៀបចំផែនការ ការតាក់តែងគោលនយោបាយ និងការពិនិត្យតាមដាន។ អ្នករៀបចំផែនការ និងអ្នកគ្រប់គ្រងការងារអប់រំនៅគ្រប់លំដាប់ថ្នាក់ ត្រូវការចាំបាច់នូវព័ត៌មានដែលសុក្រឹត ទាន់ពេលវេលា ដើម្បីដំណើរការ និងអភិវឌ្ឍប្រព័ន្ធអប់រំឱ្យមានប្រសិទ្ធភាព។ របៀបវារៈអប់រំថ្មី តម្រូវឱ្យមានទិន្នន័យដែលជឿទុកចិត្តបាន ទាន់ពេលវេលា និងអាចប្រៀបធៀបបានពីប្រភពទិន្នន័យដែលមានស្រាប់ និងប្រភពទិន្នន័យថ្មីៗផង។ ហេតុនេះ ការផ្តោតលើការវាស់វែងលទ្ធផល (គុណភាព) និងសមធម៌ ចាំបាច់

ត្រូវមានទិន្នន័យ និងស្ថិតិច្រើនទម្រង់ និងល្អប្រសើរជាងមុន មិនត្រឹមតែសម្រាប់តាមដានវឌ្ឍនភាពដែលសម្រេចបានប៉ុណ្ណោះទេ ថែមទាំងការរៀបចំគោលនយោបាយផ្អែកតាមភស្តុតាងទិន្នន័យផងដែរ។ ក្រសួងអប់រំ យុវជន និងកីឡាបានទទួលស្គាល់ពីសារៈសំខាន់នៃស្ថិតិអប់រំ និងបានអនុវត្តនូវវិធានការជាច្រើន ដើម្បីកែលម្អប្រព័ន្ធព័ត៌មានគ្រប់គ្រប់អប់រំ និងប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃដែលមានស្រាប់។ បច្ចុប្បន្ន កម្ពុជាបាននិងកំពុងរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍស្ថិតិអប់រំ ដោយមានការគាំទ្របច្ចេកទេសពីវិទ្យាស្ថានស្ថិតិរបស់យូណេស្កូ អង្គការយូណេស្កូ បាងកក និងមានការចូលរួមពីអ្នកប្រើប្រាស់ និងអ្នកផលិតទិន្នន័យផ្សេងៗ។ ប្រព័ន្ធព័ត៌មានគ្រប់គ្រប់អប់រំបាននិងកំពុងពង្រឹងបន្ថែមទៀត ដើម្បីឆ្លើយតបនឹងតម្រូវការទិន្នន័យនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ រួមទាំងក្របខណ្ឌសូចនាករផង។ យុទ្ធសាស្ត្រដែលលើកឡើងសម្រាប់កែលម្អស្ថិតិអប់រំ និងការពិនិត្យតាមដាន រួមមានការបង្កើតនូវប្រព័ន្ធផលិតទិន្នន័យដែលផ្តល់នូវព័ត៌មានប្រកបដោយគុណភាព និងពាក់ព័ន្ធការពង្រឹងការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ននានា និងការបង្កើនសមត្ថភាពបច្ចេកទេសនិងធនធានមនុស្ស។

### *យុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវបានស្នើឡើង*

តារាងទី២០ បង្ហាញពីយុទ្ធសាស្ត្រ និងសកម្មភាពសម្រាប់ពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំ។

**តារាងទី ២០៖ យុទ្ធសាស្ត្រសម្រាប់លើកកម្ពស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ**

| យុទ្ធសាស្ត្រ | សកម្មភាព |
| --- | --- |
| **៥.៣.១** ពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំនៅថ្នាក់ជាតិ តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រឱ្យបានច្បាស់លាស់ និងការផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធទិន្នន័យពាក់ព័ន្ធផ្សេងៗ។ | **៥.៣.១ក** បង្កើតប្រព័ន្ធប្រមូលទិន្នន័យពីថ្នាក់ភូមិដល់ថ្នាក់ជាតិ បង្កើនសមត្ថភាពប្រមូលទិន្នន័យ និងជំនាញវិភាជន៍នៅគ្រប់កម្រិតថ្នាក់ ចាប់ពីកម្រិតសាលារៀនថ្នាក់ស្រុក និងថ្នាក់ខេត្ត ដើម្បីពង្រឹងការផ្តល់សេវាមូលដ្ឋាន ការគ្រប់គ្រង និងការធ្វើសេចក្តីសម្រេចចិត្ត។ |
| | **៥.៣.១ខ** បង្កើតវេទិកាទិន្នន័យតាមរយៈការពង្រឹងកិច្ចសហការ និងការផ្សារភ្ជាប់រវាងប្រព័ន្ធ ប្រភពទិន្នន័យ និងកិច្ចសហការរវាងវិស័យ ឬ ក្រសួងពាក់ព័ន្ធ ដោយកំណត់ពីតួនាទី និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់។ |
| | **៥.៣.១គ** បង្កើតប្រព័ន្ធមួយដែលបង្កើនឱកាសប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងការផ្សារភ្ជាប់ទិន្នន័យសម្រាប់ចែករំលែកព័ត៌មានភ្លាមៗ វិភាគ និង |

| | |
|---|---|
| | រាយការណ៍ ក៏ដូចជាបង្កើតនូវយន្តការផ្តល់ព័ត៌មានត្រឡប់ ដើម្បីធានាឱ្យយោបល់ និងការព្រួយបារម្ភរបស់អ្នកសិក្សា មាតាបិតា អ្នកអប់រំ និងសាធារណជនទូទៅ ត្រូវបាន ទទួលយក និងយកមកប្រើប្រាស់សម្រាប់ការរៀបចំ ផែនការ ការតាក់តែងគោលនយោបាយ និងការផ្តល់ សេវានានា។ |
| **៥.៣.២** ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងនៅគ្រប់ កម្រិតថ្នាក់ ដើម្បីវាស់វែង និងពិនិត្យតាមដាន គុណភាព សមធម៌ និងបរិយាបន្ន និងប្រើប្រាស់ ទិន្នន័យសម្រាប់ការរៀបចំផែនការ និងការពិនិត្យ តាមដាន។ | **៥.៣.២ក** រៀបចំ និងអនុវត្តកម្មវិធីកសាងសមត្ថភាព ដើម្បីបណ្តុះបណ្តាលអ្នកគ្រប់គ្រងគ្រប់កម្រិតថ្នាក់ផ្នែក ប្រមូលទិន្នន័យ បែងចែកទិន្នន័យតាមប្រភេទ វិភាគ ទិន្នន័យប្រើប្រាស់ទិន្នន័យ និងពិនិត្យតាមដានទិន្នន័យ ។ល។ |
| **៥.៣.៣** ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ដែលមានស្រាប់ ដើម្បីបន្តតាមដាន ក៏ដូចជា ពិនិត្យឡើងវិញលើវឌ្ឍនភាពដែលសម្រេចបាន នៃវិស័យអប់រំ។ | **៥.៣.៣ក** ធ្វើបច្ចុប្បន្នភាពក្របខណ្ឌសូចនាករជាតិ និង ធានាឱ្យក្របខណ្ឌនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ សម្រាប់ពិនិត្យតាមដានគ្រប់ទិដ្ឋភាពនៃរបៀបវារៈអប់រំ ឆ្នាំ២០៣០ និងធានាឱ្យមានទិន្នន័យសំខាន់ និងចាំបាច់ សម្រាប់ការងារពិនិត្យតាមដាន។ |
| | **៥.៣.៣ខ** ធ្វើការពិនិត្យឡើងវិញតាមកាលកំណត់លើ វឌ្ឍនភាពនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ និងរៀបចំរបាយការណ៍ពិនិត្យឡើងវិញថ្នាក់ជាតិ។ |

## ៥. ផែនការហិរញ្ញប្បទាន

### ៥.១ ការធ្វើចំណោល

ការធ្វើចំណោល ត្រូវបានរៀបចំឡើងដោយប្រើប្រាស់ម៉ូដែលវិភាគនិងចំណោលគម្រូវការអប់រំកម្ពុជា (ខែនប្រូ) របស់ក្រសួងអប់រំ យុវជន និងកីឡា។ ខែនប្រូ គឺជាម៉ូដែលដែលបានកែសម្រួលឱ្យស្របទៅតាមស្ថានភាពជាក់ស្តែងនៃប្រព័ន្ធអប់រំរបស់កម្ពុជា។ ម៉ូដែលនេះ ធ្វើចំណោលចំនួនសិស្សផ្អែកតាមទិន្នន័យប្រជាសាស្ត្រ និងធាតុចូលសម្រាប់វិស័យអប់រំទៅតាមអាទិភាពគោលនយោបាយលទ្ធផលរំពឹងទុក។ ម៉ូដែលប៉ាន់ស្មានចំណាយជាច្រើនពាក់ព័ន្ធដូចជា (ក)ចំនួនសិស្ស (ខ)បៀវត្សគ្រូបង្រៀន និងចំណាយសម្រាប់សាងសង់បន្ទប់រៀនដែលមួយផ្នែកធំនៃធាតុចូលសម្រាប់វិស័យអប់រំ (គ)បទដ្ឋានអប់រំដូចជាផលធៀបសិស្សគ្រូ និងអត្រាឡើងថ្នាក់ ដែលជាអថេរសំខាន់ពីរដែលអាចនាំឱ្យមានការផ្លាស់ប្តូរចំនួនសិស្ស និងគ្រូបង្រៀននៅក្នុងប្រព័ន្ធអប់រំ។ តួលេខទាំងនេះ គឺជាតួលេខរបស់វិស័យអប់រំ និងគ្រប់ដណ្តប់លើវិសាលភាពទាំងមូលនៃផែនទីបង្ហាញផ្លូវនេះ។ ឆ្នាំគោលគឺ ឆ្នាំ២០១៦ និងធ្វើចំណោលលទ្ធផលរហូតដល់ឆ្នាំ២០៣០ ដែលជាឆ្នាំចុងក្រោយនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។

*ការធ្វើចំណោលចំនួនប្រជាជន*

ការធ្វើចំណោលចំនួនប្រជាជន បង្ហាញពីប្រជាជនក្នុងវ័យសិក្សាទៅតាមក្រុមអាយុផ្សេងៗ ក៏ដូចជាចំនួនប្រជាជនដល់វ័យសិក្សា។ ខណៈដែលផែនទីបង្ហាញផ្លូវគ្របដណ្តប់រយៈពេលវែងដល់ ឆ្នាំ ២០៣០ និងទិន្នន័យជំរឿនឆ្នាំ២០០៨ ត្រូវបានប្រើប្រាស់ ហើយទិន្នន័យជំរឿនថ្មីនឹងអាចមាននៅឆ្នាំ ២០២០ ដែលនឹងត្រូវពិចារណាលើការធ្វើចំណោលនេះ។ ដូចក្នុងតារាងទី២០ ចំនួនប្រជាជនក្នុងក្រុមអាយុ ៣ ដល់ ៥ឆ្នាំ ត្រូវបានធ្វើចំណោលថា នឹងកើនពី ៩១០ ៩៦៤នាក់ ដល់ ១ ០៩៧ ៨២៨នាក់ ចន្លោះពីឆ្នាំ២០១៦ ដែលជាឆ្នាំគោល រហូតដល់ឆ្នាំ២០៣០។ ក្រុមអាយុ ៦ ដល់ ១៣ ឆ្នាំ មានចំនួន ១ ៨៥៧ ៤៥៤នាក់ ឆ្នាំ២០១៦ នឹងកើនដល់ ២ ២១៩ ៧៨២នាក់ ឆ្នាំ២០៣០ ពោលគឺកើនឡើងប្រមាណជា ៣៦២ ៣២៩នាក់។ និន្នាការកំណើនស្រដៀងគ្នាដែរ ចំពោះការធ្វើចំណោលក្នុងក្រុមអាយុផ្សេងទៀត។ ចំណុចនេះ បង្ហាញថាបើធៀបនឹងឆ្នាំគោល នឹងមានកុមារនិងយុវជនកាន់តែច្រើនចូលរៀនតាមសាលារៀន ឬ មហាវិទ្យាល័យនៅឆ្នាំបន្តបន្ទាប់ ដែលចាំបាច់ត្រូវតែពង្រីកសេវាអប់រំនៅគ្រប់កម្រិតថ្នាក់ទាំងអស់។

### តារាងទី ២១៖ ចំណោលប្រជាជន ចន្លោះពីឆ្នាំ ២០១៦ ដល់ ២០៣០

| ក្រុមអាយុ | ឆ្នាំគោល ២០១៦ | ២០១៩ | ២០២៣ | ២០២៨ | ២០៣០ |
|---|---|---|---|---|---|
| ៣-៥ | ៩១០ ៩៦៤ | ៩៤៨ ៤៨៩ | ៩៩៩ ៧៤៣ | ១ ០៦៨ ៧៥៤ | ១ ០៩៧ ៨២៨ |
| ៦-១១ | ១ ៨៥៧ ៤៥៤ | ១ ៩៣០ ២៦៥ | ២ ០២៩ ៩៦៤ | ២ ១៦៣ ៦២៣ | ២ ២១៩ ៧៨២ |
| ១២-១៤ | ១ ០៥១ ៩៧៣ | ១ ០៩៣ ០៥៣ | ១ ១៤៩ ៣០៣ | ១ ២២៤ ៧១២ | ១ ២៥៦ ៣៩៧ |
| ១៥-១៧ | ១ ១១៣ ៩១៨ | ១ ១៥៨ ៥៨៩ | ១ ២១៩ ៦៨០ | ១ ៣០១ ៧៨២ | ១ ៣៣៦ ៣៣៣ |
| ១៨-២២ | ២ ២៧២ ២៤៥ | ២ ៣៨៤ ៧០៧ | ២ ៤៩៤ ៤៦៩ | ២ ៦៩៣ ៤១៦ | ២ ៧៧៧ ៩២២ |

*ការធ្វើចំណោលនៃការចូលរៀនរបស់សិស្ស*

តារាងទី២២ បង្ហាញពីចំណោលចំនួនចូលរៀនតាមភូមិសិក្សាផ្សេងៗ ពីឆ្នាំ២០១៦ ដល់ ២០៣០។ បើធៀបនឹងឆ្នាំគោល និងផ្អែកតាមនិន្នាការចូលរៀនតាមភូមិសិក្សានីមួយៗកន្លងមក លទ្ធផលចំណោលបង្ហាញថា ការចូលរៀនកើនឡើងសម្រាប់ការអប់រំកុមារតូច និងបឋមសិក្សា។ ខណៈពេលដែល ការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាលើសកលកម្មការអប់រំកម្រិតមូលដ្ឋានក្នុងរយៈពេលនេះ ត្រូវរំពឹងថាការចូលរៀននឹងកើនឡើងខ្លាំងសម្រាប់មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ (ទាំងចំណេះទូទៅ និងអប់រំបច្ចេកទេស) និងអប់រំឧត្តមសិក្សា។

### តារាងទី ២២៖ ចំណោលសិស្សចូលរៀនតាមភូមិសិក្សាចន្លោះពីឆ្នាំ ២០១៦ ដល់ ២០៣០

| ភូមិសិក្សា | ឆ្នាំគោល ២០១៦ | ២០១៩ | ២០២៣ | ២០២៨ | ២០៣០ |
|---|---|---|---|---|---|
| មត្តេយ្យសិក្សា | ៣៣២ ៧០៤ | ៤០០ ១៧២ | ៤៥៦ ៨៨១ | ៥៣៥ ១១២ | ៥៦៨ ៨៤៦ |
| បឋមសិក្សា | ២ ១០៥ ៩០៣ | ២ ១៤១ ២០១ | ២ ១៥៤ ២០១ | ២ ២១៥ ០៦៥ | ២ ២៣៧ ៨៥៩ |
| មធ្យមសិក្សាបឋមភូមិ | ៥៥៨ ៦២១ | ៦៤៨ ៩៩៩ | ៧១៥ ៦២១ | ៨០៦ ៨៩៥ | ៨៤៦ ២២៧ |
| មធ្យមសិក្សាទុតិយភូមិ | ២៦៦ ៤៤៩ | ៣៤០ ៧៥៣ | ៤០១ ៦៦២ | ៤៨៦ ៨៤៩ | ៥២៣ ៨៦២ |
| ឧត្តមសិក្សា | ២០៧ ៤៣៤ | ២៨៨ ៥៧៩ | ៤១២ ១៩១ | ៦១១ ១៩៨ | ៦៩៤ ៤៨១ |

ចំណោលសិស្ស នឹងត្រូវកែសម្រួលបន្ទាប់ពីជំរឿនប្រជាជនកម្ពុជាថ្នាក់ជាតិ ត្រូវបានបញ្ចប់នៅឆ្នាំ២០១៩/២០២០។ ផ្អែកតាមទិន្នន័យប្រជាជនបច្ចុប្បន្នភាព ចំនួនថ្នាក់រៀន សាលារៀន គ្រូបង្រៀន និងសម្ភាររូបវន្តនឹងត្រូវបានធ្វើចំណោល។

ម្យ៉ាងទៀត ក្រសួងនឹងបន្តពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពនូវស្តង់ដា និងនិយាមស្របតាមឧត្តមានុវត្តន៍អន្តរជាតិដែលនឹងប៉ះពាល់ដល់ចំណុះសិស្សក្នុងថ្នាក់រៀន ផលធៀបសិស្ស-គ្រូ សិស្ស-

បន្ទប់រៀន ចំនួនគ្រូ-បន្ទប់រៀន។ល។ ចំណោល ត្រូវបានបង្ហាញក្នុងតារាងខាងក្រោម ៖

*ការធ្វើចំណោលគ្រូបង្រៀន*

### តារាងទី ២៣៖ ចំណោលតម្រូវការគ្រូបង្រៀន

| ភូមិសិក្សា | | ឆ្នាំគោល ២០១៦ | ២០១៩ | ២០២៣ | ២០២៨ | ២០៣០ |
|---|---|---|---|---|---|---|
| មត្តេយ្យសិក្សា (មត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍) | តម្រូវការគ្រូសរុប | ១៥ ០៧៥ | ១៥ ១០០ | ១៥ ១៦២ | ១៥ ២២៤ | ១៥ ២៤៩ |
| បឋមសិក្សា | តម្រូវការគ្រូសរុប | ៥៩ ២០៦ | ៥៩ ២២៦ | ៥៩ ២៥២ | ៥៩ ២៨៥ | ៥៩ ២៩៩ |
| មធ្យមសិក្សាបឋមភូមិ | តម្រូវការគ្រូសរុប | ២៨ ៤០៤ | ២៨ ៤៣៨ | ២៨ ៤៨៤ | ២៨ ៥៤២ | ២៨ ៥៦៤ |
| មធ្យមសិក្សាទុតិយភូមិ | តម្រូវការគ្រូសរុប | ១៣ ៤៤០ | ១៣ ៧៥៥ | ១៣ ៧៧៥ | ១៣ ៨០០ | ១៣ ៨១០ |

## ៥.២ ការផ្តល់ហិរញ្ញប្បទាន ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤

ការព្យាករណ៍សេដ្ឋកិច្ចនិងហិរញ្ញវត្ថុដល់ឆ្នាំ២០៣០ គឺមានការលំបាកខ្លាំង។ ការសន្មត់អំពីកំណើននិងស្ថេរភាពនៃសេដ្ឋកិច្ចជារួម ផ្នែកនេះ បង្ហាញពីការប៉ាន់ស្មានធនធានដែលអាចមានសម្រាប់វិស័យអប់រំពីឆ្នាំ ២០១៦ ដល់ ២០៣០។ ម៉ូដែលនេះធ្វើការសន្មត់ដូចខាងក្រោម នៅពេលធ្វើចំណោលធនធានសម្រាប់ឆ្នាំមួយចំនួនដូចក្នុងតារាងទី២៥។ ជាដំបូង សេដ្ឋកិច្ចកម្ពុជាដំណើរការបានយ៉ាងល្អរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ និងត្រូវបានធ្វើចំណោលថា អត្រាកំណើននេះនៅបន្តមានទៀតរហូតដល់ឆ្នាំ ២០៣០។ បើតាមការព្យាករណ៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិកំណើនផ.ស.សរបស់កម្ពុជានឹងនៅបន្តចន្លោះពី ៧ ភាគរយ ទៅ ៨ ភាគរយ ពីឆ្នាំ២០១៦ ដល់ ២០៣០។ បន្ទាប់មក ការវិភាជន៍ថវិកាសម្រាប់វិស័យអប់រំគិតជាភាគរយនៃផ.ស.សនឹងបន្តកើនឡើងបន្តិចម្តងៗពី ២,៣ ភាគរយ ឆ្នាំ ២០១៦ ដល់ ៤,៥ ភាគរយ ឆ្នាំ២០៣០។ ដូចគ្នាដែរ ចំណាយវិស័យអប់រំគិតជាភាគរយនៃចំណាយសរុបរបស់រដ្ឋាភិបាលនឹងកើនឡើងពី ១៨,៣ ភាគរយ ឆ្នាំ២០១៦ ដល់ ២០ ភាគរយ ឆ្នាំ២០៣០។ ការធ្វើចំណោលទាំងនេះ បង្ហាញថាកម្ពុជានឹងឆ្លើយតបតាមចំណុចដៅអន្តរជាតិសម្រាប់ចំណាយលើការអប់រំ។ វិស័យអប់រំនៅទទួលបានប្រយោជន៍ពីកំណើនផ.ស.ស រំពឹងទុកនេះ។

## តារាងទី ២៤៖ ការប៉ាន់ស្មានធនធានដែលមានសម្រាប់វិស័យអប់រំ

*(គិតជាលានដុល្លារសហរដ្ឋអាមេរិក)*

| បរិយាយ | ឆ្នាំគោល ២០១៦ | ២០១៩ | ២០២៣ | ២០២៨ | ២០៣០ |
|---|---|---|---|---|---|
| កំណើន ផ.ស.ស ទៅតាមការធ្វើចំណោល (IMF) | ៧% | ៧,៣% | ៧,៥% | ៧,៨% | ៨% |
| ផ.ស.ស | ១៩,៨៥៥ | ២៤,៤៧៤ | ៣២,៥៩៩ | ៤៧,២៣៦ | ៥៥,០៣៥ |
| ផ.ស.ស គិតក្នុងតម្លៃថេរឆ្នាំ ២០០០ | ១១ ៥១៦ | ១៤ ១៧១ | ១៨,៨៣៣ | ២៧,២១៤ | ៣១,៨៥៤ |
| ភាគរយនៃចំណាយសម្រាប់វិស័យអប់រំ | ២,៣% | ៣,៥% | ៣,៩% | ៤,៣% | ៤,៥% |
| ភាគរយនៃចំណាយលើវិស័យអប់រំគិតជាភាគរយនៃចំណាយរបស់រដ្ឋាភិបាល | ១៨,៣% | ១៨,៦% | ១៩,១% | ១៩,៧% | ២០,០% |
| ថវិកាវិភាជន៍សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា | ៥៤៦ | ៩១៥ | ១ ១៥៩ | ១ ៤៦៤ | ១ ៥៨៦ |
| ផែនការវិនិយោគអាទិភាពសម្រាប់វិស័យអប់រំ | ១០៦ | ១០៥ | ១០១ | ១០១ | ១០១ |

តារាងទី២៤ បង្ហាញពីតម្រូវការធនធានហិរញ្ញវត្ថុរួម (មូលធន និងចរន្ត) ដែលបានប៉ាន់ស្មានសម្រាប់ឆ្នាំចន្លោះពីឆ្នាំ២០១៦ ដល់ ២០៣០។ ចំណាយទាំងនេះត្រូវបានបែងចែកលម្អិតតាមអនុវិស័យ ដើម្បីឱ្យក្រសួងអប់រំ យុវជន និងកីឡាកំណត់ និងធ្វើការបែងចែកធនធានហិរញ្ញវត្ថុទៅតាមការចាំបាច់។ ឆ្នាំ២០១៦ ជាឆ្នាំគោល ដែលមានការប៉ាន់ប្រមាណថា វិស័យអប់រំត្រូវការធនធានហិរញ្ញវត្ថុប្រមាណជា ៧៦៤ លានដុល្លារអាមេរិក ដែលបរិមាណនេះនឹងកើនឡើងដល់ ១ ២៨៥ លានដុល្លារអាមេរិក ឆ្នាំ ២០២៣ និង ១ ៧២៧ លានដុល្លារអាមេរិក ឆ្នាំ២០៣០។ កំណើនយ៉ាងឆាប់រហ័សនៃតម្រូវការធនធានហិរញ្ញវត្ថុចន្លោះពីឆ្នាំ២០១៦ ដល់ ២០៣០ ដែលឆ្លុះបញ្ចាំងពីផែនការពង្រីកគ្រប់អនុវិស័យទាំងអស់ ជាពិសេសអនុវិស័យអប់រំកម្រិតមូលដ្ឋាន។ ដូចតារាងខាងក្រោម អនុវិស័យអប់រំបឋមសិក្សាមានតម្រូវការថវិកាច្រើនជាងគេ នៅក្នុងផែនទីបង្ហាញផ្លូវនេះ (៤៨,៤ ភាគរយ) បន្ទាប់មកគឺ មធ្យមសិក្សា និងបច្ចេកទេស (២៨,០ ភាគរយ)។ អនុវិស័យ ២ ផ្សេងទៀត (មត្តេយ្យសិក្សា និងឧត្តមសិក្សា)មានចំណាយថវិកាប្រមាណជា ៩ ភាគរយ ដូចគ្នា។

## តារាងទី ២៥៖ ការព្យាករណ៍ចំណាយ (ចំណាយចរន្ត និងចំណាយមូលធន)

*(គិតជាលានដុល្លារសហរដ្ឋអាមេរិក)*

| ភូមិសិក្សា | ឆ្នាំគោល ២០១៦ | ២០១៩ | ២០២៣ | ២០២៨ | ២០៣០ |
|---|---|---|---|---|---|
| មត្តេយ្យសិក្សា | ៦៩,៥២ (៩,១%) | ៩៣,៦០ | ១១៥,៦៥ | ១៤៣,៩១ | ១៥៥,៤៣ |
| បឋមសិក្សា | ៣៦៩ (៤៨,៣%) | ៥០៣,៤៦ | ៦២៤,៦៣ | ៧៧៧,២៧ | ៨៣៩,៤៩ |
| មធ្យមសិក្សានិងបច្ចេកទេស | ២១៣,១២(២៨,០%) | ២៩១,៥១ | ៣៦០,១៨ | ៤៤៨,២០ | ៤៨៤,០៨ |
| ឧត្តមសិក្សា | ៧០ (៩,២%) | ៩៥,៧៣ | ១១៨,២២ | ១៤៧,១១ | ១៥៨,៨៨ |
| អប់រំក្រៅប្រព័ន្ធ | ២២,១៦ (២,៩%) | ២៩,៦៤ | ៣៥,៩៨ | ៤៤,៧៧ | ៤៨,៣៦ |
| ការអភិវឌ្ឍយុវជន | ២,៣ (០,៣%) | ៣,១៧ | ៤,៦២ | ៥,៧៦ | ៦,២២ |
| អប់រំកាយ និងកីឡា | ១៦,៨ (២,២%) | ២២,៨៨ | ២៥,៧ | ៣១,៩៨ | ៣៤,៥៤ |
| **ថវិកាសរុបដែលត្រូវការ** | **៧៦៤** | **១ ០៤០** | **១ ២៩៩** | **១ ៥៩៩** | **១ ៧២៧** |

### *គម្លាតថវិកា*

តារាងទី២៦ បង្ហាញពីភាពខុសគ្នារវាងតួលេខតម្រូវការហិរញ្ញវត្ថុដែលបានធ្វើចំណោល និងធនធានថវិកាដែលមានសម្រាប់វិស័យអប់រំ។ ការប្រៀបធៀបចំណោលធនធានដែលមាន និងតម្រូវការហិរញ្ញវត្ថុសង្កេតឃើញថា ខ្វះថវិកា ១១២ លានដុល្លារអាមេរិក នៅឆ្នាំគោល។ កង្វះថវិកា ២០ លានដុល្លារអាមេរិក ឆ្នាំ២០១៩ ដែលជាឆ្នាំដំបូងនៃការចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ និងឆ្នាំ២០២៣ ក៏មានកង្វះថវិកា ២៥ លានដុល្លារអាមេរិកផងដែរ។ ឆ្នាំ២០២៨ និង ២០៣០ ក៏គម្លាតថវិកាផងដែរ គឺ ៣៥ លានដុល្លារអាមេរិក និង ៤៥ លានដុល្លារអាមេរិក។

## តារាងទី ២៦៖ គម្លាតថវិកា

*(គិតជាលានដុល្លារសហរដ្ឋអាមេរិក)*

| បរិយាយ | ២០១៦ | ២០១៩ | ២០២៣ | ២០២៨ | ២០៣០ |
|---|---|---|---|---|---|
| ធនធានសរុបដែលមានសម្រាប់វិស័យអប់រំ | ៥៤៦ | ៩១៥ | ១ ១៥៩ | ១ ៤៦៤ | ១ ៥៨៦ |
| តម្រូវការធនធានហិរញ្ញវត្ថុសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ | ៧៦៤ | ១ ០៤០ | ១ ២៦០ | ១ ៥៦៤ | ១ ៦៨២ |
| ផែនការវិនិយោគអាទិភាពសម្រាប់វិស័យអប់រំ | ១០៦ | ១០៥ | ១០១ | ១០១ | ១០១ |
| កង្វះថវិកា | -១១២ | -២០ | -២៥ | -៣៥ | -៤៥ |
| ភាគរយនៃកង្វះថវិកាធៀបនឹងតម្រូវការសរុប | ១៤,៧% | ១,៩២% | ១,៩៨% | ២,២៣% | ២,៦៧% |

ជារួម ការអភិវឌ្ឍថ្មីៗកន្លងមកនេះបង្ហាញថា ធនធានក្នុងស្រុកដែលបំពេញតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ហិរញ្ញប្បទានដល់ការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ នៅកម្ពុជា។ និន្នាការកំណើនសេដ្ឋកិច្ចបង្ហាញថា រាជរដ្ឋាភិបាលនឹងអាចរក្សាកំណើននេះបន្តទៀតក្នុងរយៈពេលនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤នេះ។ ផែនទីបង្ហាញផ្លូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤នឹងក្លាយជាមូលដ្ឋានជាយុទ្ធសាស្ត្រមួយសម្រាប់កៀរគរធនធានសម្រាប់វិស័យអប់រំផងដែរ។ ដៃគូអភិវឌ្ឍបានរួមចំណែកគួរឱ្យកត់សម្គាល់ក្នុងវិស័យអប់រំនៅកម្ពុជាកន្លងមក ហើយសង្ឃឹមថានឹងបន្តរួមចំណែកបន្ថែមទៀតនៅក្នុងរយៈពេល ១០ ទៅ ១២ឆ្នាំខាងមុខ។ កម្ពុជាគឺកាន់តែមានសមត្ថភាពរៀបចំរបៀបវារៈអភិវឌ្ឍវិស័យអប់រំដោយខ្លួនឯង និងអាចគ្រប់គ្រង សម្របសម្រួលមូលនិធិអភិវឌ្ឍន៍ដោយខ្លួនឯង ជាពិសេសការដាក់ឱ្យអនុវត្តនូវផែនការយុទ្ធសាស្ត្រ និងអភិក្រមគ្រប់គ្រងផ្អែកតាមលទ្ធផលកាលពីពេលថ្មីៗនេះ។ ប្រទេសកម្ពុជានឹងបន្តការគាំទ្រពីអ្នកផ្តល់ជំនួយ ដែលធ្លាប់តែផ្តល់ជំនួយកន្លងមកផង និងអ្នកផ្តល់ជំនួយថ្មីៗផង។ ប្រសិនបើ ធនធានចាំបាច់ទាំងនេះពុំមាននោះទេ រាជរដ្ឋាភិបាលគួរស្វែងរកធនធានហិរញ្ញវត្ថុពីប្រភពផ្សេងទៀតដើម្បីបំពេញកង្វះខាត។ រាជរដ្ឋាភិបាលគួរបន្តលើកទឹកចិត្តឱ្យតួអង្គផ្សេងៗដូចជា អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ក៏ដូចជាអ្នកវិនិយោគក្នុងវិស័យឯកជនចូលរួមផ្តល់សេវាអប់រំមួយចំនួន(ឧទាហរណ៍ការបណ្តុះបណ្តាលជំនាញ កម្មវិធីអក្ខរកម្ម បច្ចេកវិទ្យា និងសារគមនាគមន៍ ការអប់រំកម្រិតឧត្តមសិក្សា)។ គោលនយោបាយស្តីពីភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលនឹងជួយកៀរគរធនធានបន្ថែមទៀតសម្រាប់វិស័យអប់រំ។

## ៦. ការពិនិត្យតាមដាន និងវាយតម្លៃ

ការពិនិត្យតាមដានជាប្រចាំ គឺមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ភាពជោគជ័យនៃការអនុវត្ត និងការសម្រេចចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។ មេរៀនពិសោធន៍ដ៏សំខាន់ដែលទទួលបានពីការអប់រំសម្រាប់ទាំងអស់គ្នា គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ គឺដំណើរការតាមដាន និងពិនិត្យឡើងវិញដែលមានលក្ខណៈជាប្រព័ន្ធ ជាគន្លឹះយ៉ាងសំខាន់ក្នុងការឈានទៅសម្រេចគោល-នយោបាយ។ ដូចនេះ របៀបវារៈអប់រំ ២០៣០ ក៏បានលើកឡើងឱ្យមានក្របខណ្ឌពិនិត្យតាមដាន និងពិនិត្យឡើងវិញ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ប្រទាក់ក្រឡាគ្នា ដោយគ្របដណ្តប់លើការពិនិត្យឡើងវិញនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកល និងការវាយតម្លៃនៅកម្រិតនីមួយៗធ្វើឡើង ដើម្បីសម្រេចគោលបំណងផ្សេងៗគ្នា ប៉ុន្តែបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក។ ក្នុងបរិបទដែលផ្តោតលើលទ្ធផលសិក្សា ការពិនិត្យតាមដានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ទាមទារឱ្យមានការប្រើប្រាស់អភិក្រមពហុវិស័យសម្រាប់វាស់វែងវឌ្ឍនភាពនានា ដែលគ្របដណ្តប់លើធនធានដំណើរការ លទ្ធផល និងផលសម្រេច ដោយប្រើប្រាស់ទិន្នន័យដែលមានគុណភាពខ្ពស់ជាជំនួយ។ ដើម្បីវាស់វែង និងពិនិត្យតាមដានសមធម៌ក្នុងការអប់រំ ចាំបាច់ត្រូវមានទិន្នន័យតាមប្រភេទនានាសម្រាប់អ្នកតាក់តែងគោលនយោបាយ និងអ្នករៀបចំផែនការ ដែលគ្របដណ្តប់លើគ្រប់ទម្រង់និងប្រភេទនៃបញ្ហាលំបាក។ សូចនាករមាន ៤ កម្រិត គឺកម្រិតសកល កម្រិតប្រធានបទ កម្រិតតំបន់ និងកម្រិតជាតិសម្រាប់ពិនិត្យតាមដានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ។

របាយការណ៍ពិនិត្យតាមដានការអប់រំជាសកល គឺជាយន្តការសកលសម្រាប់ពិនិត្យតាមដាន និងរាយការណ៍អំពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ និងការអប់រំទាក់ទិននឹងគោលដៅផ្សេងៗទៀត។ យន្តការនេះនឹងរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រនៅថ្នាក់ជាតិ និងថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ។ លើសពីនេះក៏នឹងមានការពិនិត្យឡើងវិញនៅថ្នាក់តំបន់ផងដែរ ក្នុងគោលបំណងចម្បងគឺ ចែករំលែកឧត្តមានុវត្តន៍ និងនវានុវត្តន៍ ក៏ដូចជាការសិក្សារៀនសូត្រពីគ្នាទៅវិញទៅមក។ អង្គការយូណេស្កូប្រចាំទីក្រុងបាងកក មានបទពិសោធន៍ក្នុងការផ្តល់នូវមូលដ្ឋានរឹងមាំមួយសម្រាប់ពិនិត្យតាមដានវឌ្ឍនភាពនៃការអប់រំសម្រាប់ទាំងអស់គ្នានៅថ្នាក់តំបន់ ហើយការិយាល័យនេះនឹងបន្តបំពេញតួនាទីទៀត ក្នុងនាមជាអ្នកផ្សារភ្ជាប់ទំនាក់ទំនងរវាងការពិនិត្យឡើងវិញថ្នាក់ជាតិ និងថ្នាក់សកល។ វេទិកាថ្នាក់តំបន់ដូចជា កិច្ចប្រជុំថ្នាក់តំបន់អាស៊ីប៉ាស៊ីភិកស្តីពីការអប់រំនឹងផ្តល់ការគាំទ្រដល់ការអនុវត្តគោលដៅប្រកបដោយចីរភាពទី៤នៅក្នុងតំបន់នេះ ព្រមទាំងជួយលើកកម្ពស់កិច្ចសហ-ប្រតិបត្តិការនៅថ្នាក់តំបន់ក៏ដូចជាការរៀនសូត្រពីគ្នាទៅវិញទៅមក។

## ៦.១ រចនាសម្ព័ន្ធ និងដំណើរការនៃការពិនិត្យតាមដាន និងវាយតម្លៃ

អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការនៃក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ចទទួលខុសត្រូវរួមលើការរៀបចំផែនការ ការគ្រប់គ្រងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ និងការពិនិត្យតាមដានលើវិស័យអប់រំ។ អគ្គនាយកដ្ឋានមាននាយកដ្ឋាន ៤ ផ្តោតលើការងារសំខាន់ៗ ៤ គឺផែនការ គោល-នយោបាយ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ និងពិនិត្យតាមដាននិងវាយតម្លៃ។ មន្ទីរអប់រំ យុវជន និងកីឡាមានតួនាទីពិនិត្យតាមដានបន្ថែមពីលើមុខងាររៀបចំផែនការ រដ្ឋបាល និងអភិវឌ្ឍរបស់ខ្លួន។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ គ្រប់គ្រងការអនុវត្តគោលនយោបាយ និងកម្មវិធីអប់រំ ព្រមទាំងពិនិត្យតាមដានដំណើរការរៀន និងបង្រៀន និងគ្រប់គ្រងការអនុវត្តថវិកាកម្មវិធីសម្រាប់សាលារៀន និងពិនិត្យតាមដានការប្រើប្រាស់ថវិកា។

នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ការពិនិត្យតាមដានវត្ថុបំណងវិស័យអប់រំធ្វើឡើងនៅ ៣ កម្រិត (វិទ្យាស្ថានអន្តរជាតិសម្រាប់ផែនការអប់រំ ឆ្នាំ២០១៦)។ ការពិនិត្យតាមដាន និងវាយតម្លៃកម្រិតទី១ គឺការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងការពិនិត្យឡើងវិញចុងក្រោយនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដោយមានការដាក់ចេញនូវសូចនាករស្នូលសម្រាប់ប្រព័ន្ធទាំងមូលផង និងសូចនាករកម្រិតផលសម្រេចសម្រាប់អនុវិស័យផង។

ដោយឡែក កម្រិតទី ២ មានយន្តការពីរសម្រាប់ធ្វើការពិនិត្យតាមដាន និង ឬ វាយតម្លៃវឌ្ឍនភាពនៃវិស័យអប់រំ គឺសន្និបាតអប់រំជាតិប្រចាំឆ្នាំ និងសន្និបាតអប់រំថ្នាក់រាជធានី-ខេត្តប្រចាំឆ្នាំ។ សន្និបាតអប់រំមានការចូលរួមពីមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យលើសមិទ្ធផលដែលសម្រេចបានក្នុងវិស័យអប់រំ ធៀបនឹងផលសម្រេច ឬ លទ្ធផល និងដំណើរការដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ។ ដំណើរការរៀបចំសន្និបាតអប់រំ ក្រសួងបានរៀបចំរបាយការណ៍សន្និបាតអប់រំដោយបានប្រមូលចងក្រងព័ត៌មានអំពីវឌ្ឍនភាពដែលសម្រេចបានតាមកម្មវិធី សកម្មភាពជាក់លាក់ ព្រមទាំងធាតុចូលមកពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ក៏ដូចជារបាយការណ៍ពាក់កណ្តាលអាណត្តិអំពីផែនការប្រតិបត្តិប្រចាំឆ្នាំ។

ការពិនិត្យតាមដានកម្រិតទី ៣ គឺធ្វើឡើងដោយមន្ត្រីការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដែលទទួលខុសត្រូវពិនិត្យតាមដានការបំពេញការងាររបស់សាលារៀននីមួយៗ ក្នុងការអនុវត្តផែនការសកម្មភាព ដោយមានការណែនាំពីមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។ ការិយាល័យ

អប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ធ្វើអធិការកិច្ចសាលារៀន ២ ដងក្នុង ១ឆ្នាំ ដោយសហការជាមួយក្រុមបំប៉ននិងពិនិត្យតាមដានក្រុង ស្រុក ខណ្ឌ។ ការធ្វើអធិការកិច្ចនេះ ការិយាល័យអប់រំ យុវជន និងកីឡាក្រុងស្រុក ខណ្ឌធានាថា សាលារៀនសម្រេចបានវឌ្ឍនភាព ដូចសកម្មភាពដែលបានគ្រោងទុក ហើយប្រសិនបើចាំបាច់ ពួកគេនឹងផ្តល់នូវវិធានការកែលម្អមួយចំនួនក្នុងករណីដែលមានការសម្រេចបានវឌ្ឍនភាពយឺតយ៉ាវ។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌត្រូវផ្ញើរបាយការណ៍ជូនមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តជារៀងរាល់ឆ្នាំ ដែលរបាយការណ៍ទាំងនេះផ្តល់នូវព័ត៌មានក៏ដូចជាការទទួលព័ត៌មានគ្រឡប់អំពីសមិទ្ធផលដែលសម្រេចបាន។ សាលារៀននីមួយៗរៀបចំផែនការអភិវឌ្ឍន៍សាលារៀន និងប្រមូលព័ត៌មានអំពីវឌ្ឍនភាពដែលសាលារៀនសម្រេចបាន ព្រមទាំងការអនុវត្តចំណាយថវិកា។ ជារៀងរាល់ឆ្នាំ សាលារៀនត្រូវផ្ញើរបាយការណ៍ និងផ្តល់ទិន្នន័យស្ថិតិអប់រំទៅនាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ។

ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃកម្ពុជា ផ្តល់ឱកាសឱ្យមានការចូលរួមពីដៃគូអភិវឌ្ឍក្នុងការពិនិត្យឡើងវិញវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ ត្រូវបានបង្កើតឡើង ដើម្បីលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងភាពជាដៃគូក្នុងការអភិវឌ្ឍសម្រាប់គាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។ លើសពីនេះ ក្រុមការងារវិស័យអប់រំ គឺជាវេទិកាមួយរបស់ដៃគូអភិវឌ្ឍដែលកំពុងធ្វើសកម្មភាពក្នុងវិស័យអប់រំ។ យន្តការទាំងពីរនេះបានបំពេញតួនាទីប្រកបដោយប្រសិទ្ធភាពក្នុងការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីសម្រេចគោលបំណងប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ និងពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ក្របខណ្ឌយន្តការទាំងនេះ ការពិនិត្យឡើងវិញរួមគ្នាលើវិស័យ ត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំដោយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍ ដើម្បីវាយតម្លៃពីលទ្ធផលដែលសម្រេចបានធៀបនឹងចំណុចដៅសូចនាករសំខាន់ៗ កំណែទម្រង់ជាអាទិភាព និងផលសម្រេចកម្រិតអនុវិស័យ ក៏ដូចជាសូចនាករគុណភាពនៃការអប់រំ។ ការពិនិត្យឡើងវិញក៏ជួយសម្របសម្រួលក្នុងចំណោមអ្នកផ្តល់ជំនួយផងដែរ ដើម្បីកាត់បន្ថយការធ្វើសកម្មភាពត្រួតគ្នា បង្កើនការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក ក៏ដូចជាបង្កើនប្រសិទ្ធភាពរួមនៃការវិភាជន៍ធនធានក្នុងវិស័យអប់រំ។ អង្គវិបស្សនាអប់រំប្រចាំឆ្នាំ ជាកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍន៍ ដើម្បីរួមគ្នាឆ្លុះបញ្ចាំងពីវឌ្ឍនភាពដែលសម្រេចបានក្នុងវិស័យអប់រំ ស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈម

ក្នុងការអនុវត្ត និងដាក់ចេញអាទិភាពសម្រាប់ឆ្នាំបន្ទាប់។ ការពិនិត្យឡើងវិញ និងការពិនិត្យតាមដានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ នឹងប្រើប្រាស់រចនាសម្ព័ន្ធ និងដំណើរការដែលមានស្រាប់។

## ៦.២ ការពិនិត្យតាមដានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤-ការអប់រំ ឆ្នាំ២០៣០

ក្របខណ្ឌពិនិត្យតាមដាន នឹងរៀបចំឡើងដោយផ្អែកតាមបទពិសោធន៍កន្លងមករបស់កម្ពុជា និងមេរៀនពិសោធន៍ដែលទទួលបានអំឡុងពេលពិនិត្យតាមដានការអប់រំសម្រាប់ទាំងអស់គ្នា គោលដៅអភិវឌ្ឍសហស្សវត្សរ៍ បទពិសោធន៍មកពីការពិនិត្យតាមដាននៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំពេលថ្មីៗនេះ និងតម្រូវការទិន្នន័យចាំបាច់ ដើម្បីពិនិត្យតាមដានចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤។ រយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ការពិនិត្យតាមដានចំណុចដៅនៃការអប់រំសម្រាប់ទាំងអស់គ្នានៅកម្ពុជា បានជួយកែលម្អគួរឱ្យកត់សម្គាល់ចំពោះការប្រមូល និងការប្រើប្រាស់ទិន្នន័យក្នុងលក្ខណៈជាប្រព័ន្ធ និងប្រទាក់ក្រឡាគ្នា។ ក្រសួងអប់រំ យុវជន និងកីឡាអាចផលិតទិន្នន័យភាគច្រើនដោយខ្លួនឯង។ ក្រសួងអប់រំ យុវជន និងកីឡាមានប្រព័ន្ធប្រមូលទិន្នន័យ និងរាយការណ៍ពីវិស័យអប់រំដែលអាចផ្តល់នូវទិន្នន័យបែបរដ្ឋបាលដ៏ច្រើន និងមានប្រយោជន៍សម្រាប់ពិនិត្យតាមដានផ្នែកខ្លះនៃចំណុចដៅគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានពង្រឹងសមត្ថភាពរបស់ខ្លួន ដើម្បីទាញប្រយោជន៍ពីទិន្នន័យជំរឿន និងទិន្នន័យអង្កេតតាមគ្រួសារផងដែរ។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងធ្វើការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ដើម្បីតាមដានការសិក្សារៀនសូត្ររបស់សិស្ស។ បច្ចុប្បន្ននេះមានការប្រឹងប្រែងយ៉ាងច្រើន ដើម្បីអភិវឌ្ឍសមត្ថភាពស្ថិតិ និងរួមចំណែកដល់ការកំណត់សូចនាករសកល ក៏ដូចជាកំណត់ពីសូចនាករដែលឆ្លុះបញ្ចាំងពីបញ្ហាប្រឈមដែលកំពុងជួបប្រទះឱ្យបានល្អបំផុត។ កម្ពុជាក៏បានបង្កើតយន្តការសម្រាប់រាយការណ៍ តាមដាន និងវាយតម្លៃដូចលើកឡើងខាងលើផងដែរ។ ការខិតខំទាំងនេះ រួមជាមួយនឹងកិច្ចប្រឹងប្រែងអភិវឌ្ឍសមត្ថភាពជាច្រើនផ្សេងទៀត ដែលធ្វើឡើងដោយមានការគាំទ្រពីដៃគូអភិវឌ្ឍ ដូចជា ការគាំទ្រដែលផ្តល់ដោយវិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូ ក្រោមក្របខណ្ឌនៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពវិស័យអប់រំ សុទ្ធតែបានផ្តោតជាសំខាន់លើការពិនិត្យតាមដានវឌ្ឍនភាពក្នុងការឈានទៅសម្រេចចំណុចដៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។

ទោះជាយ៉ាងណា ការឈានពីគោលដៅអប់រំសម្រាប់ទាំងអស់គ្នាទៅចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ មិនត្រឹមតែត្រូវការទិន្នន័យច្រើននិងល្អជាងមុនប៉ុណ្ណោះទេ ថែមទាំងត្រូវការរបៀបធ្វើការងារ និងគ្រប់គ្រងទិន្នន័យតាមបែបថ្មីផងដែរដើម្បីឱ្យពួកគេអាចធ្វើការពិនិត្យតាមដានវឌ្ឍនភាពឈានទៅសម្រេចចំណុចដៅគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ប្រកបដោយ

ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។ របៀបវារៈអប់រំថ្មីនេះមានភាពទូលំទូលាយ ក្រសួងអប់រំ យុវជន និងកីឡាទទួលស្គាល់ថា ដើម្បីពិនិត្យតាមដានវឌ្ឍនភាពលើការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤-ការអប់រំឆ្នាំ២០៣០ ចាំបាច់ត្រូវមានក្របខណ្ឌពិនិត្យតាមដានថ្មី ដែលមិនត្រឹមតែរឹងមាំ និងល្អិតល្អន់ប៉ុណ្ណោះទេ ថែមទាំងត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយជាងមុនផងដែរ។ ការវាយតម្លៃដែលធ្វើឡើងកាលពីពេលថ្មីៗនេះលើទិន្នន័យដែលមាន និងគុណភាពទិន្នន័យដោយវិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូបានបង្ហាញថា កង្វះទិន្នន័យនៅក្នុងផ្នែកជាច្រើនដូចក្នុងរូបភាពខាងក្រោម ដោយទិន្នន័យផ្នែកខ្លះ មិនធ្លាប់ប្រមូលទាល់តែសោះ ឬ ទិន្នន័យដែលប្រមូលបាននៅតិចតួច ឬ ពុំគ្រប់គ្រាន់។ កង្វះទិន្នន័យធំជាងគេ គឺទិន្នន័យអំពីអាហារូបករណ៍ (៤.ខ) ការអប់រំភាពជាពលរដ្ឋសកលសម្រាប់អភិវឌ្ឍន៍ប្រកបដោយចីរភាព (៤.៧) បំណិន (៤.៤) បរិយាកាសសិក្សា (៤.ក)។ល។ ទិន្នន័យដែលមាន ពុំអាចវិភាគអំពីភាពខុសគ្នានិងនិន្នាការរវាងក្រុមផ្សេងៗគ្នាឡើយ ដោយសារតែពុំមានការបែងចែកទិន្នន័យទៅតាមជនជាតិដើម ពិការភាព ភេទ ទីតាំងភូមិសាស្ត្រ កម្រិតចំណូល។ល។ ការកសាងសមត្ថភាពស្ថិតិ និងការពង្រឹងប្រព័ន្ធស្ថិតិអប់រំជាតិដូចជា នាយកដ្ឋានផែនការ ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ និងពិនិត្យតាមដាននិងវាយតម្លៃក្រោមចំណុះអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការមានតួនាទីយ៉ាងសំខាន់។ ការអភិវឌ្ឍសមត្ថភាព គឺជាជំហានសំខាន់ដំបូងក្នុងការបង្កើតប្រព័ន្ធពិនិត្យតាមដាន។ សំខាន់ផងដែរ គឺបង្កើតឱ្យមានការសម្របសម្រួលប្រកបដោយមានប្រសិទ្ធភាពរវាងក្រសួង-ស្ថាប័ននានា និងការិយាល័យស្ថិតិជាតិ ដែលជាស្ថាប័នទទួលខុសត្រូវលើការប្រមូលទិន្នន័យ។ វិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូបាននិងកំពុងគាំទ្រក្រសួងអប់រំ យុវជន និងកីឡាដើម្បីបង្កើនយន្តការមួយឱ្យគ្រប់អង្គភាពផលិតទិន្នន័យអាចសហការយ៉ាងជិតស្និទជាមួយនឹងវិទ្យាស្ថានជាតិស្ថិតិ ដើម្បីធានាឱ្យទិន្នន័យមានភាពស៊ីសង្វាក់គ្នា និងអាចរាយការណ៍ពីចំណុចដៅនានាក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។

**រូបភាព ៖ សូចនាករដែលមាននៅក្នុងប្រទេសកម្ពុជា តាមចំណុចដៅ**




*ប្រភព៖ វិទ្យាស្ថានស្ថិតិអង្គការ យូណេស្កូ (២០១៧)*

### ៦.២.១ ក្របខណ្ឌសូចនាករជាតិ សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤

ក្រសួងអប់រំ យុវជន និងកីឡាកំពុងបង្កើតក្របខណ្ឌសូចនាករថ្នាក់ជាតិសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤។ ក្របខណ្ឌនេះនឹងបន្សុំស្របតាមសូចនាករកម្រិតសកល និងសូចនាករតាមប្រធានបទ ដើម្បីសម្របសម្រួលការពិនិត្យតាមដានវឌ្ឍនភាព ក្នុងការឈានទៅសម្រេចតាមចំណុចដៅ ដោយមានការប្រៀបធៀបរវាងប្រទេសមួយ និងប្រទេសមួយទៀត។ ក្របខណ្ឌនេះក៏ស្របទៅតាមគំនិតផ្តួចផ្តើមពិនិត្យតាមដានការអប់រំឆ្នាំ ២០៣០ នៅថ្នាក់តំបន់ផងដែរ។ ក្របខណ្ឌនេះនឹងបញ្ចូលសូចនាករពាក់ព័ន្ធនឹងបរិបទដែលមានសារៈសំខាន់សម្រាប់ពិនិត្យតាមដាន និងតម្រង់ការអភិវឌ្ឍវិស័យអប់រំជាតិ។ ក្របខណ្ឌនេះទទួលស្គាល់ពីសារៈសំខាន់នៃការបែងចែកទិន្នន័យតាមប្រភេទដើម្បីបំពេញតាមមហិច្ឆតាមិនទុកនរណាម្នាក់ចោលដែលជាស្នូលនៃរបៀបវារៈឆ្នាំ ២០៣០។ ទិន្នន័យសម្រាប់សូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ផ្អែកទៅតាមប្រព័ន្ធស្ថិតិជាតិ ពោលគឺប្រើប្រាស់ទិន្នន័យជាច្រើនបន្ថែមទៀតលើទិន្នន័យរដ្ឋបាលនៃប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងករណីដែលអាចធ្វើបាន នឹងមានការបែងចែកសូចនាករទៅតាមភេទ និងអាយុ ប្រាក់ចំណូល ជនជាតិដើមភាគតិច ពិការភាព និងទីតាំងភូមិសាស្រ្ត។ គោលការណ៍នៃការប្រៀបធៀបជាលក្ខណៈអន្តរជាតិ ត្រូវយកមកពិចារណាក្នុងពេលរៀបចំសូចនាករទាំងនេះ។ ក្រុមការងារបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលមានការគាំទ្រពីវិទ្យាស្ថានស្ថិតិរបស់អង្គការយូណេស្កូ បានស្នើឡើងរចនាសម្ព័ន្ធដំបូងនៃក្របខណ្ឌសូចនាករនេះ ដូចបង្ហាញក្នុងតារាងទី២៧។ សូចនាករទាំងនេះ មានទំនាក់ទំនងផ្ទាល់ជាមួយនឹងអាទិភាព និងលទ្ធផលក្នុងផែនទីបង្ហាញផ្លូវនេះ។

**តារាងទី ២៧ ៖ ក្របខណ្ឌសូចនាករជាតិសម្រាប់ពិនិត្យតាមដានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤-ការអប់រំឆ្នាំ ២០៣០**

| អាទិភាពគោលនយោបាយ | លទ្ធផល | ចំនួននៃសូចនាករ | | |
|---|---|---|---|---|
| | | កម្រិតសកល/តាមប្រធានបទ | បន្ថែម | សរុប |
| អាទិភាពទី ១៖ កុមារី និងកុមារាគ្រប់រូប ទទួលបានការគាំពារនិងការអប់រំ កុមារតូច និងការអប់រំមត្តេយ្យសិក្សាប្រកបដោយ | ១.១ ការត្រៀមខ្លួនសម្រាប់ចូលរៀននៅបឋមសិក្សា និងការបង្កើនការទទួលបានសេវាគាំពារ និងអប់រំកុមារតូច និង ការអប់រំមត្តេយ្យសិក្សាប្រកបដោយគុណភាព (៤.២) | ៩ | ៤ | ១៣ |

| | | | | |
|---|---|---|---|---|
| គុណភាព និងបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន (បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) ដោយឥតគិតថ្លៃ ប្រកបដោយសមធម៌ និងគុណភាព ដែលទទួលបានលទ្ធផលសិក្សា ប្រកបដោយប្រសិទ្ធភាព និងភាពឆ្លើយតប | ១.២ ការទទួលបាន និងការបញ្ចប់ការអប់រំកម្រិតមូលដ្ឋានរយៈពេល ៩ឆ្នាំ (ការអប់រំបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) ដោយមានគុណភាពប្រកបដោយសមធម៌ | ៧ | ៧ | ១៤ |
| | ១.៣ អ្នកសិក្សាគ្រប់រូបបានទទួល **ចំណេះដឹង និងបំណិន និងគុណតម្លៃ** ដើម្បីបំពេញតួនាទីជាពលរដ្ឋសកល និងចេះគោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ វប្បធម៌សន្តិភាព អហិង្សា និងវប្បធម៌ចម្រុះ(៤.៧) ដោយមានការផ្តល់ធនធាន និងគ្រូដែលមានសមត្ថភាពគ្រប់គ្រាន់ (៤.ខ, ៤.គ) | ១៣ | ៤ | ១៧ |
| អាទិភាពទី ២៖ កុមារី និងកុមារទាំងអស់ បានបញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិ ដោយទទួលបានលទ្ធផលសិក្សា និងភាពឆ្លើយតប ព្រមទាំងយុវជនជាច្រើនកាន់តែមានលទ្ធភាពចូលរៀនការអប់រំបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព | ២.១ ការទទួលបានការអប់រំមធ្យមសិក្សាទុតិយភូមិ ដែលមានគុណភាពប្រកបដោយសមធម៌ ក្នុងបរិយាកាសសិក្សាដោយផ្តល់នូវសុវត្ថិភាព និងអំណោយផល (៤.១, ៤.ខ, ៤.គ) | ១៣ | ៦ | ១៩ |
| | ២.២ យុវជនជាច្រើននាក់កាន់តែទទួលបានការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយគុណភាព (៤.៣) | ១ | ១ | ២ |
| អាទិភាពទី ៣៖ ធានាឱ្យស្ត្រី និងបុរសទាំងអស់ មានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងឧត្តមសិក្សា ប្រកបដោយគុណភាព | ៣.១ ស្ត្រី និងបុរសទាំងអស់កាន់តែទទួលបានការអប់រំកម្រិតឧត្តមសិក្សាដែលមានគុណភាព (៤.៣ ៤.ក) | ៣ | ៥ | ៨ |
| | ៣.២ ការបង្កើនលទ្ធភាពទទួលបានការអប់រំបច្ចេកទេស និងវិជ្ជាជីវៈដែលមានគុណភាព និងបានទទួលបំណិនដែលពាក់ព័ន្ធដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ (៤.៤) | ៥ | ១ | ៦ |
| អាទិភាពទី៤៖ យុវជន និងមនុស្សពេញវ័យទាំងអស់ទទួលបានចំណេះដឹង | ៤.១ កំណើនបំណិនអក្ខរកម្មរបស់យុវជន និងបំណិនអក្ខរកម្មវិជ្ជាជីវៈ (៤.៦) | ៣ | ៣ | ៦ |

| | | | | |
|---|---|---|---|---|
| អក្ខរកម្ម និងលេខនព្វន្ត ព្រមទាំងអ្នកសិក្សាគ្រប់វ័យទាំងអស់កាន់តែមានឱកាសច្រើនឡើងៗក្នុងការសិក្សាពេញមួយជីវិត | | | | |
| អាទិភាពទី៥៖អភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំមានភាពល្អប្រសើរជាងមុននៅគ្រប់កម្រិត | ៥.១ សាលារៀន គ្រឹះស្ថានសិក្សាត្រូវបានអភិវឌ្ឍឱ្យកាន់តែមានស្វ័យភាពបំពេញការងារប្រកបដោយវិជ្ជាជីវៈ និងគណនេយ្យភាព | - | ៣ | ៣ |
| | ៥.២ អភិបាលកិច្ច និងការគ្រប់គ្រងដែលបានធ្វើឡើងប្រកបដោយតម្លាភាពគណនេយ្យភាព មានការចូលរួម មានប្រសិទ្ធភាព និងមានសមត្ថភាព (៤.៥) | ២ | - | ២ |
| | ៥.៣ មានទិន្នន័យដែលត្រឹមត្រូវ និងអាចជឿទុកចិត្តបានទាន់ពេលវេលាសម្រាប់ការរៀបចំផែនការអប់រំការតាក់តែងគោលនយោបាយ និងការពិនិត្យតាមដាន | - | ៨ | ៨ |
| **សរុប** | | **៥៦** | **៤២** | **៩៨** |

*ប្រភព៖ វិទ្យាស្ថានស្ថិតិអង្គការយូណេស្កូ (២០១៧)*

### *៦.២.២ ការវាយតម្លៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤*

ក្របខណ្ឌសកម្មភាពសម្រាប់ការអប់រំឆ្នាំ ២០៣០ បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការវាយតម្លៃឱ្យបានទៀងទាត់ ម៉ត់ចត់ និងមានលក្ខណៈបរិយាបន្ន ក្រោមការដឹកនាំផ្ទាល់របស់ប្រទេសនីមួយៗលើវឌ្ឍនភាពក្នុងការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ការវាយតម្លៃនឹងត្រូវធ្វើឡើងជារៀងរាល់ឆ្នាំដើម្បីពិនិត្យតាមដានវឌ្ឍនភាព និងកំណត់ពីភាពពាក់ព័ន្ធ ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងផលប៉ះពាល់នៃគោលនយោបាយ កម្មវិធី ឬគម្រោងនានា។ ការពិនិត្យឡើងវិញថ្នាក់ជាតិនឹងត្រូវធ្វើឡើងដោយបំពេញបន្ថែមពីការពិនិត្យឡើងវិញថ្នាក់ក្រោមជាតិ ដែលត្រូវធ្វើឡើងនៅថ្នាក់រាជធានី-ខេត្ត។ ដំណើរការ ឬ រចនាសម្ព័ន្ធថ្មី ពុំត្រូវបានស្នើបង្កើតឡើងទេ។ ការពិនិត្យឡើងវិញគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤នឹងត្រូវធ្វើឡើងដោយប្រើប្រាស់ដំណើរការពិនិត្យតាមដាន និងស្ថាប័នដែលមានស្រាប់។ សមត្ថភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាអង្គភាពថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាននឹងត្រូវពង្រឹងបន្ថែមទៀតដើម្បីផ្តល់ភស្តុតាងឱ្យបានទាន់ពេលវេលា និងកាត់បន្ថយហានិភ័យ

នានា និងប្រមែលប្រមូលព័ត៌មានសម្រាប់ធ្វើការកែតម្រូវ។ ការវាយតម្លៃនៅថ្នាក់ជាតិនឹងជួយឱ្យមានការបង្កើត និងការប្រើប្រាស់ទិន្នន័យទាន់ពេលវេលា និងងាយស្រួលទទួលបានប្រកបដោយគុណភាពអាចជឿទុកចិត្តបាន និងបែងចែកទៅតាមប្រភេទ។ ការពិនិត្យឡើងវិញនៅថ្នាក់ជាតិនឹងធ្វើឡើងដោយទូលំទូលាយ និងតម្លាភាព ដែលផ្តល់លទ្ធភាពឱ្យគ្រប់គ្នាអាចចូលរួមចំណែកនៅក្នុងដំណើរការនេះ ក្នុងនោះ រួមបញ្ចូលទាំងអង្គការសង្គមស៊ីវិលផងដែរ។

### ៦.២.៣ ការវាយការណ៍នៅថ្នាក់ជាតិ

ប្រព័ន្ធរបាយការណ៍ថ្នាក់ជាតិ គួរតែជាប្រព័ន្ធសំខាន់បំផុតសម្រាប់ដំណើរការពិនិត្យឡើងវិញលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ដោយសារតែប្រទេសនីមួយៗត្រូវមានភាពជាម្ចាស់លើរបៀបវារៈឆ្នាំ២០៣០ និងគោលការណ៍ស្នូលនៃរបៀបវារៈនេះ គឺការមិនទុកឱ្យនរណាម្នាក់ចោល។ របាយការណ៍ប្រចាំឆ្នាំថ្នាក់ជាតិ ស្តីពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤នឹងត្រូវរៀបចំឡើងដោយបង្ហាញឱ្យឃើញពីវឌ្ឍនភាពក្នុងការសម្រេចចំណុចដៅសំខាន់ៗ។ របាយការណ៍ទាំងនេះនឹងកំណត់អំពីចំណុចខ្វះខាតក្នុងការអនុវត្ត រួមទាំងចំណុចខ្វះខាតផ្នែកទិន្នន័យ និង យុទ្ធសាស្ត្រផងដែរ ក៏ដូចជាបញ្ហាប្រឈមផ្នែកគោលនយោបាយ ជម្រើស សកម្មភាព និងបញ្ហាថ្មីៗមួយចំនួន។ របាយការណ៍ទាំងនេះត្រូវរៀបរាប់ពីនិន្នាការសូចនាករនានានិងវិភាគពីមូលហេតុ និងលើកឡើងសំណូមពរកម្រិតគោលនយោបាយ ដើម្បីដោះស្រាយបញ្ហាប្រឈមថ្មីៗ។ របាយការណ៍នេះក៏នឹងធ្វើការវិភាគពីនិន្នាការដោយកំណត់នូវចំណុចដៅសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ក្នុងករណីវឌ្ឍនភាពសម្រេចបានយឺតយ៉ាវ ឬ ថយចុះ (មិនទំនងជាសម្រេចចំណុចដៅណាមួយត្រឹមឆ្នាំ ២០៣០) ឬ មានភាពគ្រប់គ្រាន់ ឬ ធ្វើបានលឿន (ទំនងជាសម្រេចបាន ឬ សម្រេចបានលើសពីការរំពឹងទុក)។

### ៦.២.៤ ការវាយតម្លៃ

លើសពីនេះ ការពិនិត្យតាមដានជាទៀងទាត់ ក្របខណ្ឌការពិនិត្យតាមដាន និងវាយតម្លៃដែលស្នើឡើង ត្រូវបញ្ចូលគ្នាការវាយតម្លៃតាមដំណាក់កាល និងការវាយតម្លៃចុងក្រោយ ដែលត្រូវដាក់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំបន្ទាប់។ ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនឹងត្រូវធ្វើឡើងទម្រង់ជាការវាយតម្លៃតាមដំណាក់កាល ដើម្បីពិនិត្យមើលភាពស័ក្តិសិទ្ធិ និងផលប៉ះពាល់រយៈពេលខ្លីនៃការអនុវត្តគម្រោង និងធ្វើការកែតម្រូវសកម្មភាពក្នុងករណីដែលចាំបាច់។ ជាពិសេស ការវាយតម្លៃនឹងពិនិត្យមើលផ្តោតថាតើសកម្មភាពអនុវត្តត្រូវតាមផែនការឬទេ និងសម្រេចបានលទ្ធផលគ្រោងទុកដែរឬទេ។ ការវាយតម្លៃទាំងនេះនឹងកំណត់ឱ្យឃើញនូវបទពិសោធន៍នានាដែលទទួលបានពីការអនុវត្តក្នុងដំណាក់កាលដំបូងៗ។ ការវាយតម្លៃនឹងធ្វើឡើងនៅពេលបញ្ចប់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដែល

ផ្តោតផលប៉ះពាល់ និងនិរន្តរភាពនៃកម្មវិធីនានា ព្រមទាំងវាយតម្លៃថាតើ សម្រេចបានដែរឬទេ។ សមត្ថភាពចាំបាច់ត្រូវអភិវឌ្ឍបន្ថែមទៀតក្នុងក្របខណ្ឌក្រសួងអប់រំ យុវជន និងកីឡា ដើម្បីអនុវត្ត ដឹកនាំ និងគាំទ្រដល់ការវាយតម្លៃទាំងនេះ ក៏ដូចជាការប្រើប្រាស់លទ្ធផលវាយតម្លៃសម្រាប់អភិវឌ្ឍកម្មវិធីនានា។

## ៦.៣ ក្របខណ្ឌលទ្ធផលសំខាន់ៗ

ក្របខណ្ឌលទ្ធផល បង្ហាញដោយសង្ខេបពីសូចនាករសំខាន់ៗនៃកម្រិតវិស័យ ដែលត្រូវប្រើប្រាស់សម្រាប់ពិនិត្យតាមដានលទ្ធផលនៃវិស័យអប់រំ។ ក្របខណ្ឌនេះបង្ហាញពីទិន្នន័យសូចនាករឆ្នាំគោល ចំណុចដៅសំខាន់ៗ ក៏ដូចជាចំណុចដៅឆ្នាំ២០៣០។ សូចនាករដែលបានកំណត់ក្នុងក្របខណ្ឌនេះត្រូវបានរៀបចំដោយផ្អែកតាមទិន្នន័យដែលមាន និងបន្សុីជាមួយនឹងសូចនាករក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដើម្បីអាចប្រៀបធៀបគ្នាបាន។ សូចនាករទាំងនេះឆ្លើយតបនឹងសូចនាករកម្រិតសកល និងតាមប្រធានបទដែលបានកំណត់នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤-ការអប់រំឆ្នាំ២០៣០។ ទោះយ៉ាងណា នៅមានផ្នែកជាច្រើនទៀតដែលពុំទាន់បានឆ្លើយតបនៅឡើយ។ ក្របខណ្ឌនេះ គួរតែត្រូវបានកែសម្រួល និងធ្វើបច្ចុប្បន្នភាពផ្អែកតាមទិន្នន័យដែលមានគ្របដណ្តប់លើផ្នែកទាំងអស់ ដូចបានកំណត់ក្នុងក្របខណ្ឌសូចនាករនេះ។

### តារាងទី ២៨ ៖ ម៉ាទ្រិកលទ្ធផល

| អាទិភាពគោលនយោបាយ | លទ្ធផលរំពឹងទុក | សូចនាករ | ឆ្នាំគោល ២០១៨ | ២០១៩-២០២៣ | ២០២៤-២០២៨ | ២០៣០ |
|---|---|---|---|---|---|---|
| អាទិភាពទី ១៖ កុមារី និងកុមារគ្រប់រូបទទួលបានការគាំពារនិងការអប់រំកុមារតូច និងការអប់រំមត្តេយ្យសិក្សា ប្រកបដោយគុណភាព និងបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន (បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ) ដោយឥតបង់ថ្លៃ ប្រកប | ១.១ កុមារតូចគ្រប់រូបអាយុក្រោម ៥ ឆ្នាំ កាន់តែទទួលបានការគាំពារនិងអភិវឌ្ឍកុមារតូច និងការអប់រំមត្តេយ្យសិក្សាប្រកបដោយគុណភាព និងត្រៀមលក្ខណៈពេញលេញ ដើម្បីទទួលការអប់រំបឋមសិក្សា | អត្រារួមនៃការសិក្សានៅមត្តេយ្យសិក្សា | ៤១,៣% | ៤៥,៧% | ៥០,១% | ៥១,៨% |
| | | អត្រាចូលរៀនកុមារអាយុ ៥ឆ្នាំ គ្រប់រូបភាព | ៦៨,៥% | ៧៦,០% | ៨១,៥% | ៨៤,១% |
| | | ភាគរយសិស្សថ្នាក់ទី ១ បានឆ្លងកាត់កម្មវិធីអប់រំកុមារតូចគ្រប់រូបភាព | ៦៥,០% | ៧៤,៥% | ៨០,៣% | ៨២,៨% |
| | | ភាគរយសាលាមត្តេយ្យសិក្សាដែលមានទឹកស្អាតសម្រាប់ទទួលទាន សម្អារអនាម័យ និងកន្លែងលាងដៃ | ៣០,៥% | ៥៥,៣% | ៧២,៩% | ៨០,០% |

| អាទិភាពគោលនយោបាយ | លទ្ធផលរំពឹងទុក | សូចនាករ | ឆ្នាំគោល ២០១៨ | ២០១៩-២០២៣ | ២០២៤-២០២៨ | ២០៣០ |
|---|---|---|---|---|---|---|
| ដោយសមធម៌ និងគុណភាព ដែលទទួលបានលទ្ធផលសិក្សាប្រកបដោយប្រសិទ្ធភាព និងភាពឆ្លើយតប | | ភាគរយសាលាមត្តេយ្យសិក្សាដែលមានអគ្គិសនីអ៊ិនធឺណិតសម្រាប់បង្រៀននិងរៀននិងកុំព្យូទ័រ | ២០,៤% | ៣៥,២% | ៤៥,៨% | ៥០,០% |
| | | ភាគរយគ្រូបង្រៀននៅមត្តេយ្យសិក្សាដែលមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិ | ៥៧,៦% | ៦២,៤% | ៧៦,៨% | ៨០,០% |
| | | ផលធៀបសិស្ស-គ្រូនៅមត្តេយ្យសិក្សា | ៣៨ | ៣២ | ២៧ | ២៥ |
| | | ភាគរយគ្រូបង្រៀននៅមត្តេយ្យសិក្សាបឋមសិក្សាមធ្យមសិក្សា ដែលឆ្លងកាត់ការបណ្តុះ-បណ្តាលនិងទទួលវិក្រឹតការ | ៩៩,០% | ៩៩,៥% | ៩៩,៩% | ១០០% |
| | ១.២ កុមារី និងកុមារគ្រប់រូបបញ្ចប់ការអប់រំកម្រិតមូលដ្ឋាន (បឋមសិក្សា និង មធ្យមសិក្សាបឋមភូមិ) ប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ ក្រោមការឧបត្ថម្ភពីរដ្ឋ និងផ្តល់ដោយឥតបង់ថ្លៃ និងទទួលបានបំណិនអក្ខរកម្មវិជ្ជាជីវៈ ផ្នែកអក្សរ និងលេខនព្វន្ត ក៏ដូចជាទទួលបាន | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | ៨២,៧% | ៨៦,២% | ៨៩,៧% | ៩១,១% |
| | | ភាគរយសាលាបឋមសិក្សាដែលមានទឹកស្អាតសម្រាប់ទទួលទាន សម្ភារអនាម័យ និងកន្លែងលាងដៃ | ៦០,២% | ៨០,១% | ៩៤,៣% | ១០០% |
| | | ភាគរយសាលាបឋមសិក្សាដែលមានអគ្គិសនីអ៊ិនធឺណិតសម្រាប់បង្រៀននិងរៀន និងកុំព្យូទ័រ | ៣៦,៥% | ៥៣,២% | ៦៥,២% | ៧០,០% |

| អាទិភាពគោលនយោបាយ | លទ្ធផលរំពឹងទុក | សូចនាករ | ឆ្នាំគោល ២០១៨ | ២០១៩-២០២៣ | ២០២៤-២០២៨ | ២០៣០ |
|---|---|---|---|---|---|---|
| | ចំណេះដឹងមុខវិជ្ជា និងទទួលបានបំណិនពាក់ព័ន្ធនឹងការគិត និងបំណិនមិនពាក់ព័ន្ធនឹងការគិតដែលផ្តល់លទ្ធភាពឱ្យពួកគេអាចអភិវឌ្ឍសក្តានុពលរបស់ពួកគេយ៉ាងពេញលេញ | ភាគរយគ្រូបង្រៀនបឋមសិក្សាដែលមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិ | ៦២,៩% | ៧៦,៥% | ៨១,៦% | ៩០,០% |
| | | ផលធៀបសិស្ស-គ្រូនៅបឋមសិក្សា | ៤៤ | ៤៧ | ៤៩ | ៥០ |
| | | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ៤៦,៥% | ៥២,៦% | ៥៨,៧% | ៦១,១% |
| | | ភាគរយសាលាមធ្យមសិក្សា ដែលមានអគ្គិសនី អ៊ីនធឺណិតសម្រាប់បង្រៀននិងរៀន និងកុំព្យូទ័រ | ៣៣,០% | ៤៧,៦% | ៥៦,៥% | ៦០,០% |
| | | ភាគរយនៃសាលាបឋមសិក្សា និងមធ្យមសិក្សាដែលមានជម្រាលសម្រាប់ជនពិការ | ០% | ១០,៧% | ១៧,៣% | ២០,០% |
| | | ភាគរយគ្រូបង្រៀនមធ្យមសិក្សា ដែលមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិ | ៣៤,៥% | ៥២,៣% | ៦៤,៩% | ៧០,០% |
| | | ផលធៀបសិស្ស-គ្រូមធ្យមសិក្សាបឋមភូមិ | ២២ | ៣៣ | ៤២ | ៤៥ |
| | | ភាគរយគ្រូមធ្យមសិក្សាទទួលបានវិក្រឹតការ | ៣,៩% | ១៦,៩% | ២៦,៣% | ៣០% |
| **អាទិភាពទី២៖** កុមារី និងកុមារាទាំងអស់ បញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិដោយទទួលបានលទ្ធផលសិក្សា និងភាពឆ្លើយតប | ២.១ កុមារី និងកុមារាគ្រប់រូបបញ្ចប់ការអប់រំមធ្យមសិក្សាទុតិយភូមិប្រកបដោយគុណភាពបរិយាបន្ន និងសមធម៌ក្រោមការឧបត្ថម្ភពីរដ្ឋ និងផ្តល់ដោយឥតបង់ថ្លៃ និងទទួលបានបំណិនអក្ខរកម្ម | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | ២៣,៦% | ៣២,៥% | ៤១,៤% | ៤៥,០% |
| | | ភាគរយសាលាមធ្យមសិក្សាទុតិយភូមិដែលមានទឹកស្អាតសម្រាប់ទទួលទាន សម្ភារអនាម័យ និងកន្លែងលាងដៃ | ៥៩,៤% | ៧៤,៧% | ៨៥,៦% | ៩០% |

| អាទិភាពគោលនយោបាយ | លទ្ធផលរំពឹងទុក | សូចនាករ | ឆ្នាំគោល ២០១៨ | ២០១៩-២០២៣ | ២០២៤-២០២៨ | ២០៣០ |
|---|---|---|---|---|---|---|
| ព្រមទាំងយុវជនជាច្រើនកាន់តែមានលទ្ធភាពចូលរៀនការអប់រំបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព | វិជ្ជាជីវៈផ្នែកអក្សរ និងលេខនព្វន្ត ក៏ដូចជាទទួលបានចំណេះដឹងមុខវិជ្ជា និងទទួលបានបំណិនពាក់ព័ន្ធនឹងការគិត និងបំណិនមិនពាក់ព័ន្ធនឹងការគិត ដែលផ្តល់លទ្ធភាពឱ្យពួកគេអាចអភិវឌ្ឍសក្តានុពលរបស់ពួកគេយ៉ាងពេញលេញ | ភាគរយសាលាមធ្យមសិក្សាដែលមានអគ្គិសនី អ៊ីនធឺណិតសម្រាប់បង្រៀន និងរៀន និងកុំព្យូទ័រ | ៦២,៤% | ៨០,១% | ៩២,៩% | ៩៨,០% |
| | | ភាគរយគ្រូបង្រៀននៅមធ្យមសិក្សាដែលមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិ | ៩៨,០% | ៩៨,៥% | ៩៨,៩% | ៩៩,០% |
| | | ផលធៀបសិស្ស-គ្រូនៅមធ្យមសិក្សាទុតិយភូមិ | ២៣ | ៣២ | ៣៨ | ៤០ |
| | ២.២ យុវជនជាច្រើនកាន់តែមានលទ្ធភាពចូលរៀនការអប់រំបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព | | | | | |
| អាទិភាពទី ៣៖ ធានាឱ្យស្ត្រី និងបុរសទាំងអស់មានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងឧត្តមសិក្សាប្រកបដោយគុណភាព | ៣.១ ស្ត្រី និងបុរសគ្រប់រូបកាន់តែទទួលបានការអប់រំឧត្តមសិក្សាប្រកបដោយគុណភាព | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា | ១១,៦% | ១៦,៩% | ២២,៧% | ២៥,០% |
| | ៣.២ ស្ត្រី និងបុរសគ្រប់រូប កាន់តែអាចទទួលបានការអប់រំបច្ចេកទេស និងវិជ្ជាជីវៈប្រកបដោយគុណភាព និងទទួលបានជំនាញពាក់ព័ន្ធសម្រាប់ឆ្លើយតបទៅនឹងតម្រូវការរបស់ទីផ្សារការងារ | អត្រារួមនៃការសិក្សាសម្រាប់អប់រំបច្ចេកទេស (អាយុ១៥-២៤ឆ្នាំ) | ០,០៣% (២០១៦) | ១៨,៧% | ៣០,៣% | ៣៥,០% |
| **អាទិភាពទី ៤៖** យុវជន និងមនុស្សពេញវ័យទាំងអស់ ទទួលបានចំណេះដឹង | ៤.១ យុវជន និងមនុស្សពេញវ័យ ត្រូវសម្រេចឱ្យបាននូវបំណិនអក្ខរកម្ម វិជ្ជាជីវៈផ្នែកអក្សរ និងលេខនព្វន្ត ដែល | អត្រាអក្ខរកម្មមនុស្សពេញវ័យ (អាយុចាប់ពី ១៥ឆ្នាំឡើងទៅ) | ៨២,៥% | ៨៨,០% | ៩៣,៥% | ៩៥,៧% |

| អាទិភាពគោលនយោបាយ | លទ្ធផលរំពឹងទុក | សូចនាករ | ឆ្នាំគោល ២០១៨ | ២០១៩-២០២៣ | ២០២៤-២០២៨ | ២០៣០ |
|---|---|---|---|---|---|---|
| អក្ខរកម្ម និង លេខនព្វន្ត ព្រមទាំងអ្នកសិក្សាគ្រប់វ័យទាំងអស់ កាន់តែមានឱកាសច្រើនឡើងៗ ក្នុងការសិក្សាពេញមួយជីវិត | ពាក់ព័ន្ធក្នុងកម្រិតដែលមានការទទួលស្គាល់សមមូលនឹងការបញ្ចប់ការអប់រំកម្រិតមូលដ្ឋានប្រកបដោយជោគជ័យ | | | | | |
| អាទិភាពទី ៥៖ អភិបាលកិច្ច និង ការគ្រប់គ្រងវិស័យអប់រំ មានភាពល្អប្រសើរជាងមុននៅគ្រប់កម្រិត | ៥.១ សាលារៀន គ្រឹះស្ថានសិក្សា ត្រូវបានអភិវឌ្ឍក្លាយទៅជាគ្រឹះស្ថានដែលមានស្វ័យភាពវិជ្ជាជីវៈ និង គណនេយ្យភាពច្រើនជាងមុន | | | | | |
| | ៥.២ អភិបាលកិច្ច និង ការគ្រប់គ្រងវិស័យអប់រំ មានតម្លាភាព គណនេយ្យភាព មានការចូលរួម មាន ប្រសិទ្ធភាព និង ធ្វើឡើងប្រកបដោយសមត្ថភាព | | | | | |
| | ៥.៣ ទិន្នន័យសុក្រឹត និងជឿទុកចិត្តបានត្រូវផលិតបានទាន់ពេលវេលាសម្រាប់រៀបចំផែនការ និងគាក់តែងគោលនយោបាយអប់រំ | | | | | |